# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# វិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀន ឱ្យមានប្រសិទ្ធភាពសៀវភៅណែនាំ សម្រាប់គ្រូបង្រៀនថ្នាក់បឋមសិក្សា




## សៀវភៅណែនាំគ្រូបង្រៀនថ្នាក់បឋមសិក្សា

youtube.com/moeyscambodia
sala.moeys.gov.kh
t.me/moeysnews

**រចនាបថ៖** រក្សាសិទ្ធិគ្រប់យ៉ាង © Graphic Roots Co., Ltd. /2019/
**រូបភាព៖** រក្សាសិទ្ធិគ្រប់យ៉ាង © UNICEF Cambodia./2019/ ច័ន្ទ ពិសី

សម្រាប់ការផលិតឡើងវិញ ទោះបីផ្នែកណាមួយនៃឯកសារនេះក៏ដោយ ត្រូវសុំការអនុញ្ញាតជាមុន។

**សូមទាក់ទង៖**
ក្រសួងអប់រំ យុវជន និងកីឡា
អគារលេខ #៨០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ/ទូរសារ៖ +៨៥៥ ២៣ ២១៩ ២៨៥
អ៊ីមែល៖ info@moeys.gov.kh

ភ្នំពេញ ឆ្នាំ២០១៩

# អារម្ភកថា

ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំបន្តកែលម្អសេវាអប់រំឱ្យកាន់តែមានគុណភាព និងធានាថា យុវជន និងកុមារកម្ពុជាគ្រប់រូប មានឱកាសស្មើៗគ្នាក្នុងការទទួលបានការអប់រំ ស្របតាមរដ្ឋធម្មនុញ្ញ និងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ ពោលគឺគោលការណ៍មិនរើសអើងអំពីស្ថានភាពសង្គម ភូមិសាស្ត្រ ជនជាតិ សាសនា ភាសា ភេទ និងកាយសម្បទា។ ទន្ទឹមនឹងនេះ វិស័យអប់រំនៅឆ្នាំ២០៣០ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ដែលការអប់រំគឺជាគន្លឹះដែលធ្វើឱ្យជីវិតល្អប្រសើរសម្រាប់កុមារគ្រប់រូប និងជាមូលដ្ឋានគ្រឹះរបស់សង្គមដែលមានភាពរឹងមាំ និងផ្ដល់ជូនការអប់រំប្រកបដោយបរិយាកាសសិក្សាមានសុវត្ថិភាព មានការគាំទ្រ និងមានសន្តិសុខដែលមិនមានអំពើហិង្សា ហើយត្រូវឱ្យកុមារទាំងអស់នៅក្នុងសាលារៀន និងទទួលបានការរៀនសូត្រមួយដ៏រីករាយ។

ក្រសួងបានខិតខំអភិវឌ្ឍសាលារៀន ឱ្យក្លាយជាទីកន្លែងដែលមានសុវត្ថិភាពដល់កុមារគ្រប់រូប ជាពិសេសកុមារពិការ កុមារកំព្រា និងក្រុមកុមាររងាយរងគ្រោះដទៃទៀត។ ដើម្បីធ្វើឱ្យសម្រេចនូវកិច្ចការងារទាំងនេះ គោលនយោបាយស្ដីពីកិច្ចការពារកុមារនៅសាលារៀន ត្រូវបានដាក់ឱ្យអនុវត្តក្នុងឆ្នាំ ២០១៦ ដោយធានាថា កុមារគ្រប់រូបនឹងទទួលបានការការពារពីទង្វើទាំងឡាយដែលនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់ឱកាសទទួលបានការអប់រំ សុខភាព និងសុខុមាលភាពរបស់ពួកគេ ព្រមទាំងទទួលបាននូវការគោរពនូវសេចក្ដីថ្លៃថ្នូរ និងសេរីភាព រួចផុតពីទណ្ឌកម្មផ្សេងៗគ្រប់ទម្រង់ ដែលក្នុងនោះផងដែរ ការអនុវត្តកម្មវិធីវិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព ក៏បានដើរតួយ៉ាងសំខាន់ក្នុងការធ្វើឱ្យការបង្រៀនមានលក្ខណៈអហិង្សា ដោយប្រើគោលវិធីសិស្សមជ្ឈមណ្ឌលស្របតាមកម្មវិធីសាលាកុមារមេត្រី។

ក្នុងការអនុវត្តវិន័យបែបវិជ្ជមាន គឺស្របតាមយុទ្ធសាស្ត្រទី៤ នៃគោលនយោបាយ ស្ដីពីសាលាកុមារមេត្រី និងមានចែងយ៉ាងច្បាស់ក្នុងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយ ស្ដីពីកិច្ចការពារកុមារនៅសាលារៀន ដោយមានឯកសារប្រតិបត្តិ ស្ដីពីការទប់ស្កាត់អំពើហិង្សាលើកុមារ ដើម្បីគាំទ្រដល់ការអនុវត្តផងដែរ។ បច្ចុប្បន្ននេះ ដើម្បីជំរុញឱ្យការអនុវត្តវិន័យបែបវិជ្ជមានកាន់តែមានប្រសិទ្ធភាព ក្រសួងបានរៀបចំឯកសារប្រតិបត្តិ ស្ដីពីវិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាពចំនួន៤ បន្ថែមទៀត គឺ៖ ១.សៀវភៅណែនាំនាយកសាលារៀន ២.សៀវភៅណែនាំគ្រូបង្រៀនថ្នាក់បឋមសិក្សា ៣.សៀវភៅទប់ស្កាត់អំពើហិង្សាលើកុមារនិង ៤.សៀវភៅមគ្គុទេសក៍សម្រាប់អ្នកសម្របសម្រួល។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ បុគ្គលិកអប់រំ អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍពាក់ព័ន្ធ ជាពិសេសអង្គការ UNICEF ដែលបានជួយគាំទ្រផ្នែកបច្ចេកទេស សម្ភារៈ និងថវិកា ក្នុងការរៀបចំចងក្រងឯកសារប្រតិបត្តិនេះឡើង។

ក្រសួងសង្ឃឹមថា អង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍនានា សហគមន៍ និងអ្នកពាក់ព័ន្ធ ជាពិសេសលោកគ្រូ អ្នកគ្រូនឹងចូលរួមយ៉ាងសកម្មក្នុងការផ្សព្វផ្សាយ គាំទ្រ និងជំរុញការអនុវត្តឯកសារប្រតិបត្តិ ស្ដីពីវិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព ឱ្យទទួលបានជោគជ័យ ដើម្បីជាឧត្តមប្រយោជន៍ដល់កុមារគ្រប់រូប ក៏ដូចជាការអភិវឌ្ឍមូលធនមនុស្សនៅកម្ពុជា។

ថ្ងៃ សុក្រ ៣កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

# មាតិកា


អារម្ភកថា ................................................ ៣
មាតិកា ................................................ ៤
ពាក្យបំព្រួញ ................................................ ៦
សេចក្តីផ្តើម ................................................ ៧
តើសៀវភៅណែនាំនេះជាអ្វីនិងសម្រាប់អ្នកណា ................................................ ៧
តើអ្នកនឹងរៀនបានអ្វីខ្លះ ................................................ ៧
តើប្រើប្រាស់ឯកសារនេះដោយរបៀបណា ................................................ ៧
១. ការយល់ដឹងអំពីអំពើហិង្សាលើកុមារនិងទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតី ................................................ ៩
១.១ ការយល់ដឹងអំពីទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតី ................................................ ៩
តើទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីជាអ្វី? ................................................ ៩
និយមន័យអំពីទម្រង់នៃអំពើហិង្សា ................................................ ១០
១.២ ជំនឿខុសឆ្គងលើទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតី ................................................ ១២
១.៣ តើមានផលវិបាកអ្វីខ្លះ? ................................................ ១៧
១.៤ តើទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតីមានប្រសិទ្ធភាពឬទេ? ................................................ ៣១
១.៥ ការដាក់វិន័យបែបវិជ្ជមាននិងការគ្រប់គ្រងថ្នាក់រៀនដោយប្រសិទ្ធភាព ................................................ ៣២
តើវិន័យបែបវិជ្ជមានជាអ្វី? ................................................ ៣៣
តើការគ្រប់គ្រងថ្នាក់រៀនដោយប្រសិទ្ធភាពជាអ្វី? ................................................ ៣៤
២. ការបង្កើតទំនាក់ទំនងវិជ្ជមានរវាងគ្រូនិងសិស្ស ................................................ ៣៦
២.១ ការផ្តល់ភាពកក់ក្តៅនិងការណែនាំ ................................................ ៣៦
២.២ បទពិសោធន៍"អារម្មណ៍ល្អ" ច្រើនជាងអារម្មណ៍"មិនល្អ" ................................................ ៣៩
២.៣ ការស្វែងយល់អំពីការលូតលាស់របស់កុមារ ................................................ ៤០
ចាប់ពីកំណើតទៅដល់អាយុ ៥ ឆ្នាំ (កុមារតូច) ................................................ ៤០
ចាប់ពី ៦ទៅដល់១២ឆ្នាំ (កុមារវ័យកណ្តាល) ................................................ ៤០
ការអភិវឌ្ឍផ្នែកស្មារតីនិងផ្លូវចិត្តរបស់សិស្ស ................................................ ៤៣
២.៤ ការធ្វើជាគំរូវិជ្ជមាន ................................................ ៤៥
២.៥ ការស្វែងយល់អំពីសិស្សរបស់អ្នក ................................................ ៥១
ស្វែងយល់អំពីប្រវត្តិគ្រួសារសិស្សរបស់អ្នក ................................................ ៥២
២.៦ ការស្វែងយល់អំពីវិធីសាស្ត្របង្រៀនតាមបែបប្រពៃណី ................................................ ៥៣
២.៧ តើគ្រូល្អមានលក្ខណៈបែបណា? ................................................ ៥៥
៣. ការរម្ងាប់កំហឹង ................................................ ៥៦
៣.១ តើព្រះពុទ្ធបានបង្រៀនអ្វីខ្លះអំពីភាពក្រេវក្រោធ/កំហឹង ................................................ ៥៦

៣.២ តើយើងធ្វើបែបណាដើម្បីរម្ងាប់កំហឹង? ....... ៥៨
៣.៣ អ្វីៗដែលយើងបាននិយាយសុទ្ធតែនាំមកនូវផលវិបាក ....... ៥៨

**៤. ការដាក់វិន័យបែបវិជ្ជមាន ....... ៦១**

៤.១ ការបង្រៀនសិស្សអំពីបំណិនជីវិត ....... ៦១
៤.២ ហេតុអ្វីបានជាកុមារ"ប្រព្រឹត្តមិនគប្បី"? ....... ៦៧
៤.៣ ការដាក់វិន័យបែបវិជ្ជមាន៖ជាជម្រើសដើម្បីជំនួសការដាក់ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតី ....... ៦៨
ការឆ្លុះបញ្ចាំង ....... ៧១
ការដាក់វិន័យ ....... ៧៥
ការផ្តល់សំណង ....... ៧៧
ជម្រើសចុងក្រោយ ....... ៧៩

**៥. ការគ្រប់គ្រងថ្នាក់រៀនឱ្យមានប្រសិទ្ធភាព ....... ៨១**

៥.១ តើគ្រូបង្រៀនបែបណាដែលមានប្រសិទ្ធភាព? ....... ៨១
៥.២ តើត្រូវចងក្រងបទបញ្ជាផ្ទៃក្នុងថ្នាក់រៀនជាមួយសិស្សដោយរបៀបណា? ....... ៨៣
៥.៣ ការលើកទឹកចិត្តឱ្យមានអាកប្បកិរិយាល្អ ....... ៨៦
៥.៤ របៀបធ្វើការជាមួយសិស្សមាន: ....... ៨៨
ការឆ្លើយតបបែបច្នៃប្រឌិតចំពោះបញ្ហាអាកប្បកិរិយា ....... ៨៩
ការយកចិត្តទុកដាក់៖តើត្រូវធ្វើបែបណា? ....... ៨៩
ការស្វែងរកឥទ្ធិពល៖តើត្រូវធ្វើបែបណា? ....... ៩០
ការបញ្ចៀសបរាជ័យ៖តើត្រូវធ្វើបែបណា? ....... ៩១

**ឯកសារយោង ....... ៩២**

**ឧបសម្ព័ន្ធ ....... ៩៤**

ឧបសម្ព័ន្ធ១. គំរូប័ណ្ណ - តើខ្ញុំជាអ្នកណា? ....... ៩៤
ឧបសម្ព័ន្ធ២. វិន័យបែបវិជ្ជមានជាការឆ្លើយតបនឹងអាកប្បកិរិយាមិនគប្បីរបស់សិស្ស៖ ជម្រើសផ្សេងៗ ក្រៅពីទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតី ....... ៩៥
ឧបសម្ព័ន្ធ៣. គំរូសម្រាប់កិច្ចសន្យាកែប្រែអាកប្បកិរិយា ....... ៩៧
ឧបសម្ព័ន្ធ៤. ការលើកសរសើរចំពោះអាកប្បកិរិយាល្អ ....... ៩៨

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ពាក្យបំព្រួញ

| | |
|---|---|
| **CVACS** | ការអង្កេតអំពីអំពើហិង្សាលើកុមារនៅកម្ពុជា |
| **CFS** | សាលាកុមារមេត្រី |
| **NGOs** | អង្គការមិនមែនរដ្ឋាភិបាល |
| **PED** | នាយកដ្ឋានបឋមសិក្សា |
| UNESCO | អង្គការអប់រំ វិទ្យាសាស្ត្រ វប្បធម៌នៃអង្គការសហប្រជាជាតិ |
| UNICEF | អង្គការមូលនិធិសហប្រជាជាតិដើម្បីកុមារ |

# សេចក្ដីផ្ដើម

## តើសៀវភៅណែនាំនេះជាអ្វីនិងសម្រាប់អ្នកណា ?

សៀវភៅណែនាំនេះត្រូវបានរៀបចំឡើងសម្រាប់គ្រូបង្រៀនថ្នាក់បឋមសិក្សានិងគ្រូបង្រៀនដែលមានសេចក្ដីប្រាថ្នាខ្ពស់។ សៀវភៅនេះអធិប្បាយអំពីបញ្ហាប្រចាំថ្ងៃដែលកើតមានឡើងនៅក្នុងសាលារៀននិងនៅក្នុងថ្នាក់រៀននិងមានគោលដៅលើកកម្ពស់ទំនាក់ទំនងវិជ្ជមានអហិង្សានិងទំនាក់ទំនងកុមារមេត្រីរវាងគ្រូនិងសិស្ស។

## តើអ្នកនឹងរៀនបានអ្វីខ្លះ ?

សៀវភៅណែនាំនេះជួយគ្រូនៅក្នុងការដោះស្រាយការប្រឈមនានា ដែលទាក់ទងនឹងវិន័យក្នុងថ្នាក់រៀនដើម្បីពង្រឹងគុណភាពនៃការបង្រៀននិងបង្កើតបរិយាកាសវិជ្ជមានសម្រាប់ការសិក្សា។ ដើម្បីសម្រេចគោលដៅនេះសៀវភៅណែនាំនេះផ្ដល់ជាឧបករណ៍អនុវត្តដើម្បីជួយធានាឱ្យមានវិន័យបែបវិជ្ជមាននៅក្នុងថ្នាក់រៀននិងការគ្រប់គ្រងថ្នាក់រៀនឱ្យមានប្រសិទ្ធភាព។

### សៀវភៅណែនាំនេះចែកចេញជា៥ជំពូកៈ

- **ជំពូកទីមួយ** "ការយល់ដឹងអំពីអំពើហិង្សាចំពោះកុមារនិងទណ្ឌកម្មលើរាងកាយនិងផ្លូវស្មារតី" នឹងជួយឱ្យគ្រូបង្រៀនយល់អំពីទម្រង់ខុសៗគ្នានៃអំពើហិង្សាលើកុមារីនិងកុមាររួមទាំងអំពើហិង្សាយេនឌ័រផងដែរ។ ជំពូកនេះស្វែងយល់ពីប្រពៃណីនិងជំនឿជាយូរលង់មកហើយអំពីទណ្ឌកម្មលើរាងកាយនិងផ្លូវស្មារតី និងអធិប្បាយអំពីផលវិបាកនៃមហន្តរាយបណ្ដាលពីទណ្ឌកម្មលើរាងកាយនិងផ្លូវស្មារតី។ ជំពូកនេះបង្ហាញពីសញ្ញាណនៃវិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនឱ្យមានប្រសិទ្ធភាព។
- **ជំពូកទីពីរ** "ការបង្កើតទំនាក់ទំនងវិជ្ជមានរវាងគ្រូនិងសិស្ស" បង្ហាញពីសមាសភាគសំខាន់ៗដូចជាការផ្ដល់ភាពកក់ក្ដៅនិងការណែនាំ។ គ្រូបង្រៀននឹងរៀនសូត្របន្ថែមទៀតផងដែរអំពីការវិវឌ្ឍរបស់កុមារ។ ជំពូកនេះពន្យល់អំពីដំណើរការស្មុគស្មាញនៃការសិក្សាដែលជាការប្រាស្រ័យទាក់ទងរវាងសមត្ថភាពរបស់សិស្សក្នុងការវិភាគព័ត៌មាននិងបរិយាកាសរៀនសូត្របែបកុមារមេត្រី។ ជំពូកនេះនិទានរឿងរ៉ាវអំពីគ្រូដែលដើរតួជាគំរូល្អនៅក្នុងការជួយកុមារឱ្យរៀនពីភាពខុសគ្នារវាងត្រូវនិងខុសនិងបង្កើតវិន័យសម្រាប់ខ្លួនឯង។ ជំពូកនេះឆ្លុះបញ្ចាំងអំពីវិធីសាស្ត្របង្រៀននាពេលបច្ចុប្បន្នដែលបើកឱកាសសម្រាប់បង្កើតឱ្យមានវិន័យបែបវិជ្ជមាននៅក្នុងថ្នាក់រៀន។
- **ជំពូកទីបី** "ការរម្ងាប់កំហឹង" ពន្យល់ពីរបៀបទប់ទល់នឹងកំហឹង។ ជំពូកនេះសង្ខេបនូវអ្វីដែលជាទ្រឹស្ដីនៃព្រះពុទ្ធសាសនាដែលបង្រៀនអំពីកំហឹង។ ជំពូកនេះបង្ហាញពីតម្រុយជាក់ស្ដែងអំពីរបៀបរម្ងាប់កំហឹង។
- **ជំពូកទីបួន** "វិន័យបែបវិជ្ជមាន" ពិនិត្យមើលកាន់តែពិស្ដារនូវវិន័យបែបវិជ្ជមាន និងជួយឱ្យគ្រូយល់ពីមូលហេតុដែលសិស្សកុមារប្រព្រឹត្តមិនគប្បី។ តារាងពិស្ដារមួយអំពីអាកប្បកិរិយាហាមឃាត់ចំពោះសិស្សនិងការដាក់វិន័យបែបវិជ្ជមានដែលបង្ហាញពីសារសំខាន់ៗនៃជំពូកនេះពោលគឺស្វែងរកនិងប្រើប្រាស់វិន័យបែបអហិង្សាដែលជួយសិស្សនៅក្នុងការស្វែងយល់កំហុសរបស់ខ្លួននិងរៀនកំហុសទាំងនោះ។
- **ជំពូកទីប្រាំ** "ការគ្រប់គ្រងថ្នាក់រៀនឱ្យមានប្រសិទ្ធភាព" បង្ហាញពីវិធីខុសៗគ្នា នៃការគ្រប់គ្រងថ្នាក់រៀនឱ្យមានប្រសិទ្ធភាព។ ជំពូកនេះមានផ្ដល់គំរូកិច្ចតែងការល្អសម្រាប់ការបង្រៀន និងបង្ហាញពីរបៀបចងក្រងបទបញ្ជាផ្ទៃក្នុងសម្រាប់ថ្នាក់រៀនជាមួយសិស្ស។ ជំពូកនេះផ្ដល់តម្រុយដែលប្រើការបានអំពីការអនុវត្តការងារក្រុមនៅក្នុងថ្នាក់រៀនដែលមានសិស្សច្រើននិងពន្យល់អំពីរបៀបដោះស្រាយបញ្ហាអាកប្បកិរិយាមានះរបស់សិស្ស។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## តើប្រើប្រាស់សៀវភៅណែនាំនេះដោយរបៀបណា?

សៀវភៅណែនាំនេះអាចយកទៅប្រើប្រាស់ជាឧបករណ៍ស្វ័យសិក្សា។ យើងស្នើឱ្យអានជំពូកនានាតាមលំដាប់លំដោយ។ សារសំខាន់ៗត្រូវបានគូសបញ្ជាក់ជាអក្សរដិតនិងមានសង្ខេបនៅក្នុងប្រអប់អត្ថបទ។ ប្រអប់សកម្មភាពបង្ហាញពីលំហាត់និងសកម្មភាពនានាដែលជួយគ្រូក្នុងការឆ្លុះបញ្ចាំងនិងបង្កើនការយល់ដឹងស៊ីជម្រៅអំពីប្រធានបទខុសៗគ្នា។ ប្រអប់យោបល់ផ្តល់ជាតម្រុយយោបល់និងសកម្មភាពដែលមានប្រយោជន៍ដែលគ្រូអាចយកទៅប្រើប្រាស់ដើម្បីដោះស្រាយស្ថានភាពប្រឈមនានាក្នុងថ្នាក់រៀន និងនៅតាមសាលារៀន។

ដើម្បីបង្កើតការរៀនសូត្រឱ្យកាន់តែមានភាពរីករាយឯកសារណែនាំនេះបានបញ្ចូលរូបត្លុកខុសៗគ្នា។ រូបត្លុកទាំងនេះត្រូវបានរៀបចំឡើងដើម្បីបង្ហាញទិដ្ឋភាពនានាដែលជួនកាលអាចកើតមាននៅក្នុងថ្នាក់រៀនឬនៅតាមសាលារៀន។ គោលបំណងនៃការបញ្ចូលរូបត្លុកទាំងនេះគឺបង្ហាញពីទម្លាប់ល្អនៅក្នុងថ្នាក់រៀននិងអំពីអ្វីដែលគ្មានប្រសិទ្ធភាពនិងគ្មានប្រយោជន៍។



# ១

# ការយល់ដឹងអំពីអំពើហិង្សាលើកុមារនិងទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតី

## ១.១ ការយល់ដឹងអំពីទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតី

### តើទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីជាអ្វី?

នៅក្នុងបរិបទនៃសាលារៀនទណ្ឌកម្មពាក់ព័ន្ធនឹងការបង្កការឈឺចាប់ដែលជាការដាក់ទោសមួយមកលើកុមារដែលមានអាកប្បកិរិយាមិនគប្បី។ ទណ្ឌកម្មបានផ្អែកលើបទបញ្ញាផ្ទៃក្នុងដែលថាកុមារត្រូវរងការឈឺចាប់ដើម្បីពួកគេអាចរៀនសូត្រពីបទពិសោធន៍ និងឈប់ប្រព្រឹត្តកំហុសនោះជាថ្មីឡើងវិញ។

- ទណ្ឌកម្មមិនមែនជាវិន័យទេ
- ទណ្ឌកម្ម
- បង្កការឈឺចាប់
- ធ្វើឱ្យសិស្សបាក់ទឹកចិត្ត
- ធ្វើឱ្យសិស្សបាត់បង់ទំនុកចិត្តលើខ្លួនឯង
- ធ្វើឱ្យពួកគេមិនចូលចិត្តឬថែមទាំងស្អប់សាលារៀនទៀតផង។



ទណ្ឌកម្មក្រោមរូបភាពណាមួយដោយប្រើកម្លាំងកាយដែលបង្កជាការឈឺចាប់។

- ការទះកំភ្លៀង
- ការទាញត្រចៀក ឬសក់
- ការទះ
- ការបង្ខំឱ្យកុមារមានជំហរមិនស្រួល
- ការដាល់
- ការបង្ខំឱ្យកុមារឈរនៅទីកន្លែងក្តៅ ឬត្រជាក់
- ការវាយ និងវត្ថុអ្វីមួយ
- ការដាក់កុមារក្នុងទូរខោអាវ ឬទូរដាក់ចានពែងកែវ



វាក៏ត្រូវបានធ្វើឡើងក្រោមរូបភាពណាមួយដែលមិនមែនប្រើកម្លាំងកាយ តែជាទណ្ឌកម្មផ្លូវចិត្តដូចជា៖

- ការគំរាមកំហែង
- ការហៅឈ្មោះចំ
- ការស្រែក
- ការមិនយកចិត្តទុកដាក់ ឬទុកចោល
- ការបង្អាប់ចំអក
- ការធ្វើឱ្យមានភាពអាម៉ាស់
- ការលេងសើចទៅលើកុមារ
- ភាពលម្អៀង

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ទាំងទណ្ឌកម្មលើរាងកាយនិងផ្លូវចិត្តជាការបំពានលើសិទ្ធិកុមារី និងកុមារា ដែលត្រូវគោរពមានភាពថ្លៃថ្នូរកិច្ចការពារដោយស្មើភាពនៅចំពោះមុខច្បាប់និងកិច្ចការពារពីអំពើហិង្សាគ្រប់បែបយ៉ាង។

**អនុសញ្ញាស្តីពីសិទ្ធិកុមារ**តម្រូវឱ្យផ្តល់កិច្ចការពារកុមារពី"គ្រប់ទម្រង់នៃអំពើហិង្សាលើរាងកាយឬស្មារតីការបង្ករបួសស្នាមនិងការបៀតបៀនការធ្វេសប្រហែសឬមិនយកចិត្តទុកដាក់ការធ្វើបាបឬការកេងប្រវ័ញ្ចដែលរួមទាំងការបៀតបៀនផ្លូវភេទផងដែរ" (មាត្រា១៩)។

## និយមន័យអំពីទម្រង់នៃអំពើហិង្សាលើកុមារ

នៅក្នុងសៀវភៅណែនាំនេះ**ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីរួមមានទាំងអំពើហិង្សាលើរាងកាយនិងផ្លូវចិត្ត**។

តារាងខាងក្រោមបង្ហាញនិយមន័យអំពីទម្រង់ខុសៗគ្នានៃអំពើហិង្សាលើកុមារដែលអាចកើតមានទាំងនៅក្នុង និងនៅក្រៅសាលារៀន។

| | |
|---|---|
| **អំពើហិង្សាលើកុមារ** | អង្គការសហប្រជាជាតិឱ្យនិយមន័យអំពើហិង្សាចំពោះកុមារស្របតាមមាត្រា១៩នៃអនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិៈ ប្រឆាំងនឹង"គ្រប់ទម្រង់នៃអំពើហិង្សាលើរាងកាយឬស្មារតីការបង្ករបួសស្នាមនិងការបៀតបៀនការធ្វេសប្រហែសឬមិនយកចិត្តទុកដាក់ចំពោះកុមារការធ្វើបាបឬការកេងប្រវ័ញ្ចដែលរួមទាំងការបៀតបៀនផ្លូវភេទផងដែរ។" |
| **អំពើហិង្សាយេនឌ័រ** | អំពើហិង្សាដែលនាំឱ្យ ឬអាចនឹងនាំបណ្តាលឱ្យមានគ្រោះថ្នាក់ ឬភាពឈឺចាប់ផ្នែករាងកាយ ផ្លូវភេទ និងផ្លូវចិត្តប្រឆាំងនឹងនរណាម្នាក់ផ្អែកលើការរើសអើងយេនឌ័រ តួនាទីយេនឌ័ររំពឹងទុក និងផ្នត់គំនិតយេនឌ័រ ឬផ្អែកលើឋានៈអំណាចខុសៗគ្នាដែលភ្ជាប់ទៅនឹងបញ្ហាយេនឌ័រ។ |
| **អំពើហិង្សាលើរាងកាយ** | អំពើហិង្សាលើរាងកាយ រួមមាន ទះកំផ្លៀង ច្រាន ដាល់ ទាត់ វាយនឹងរំពាត់ ឬវាយនឹងវត្ថុអ្វីមួយ ធ្វើឱ្យឈ្លក់ ខ្ទប់មុខធ្វើឱ្យលង់ទឹក ដុត ធ្វើឱ្យរលាកដោយចេតនា ឬធ្វើឱ្យរបួស ឬគំរាមដោយអាវុធ ដូចជា កាំបិត ឬអាវុធផ្សេងទៀត។ អំពើហិង្សាបែបនេះអាចកើតឡើងតែម្តងឬជាបន្តបន្ទាប់។ |
| **អំពើហិង្សាខាងផ្លូវចិត្ត** | អំពើហិង្សាខាងផ្លូវចិត្ត ត្រូវបានឱ្យនិយមន័យថាជាអាកប្បកិរិយាដោយពាក្យសម្តីដែលកើតមានជាបន្តបន្ទាប់ឬក្នុងករណីដាច់ដោយឡែកណាមួយ ដែលមិនសមស្របតាមកម្រិតអភិវឌ្ឍន៍របស់កុមារ មិនផ្តល់ការគាំទ្រដល់កុមារ និងមានលទ្ធភាពខ្ពស់ក្នុងការធ្វើឱ្យខូចសុខភាពផ្លូវចិត្ត ឬការអភិវឌ្ឍខាងរាងកាយ ផ្លូវចិត្ត ស្មារតី សីលធម៌ ឬសង្គមរបស់កុមារ។ |
| **ការសម្លុតធ្វើបាប** | ការសម្លុតធ្វើបាប អាចមានន័យថាជាការរំខាននិងបៀតបៀនម្តងហើយម្តងទៀត ឬជាលក្ខណៈប្រព័ន្ធមកលើអ្នកដទៃ។ ពេលខ្លះអាកប្បកិរិយាកាចសាហាវដែលជាការគំរាមកំហែង បន្តកើតមានជាប់រហូត ដែលបង្កឱ្យមានការគំរាមកំហែងដល់បងប្អូន កុមារដែលរស់នៅជិតខាង និងមិត្តរួមថ្នាក់។ វាអាចបង្កដោយបុគ្គល ឬក្រុម។ |
| **មិនយកចិត្តទុកដាក់** | ការមិនយកចិត្តទុកដាក់រួមមានការបន្តខកខានមិនបំពេញតម្រូវការជាមូលដ្ឋានខាងរាងកាយឬផ្លូវចិត្តរបស់កុមារ។ កុមារមិនបានទទួលកិច្ចការពារពីគ្រោះថ្នាក់នានា ឬមិនទទួលបានសេវាសុខភាព សំបុត្រកំណើតឬសេវាដទៃទៀត ទោះបីអ្នកទទួលខុសត្រូវថែទាំកុមារមានមធ្យោបាយ ចំណេះដឹង និងលទ្ធភាពដើម្បីទទួលបានសេវា ដើម្បីបំពេញតម្រូវការរបស់កុមារក៏ដោយ។ ការមិនយកចិត្តទុកដាក់ អាចកើតមានឡើង នៅក្នុងកំឡុងពេលមានផ្ទៃពោះដោយសារម្តាយសេពគ្រឿងហាមឃាត់។ |

**អំពើហិង្សាខាងផ្លូវភេទ**

**អំពើហិង្សាខាងផ្លូវភេទរួមមាន៖**

- **ការបៀតបៀនខាងផ្លូវភេទ៖**
  - **ការធ្វើឱ្យមានអារម្មណ៍ស្រើបស្រាលមិនតាមចំណង់៖** ការបង្កើតអារម្មណ៍ស្រើបស្រាលចំពោះកុមារ ដូចជាការថើបបែបផ្លូវភេទ ការស្ទាបអង្អែលប្រដាប់ភេទ ឬកន្លែងឯកជនរបស់កុមារក្នុងគោលបំណងរួមភេទ ឬឱ្យកុមារស្ទាបអង្អែលប្រដាប់ភេទនរណាម្នាក់ ឬលេងល្បែងផ្លូវភេទដោយគ្មានការអនុញ្ញាតពីកុមារនោះ។
  - **ការប៉ុនប៉ងរួមភេទមិនតាមចំណង់៖** មានបំណងបង្ខំកុមារឱ្យរួមភេទតាមទម្រង់ណាមួយប៉ុន្តែពុំបានសម្រេច។
  - **ការបង្ខិតបង្ខំលើរាងកាយដើម្បីរួមភេទ៖** ការបង្ខំលើរូបរាងកាយកុមារឱ្យរួមភេទតាមរបៀបណាមួយទោះបីជនរងគ្រោះតបតមកវិញក៏ដោយ
  - **ការដាក់សម្ពាធឱ្យរួមភេទ៖** ការមិនប្រើកម្លាំងកាយក្នុងបំណងរួមភេទតាមរបៀបណាមួយនៅពេលពួកគេពុំចង់រួមភេទហើយការរួមភេទត្រូវបានកើតឡើង។ ពេលនរណាម្នាក់ដាក់សម្ពាធលើកុមារឱ្យរួមភេទ វាអាចរួមមានដូចជា ការគំរាមកំហែង ការបៀតបៀន និងការទាក់ទាញទឹកចិត្ត ឬបោកបញ្ឆោតឱ្យរួមភេទ។
- **ការកេងប្រវ័ញ្ចផ្លូវភេទ៖** ការផ្ដល់ប្រាក់កាស អាហារ អំណោយ ឬភាពលំអៀងចំពោះអ្នកណាម្នាក់ ជាថ្នូរនឹងការរួមភេទ ឬការធ្វើសកម្មភាពផ្លូវភេទតាមទម្រង់ណាមួយផ្សេងទៀត។
- **អំពើហិង្សាផ្លូវភេទដោយគ្មានការប៉ះពាល់រាងកាយ៖**
  - ភាសាផ្លូវភេទមិនសមរម្យ ឬការគំរាមកំហែងដោយផ្ទាល់លើកុមារ (តាមពាក្យសំដី ឬការសរសេរ)
  - បង្ហាញប្រដាប់ភេទរបស់មនុស្សពេញវ័យទៅកុមារដើម្បីបង្ហាញភាពស្រើបស្រាល និងចំណង់ចំណូលចិត្តផ្លូវភេទរបស់មនុស្សពេញវ័យ
  - ការបង្ខំ ឬគំរាមកំហែងកុមារឱ្យបង្ហាញប្រដាប់ភេទ ឬតំបន់ឯកជនសម្រាប់ភាពស្រើបស្រាល និងចំណង់ចំណូលចិត្តផ្លូវភេទរបស់មនុស្សពេញវ័យ
  - បង្ខំឱ្យកុមារមើលរូប ឬវីដេអូអាសអាភាសដែលផ្ទុយពីឆន្ទៈរបស់ពួកគេ
  - បង្ខំឱ្យកុមារធ្វើជាសាក្សីលើការចាប់រំលោភ និង/ឬសកម្មភាពផ្សេងទៀតនៃអំពើហិង្សាផ្លូវភេទ

**ការកេងប្រវ័ញ្ច**

ការកេងប្រវ័ញ្ចខាងពាណិជ្ជកម្មឬការកេងប្រវ័ញ្ចផ្សេងទៀតលើកុមារសំដៅលើការប្រើប្រាស់កុមារនៅក្នុងការងារឬក្នុងសកម្មភាពដទៃទៀតដើម្បីជាប្រយោជន៍របស់អ្នកដទៃ។ ការកេងប្រវ័ញ្ចបែបនេះរាប់បញ្ចូលពលកម្មកុមារនិងពេស្យាចារកុមារ។ សកម្មភាពទាំងនេះធ្វើឱ្យខូចសុខភាពផ្លូវកាយនិងស្មារតីរបស់កុមារការអប់រំឬការវិវត្តខាងផ្លូវចិត្តសីលធម៌ ឬទំនាក់ទំនងចិត្តសង្គមរបស់កុមារ។ ការកេងប្រវ័ញ្ចលើកុមាររួមបញ្ចូលផងដែរការកេណ្ឌនិងប្រើប្រាស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធការជួញដូរកុមារនិងការលក់កុមារ។

ការកេងប្រវ័ញ្ចអាចពាក់ព័ន្ធនឹងការដាក់សម្ពាធមកលើកុមារឱ្យធ្វើការដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនរបស់គ្រូឬបុគ្គលិកដទៃទៀតនៅក្នុងសាលា។ វាក៏អាចពាក់ព័ន្ធផងដែរជាមួយការកេងចំណេញយកប្រាក់ពីកុមារដើម្បីបានចូលរៀនឬការដាក់ទណ្ឌកម្មចំពោះអាកប្បកិរិយាមិនគប្បីផងដែរ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| **ពលកម្មលើកុមារ** | ជាញឹកញាប់ ពលកម្មលើកុមារត្រូវបានឱ្យនិយមន័យថាជាការងារដែលដកហូតកុមារភាព សក្តានុពល និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ហើយបង្កគ្រោះថ្នាក់ដល់ការលូតលាស់រាងកាយ និងស្មារតី។ ពលកម្មលើកុមារកើតមាននៅពេលកុមារបំពេញការងារក្នុងវ័យក្មេងខ្លាំងតាមបទដ្ឋានស្របច្បាប់ដែលកំណត់ដោយប្រទេសរបស់ពួកគេ ឬនៅពេលពួកប្រទូកនឹងការងារគ្រោះថ្នាក់។ ការងារគ្រោះថ្នាក់គឺជាការងារទាំងឡាយណាដែលបង្កការប៉ះពាល់ដល់ការលូតលាស់ផ្នែករាងកាយ សង្គម ចិត្តសាស្ត្រ ឬការអប់រំរបស់កុមារ។ ក្នុងទម្រង់មួយធ្ងន់ធ្ងរ ពលកម្មលើកុមារគឺការជិះជាន់លើកុមារ ការបំបែកពួកគេចេញពីគ្រួសារ ការឱ្យពួកគេប្រឈមទៅនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរ និងជំងឺ និង/ឬការបំបោះបង់ពួកគេចោលនៅតាមផ្លូវ។ សន្និបាតលើកទី ១៣៨ របស់អង្គការ ILO ចែងថាកុមារអាយុទាបបំផុតដែលស្របច្បាប់សម្រាប់បម្រើការងារបានគឺអាយុ ១៥ ឆ្នាំ[១]។ |

សូមយោងផងដែរទៅឯកសារណែនាំស្តីពីសាលាកុមារមេត្រីជំពូក៤ ( ទិដ្ឋភាពទី ៣ ) ស្តីពីសុខភាពកុមារ សុវត្ថិភាព និងកិច្ចការពារៈ ការទប់ស្កាត់អំពើហិង្សាប្រឆាំងនឹងកុមារ ជំពូកទី៤។

## ១.២ ជំនឿខុសឆ្គងលើទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតី

ក្នុងពេលដែលយើងទាំងអស់គ្នាផ្តន្ទាទោសអំពើហិង្សាជាទូទៅគឺគេនៅខ្វះការយកចិត្តទុកដាក់ចំពោះអំពើហិង្សាមកលើកុមារ។ ហេតុអ្វី? ប្រពៃណីនិងជំនឿជាយូរលង់មកហើយអំពីទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីនៅតែមានហើយនៅបន្តប្រើប្រាស់ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីនៅក្នុងសង្គមជាច្រើន។ កុមារមិនសូវបានការពារខ្លួនទល់នឹងសកម្មភាពហិង្សាជាងមនុស្សពេញវ័យឡើយ។

**ប្រអប់សកម្មភាព - ជំនឿតាមបែបវប្បធម៌អំពីទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតី - *តើអ្នកគិតយ៉ាងណាដែរ?***

តើអ្នកឯកភាពឬមិនឯកភាពជាមួយប្រយោគដូចមានខាងក្រោមនេះ? សូមគូសយកប្រអប់ដែលត្រូវគ្នានឹងគំនិតរបស់អ្នក។

| | ការពណ៌នា | ឯកភាព | មិនឯកភាព |
|---|---|---|---|
| ១ | "ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីបានកើតមានចំពោះរូបខ្ញុំកាលខ្ញុំនៅពីក្មេងនិងមិនបង្កអន្តរាយចំពោះខ្ញុំឡើយ។" | ☐ | ☐ |
| ២ | "គ្មានវិធីផ្សេងដែលមានប្រសិទ្ធភាពឡើយ!" ឬ "ពួកគេសមនឹងទទួលទណ្ឌកម្មនេះ!" | ☐ | ☐ |
| ៣ | "ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីគឺជាការចាំបាច់ដើម្បីអប់រំកុមារ។បើគ្មានទណ្ឌកម្មបែបនេះទេកុមារនឹងមានអារម្មណ៍ទម្រើសនិងគ្មានវិន័យ។" | ☐ | ☐ |
| ៤ | "ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីគឺជាការបង្រៀនឱ្យស្តាប់ឱវាទ" | ☐ | ☐ |
| ៥ | "នៅពេលដែលក្មេងស្រីម្នាក់ប្រែជាក្លាហានពេកក្នុងថ្នាក់ នាងគួរតែត្រូវបានគ្រប់គ្រងដោយមិនត្រូវនិយាយស្តីលឺ។ " | ☐ | ☐ |
| ៦ | "ក្មេងប្រុសមើលទៅរឹងប៉ឹង និងមានកាយសម្បទារឹងមាំ ដូច្នេះការដាក់ទណ្ឌកម្មលើរាងកាយរបស់ពួកគេគឺមិនអីទេ។" | ☐ | ☐ |

១ អនុសញ្ញា ILO លេខ ១៣៨ ស្តីពីអាយុអប្បបរមា សម្រាប់ទទួលឱ្យធ្វើការងារ អនុម័ត ក្នុងឆ្នាំ ១៩៧៣ និងចូលជាធរមាន ក្នុងឆ្នាំ ១៩៧៦។

| | | | |
|---|---|---|---|
| ៧ | "ខ្ញុំអនុវត្តវាជាជម្រើសចុងក្រោយប៉ុណ្ណោះព្រោះខ្ញុំគ្មានជម្រើសផ្សេងទៀយ។" | ☐ | ☐ |
| ៨ | វាជាវិធីតែមួយដែលអាចឱ្យខ្ញុំគ្រប់គ្រងថ្នាក់រៀនដែលមានសិស្សច្រើនបាន។ | ☐ | ☐ |
| ៩ | "ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីគឺជាផ្នែកមួយនៃប្រពៃណីរបស់យើង។" | | |

ក្រោយគូសរួចសូមរាប់ចំនួនប្រយោគដែលអ្នកឯកភាព។

តើអ្នកមានចំណុច"ឯកភាព"ចំនួនប៉ុន្មានដង?

## មានចំនួនឯកភាពសូន្យ (0)៖

អ្នកទំនងជាមនុស្សដែលធ្វើការនៅក្នុងមជ្ឈដ្ឋានមួយដែលមិនគាំទ្រទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតីឡើយ។ ប្រពៃណីរបស់អ្នកហាមឃាត់ការដាក់ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីកុមារី និងកុមារី តែត្រូវបានជំនួសដោយការដាក់វិន័យបែបវិជ្ជមាន។ អ្នកប្រហែលជាមនុស្សដែលបានធំដឹងក្តីនៅក្នុងបន្ទុកឪពុកម្តាយនិងគ្រូបង្រៀនដែលតែងលើកសរសើរនិងលើកទឹកចិត្តអ្នកនិងមិនបន្តសកម្មភាពហិង្សាលើរូបអ្នកឡើយ។

## មានចំនួនឯកភាពពី១ដល់៣៖

អ្នកទំនងជាមនុស្សដែលរស់នៅក្នុងមជ្ឈដ្ឋានមួយដែលមនុស្សទាំងឡាយដែលតែងតែសួរថាតើទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតីគឺជាវិធីសមស្របមួយសម្រាប់ដាក់វិន័យលើកុមារដែរឬទេ។ អ្នកប្រហែលជាបានរស់នៅក្នុងប្រពៃណីមួយដែលក្នុងនោះទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីត្រូវបានហាមឃាត់ដោយច្បាប់។ អ្នកអាចស្គាល់អ្នកដទៃដែលបានប្រើប្រាស់វិន័យបែបវិជ្ជមានរួចមកហើយឬរូបអ្នកខ្លួនឯងបានចាប់ផ្តើមកែប្រែគំនិតនិងប្រើប្រាស់វិន័យបែបវិជ្ជមាន។ សហការីឬមិត្តភក្តិខ្លះអាចនៅតែជឿថាទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីនៅតែត្រូវការចាំបាច់ជាវិធីចុងក្រោយដើម្បីអប់រំកុមារី និងកុមារា។ រូបអ្នកហ៊ុមព័ទ្ធដោយប្រពៃណីដែលក្នុងនោះទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីនៅពុំទាន់ហាមឃាត់ទាំងស្រុងនៅឡើយទេ។

## មានចំនួនឯកភាពពី៤ដល់៧៖

នៅក្នុងមជ្ឈដ្ឋានរបស់អ្នកទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីត្រូវបានមនុស្សទាំងឡាយទទួលយក និងប្រើប្រាស់។ ច្បាប់អាចហាមឃាត់ទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតី ប៉ុន្តែទម្លាប់នៃការដាក់ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីនៅតែមានលើសលប់លើទម្លាប់នៃការដាក់វិន័យបែបវិជ្ជមាន។ គេអាចមើលឃើញថាវិន័យបែបវិជ្ជមានគឺជាវិធីដែលគ្មានប្រយោជន៍។ អ្នកប្រហែលជាមនុស្សដែលបានធំដឹងក្តីក្នុងបន្ទុកឪពុកម្តាយនិងគ្រូបង្រៀនដែលធ្លាប់តែវាយដំឬគំរាមកំហែងរូបអ្នក។ ឪពុកម្តាយនិងគ្រូបង្រៀនរបស់អ្នកប្រហែលជាពុំធ្លាប់លើកសរសើរឬលើកទឹកចិត្តអ្នកញឹកញាប់ទេ។ ក្មេងប្រុសហាក់ដូចជាឆ្លងកាត់អំពើហិង្សាផ្នែកខាងផ្លូវកាយ ខណៈឯក្មេងស្រីអាចនឹងឆ្លងកាត់អំពើហិង្សាខាងផ្លូវចិត្ត។ ត្រូវការឱ្យមានការកែប្រែអាកប្បកិរិយាដើម្បីជួយបំបែកទម្លាប់នៃអំពើហិង្សា។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ប្រយោគទាំងអស់ខាងក្រោមគឺជាជំនឿខុសឆ្គងដែលតំណាងឱ្យប្រពៃណីយូរអង្វែងនិងជំនឿដែលនាំឱ្យទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតីត្រូវបានប្រើប្រាស់ជាប្រចាំ។ ជំនឿខុសឆ្គងទូទៅខ្លះៗគឺ៖

## ជំនឿខុសឆ្គងទី ១៖

### "ទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតីបានកើតមានចំពោះរូបខ្ញុំ កាលពីក្មេងតែពុំបង្កអន្តរាយចំពោះខ្ញុំឡើយ។[២]"

ទោះជាយ៉ាងណាក៏ដោយពួកគេអាចមានអារម្មណ៍ភ័យខ្លាចខឹងនិងលែងទុកចិត្តដោយសារតែត្រូវឪពុកម្ដាយឬគ្រូបង្រៀនវាយពួកគេដែលជាកុមារ។ មនុស្សដែលប្រើប្រាស់អំណះអំណាងនេះច្រើនតែធ្វើបែបនេះដើម្បីកាត់បន្ថយអារម្មណ៍អំពីការប្រព្រឹត្តខុសរបស់ខ្លួនដោយសារការដាក់ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីដែលបានធ្វើឡើងបច្ចុប្បន្ននេះ។ នៅក្នុងអារម្មណ៍របស់ពួកគេពួកគេតែងតែការពារអំពើហិង្សារបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ អំពើរបស់ពួកគេបានបង្ហាញឱ្យឃើញថាទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីពិតជាបានបង្កទុក្ខទោសចំពោះពួកគេ៖ វាជម្រុញឱ្យមានវដ្ដនៃអំពើហិង្សាដែលឥឡូវនេះបង្កជារបួសស្នាមលើកុមារ។ ដូចគ្នានេះផងដែរកុមារទាំងនេះទំនងជានឹងបន្តប្រើប្រាស់អំពើហិង្សានេះជាច្រើនជំនាន់តទៀតទៅអនាគត។ ទម្លាប់អនុវត្តជាច្រើនដែលមនុស្សជំនាន់មុនបានឆ្លងកាត់កន្លងមកឥឡូវនេះលែងនៅជាទម្លាប់ទូទៅទៀតហើយ។

ជាក់ស្ដែងមនុស្សជាច្រើនដែលកាលពីក្មេងអាចពុំបានទទួលថ្នាំបង្ការពុំមានន័យថាឥឡូវនេះពួកគេចង់បន្តការមិនទទួលថ្នាំបង្ការសម្រាប់កូនរបស់ខ្លួននោះឡើយ។ មានភស្តុតាងជាច្រើនដែលបង្ហាញថាកុមារដែលធ្លាប់រងការបៀតបៀនពុំសម្រេចជោគជ័យបានពេញលេញនៅក្នុងជីវិតរបស់ខ្លួនឡើយចំណែកកុមារដែលពុំធ្លាប់រងការបៀតបៀនបែបនេះទំនងជាបានដឹកនាំខ្សែជីវិតដែលផ្ដល់សក្ដានុពលខ្ពស់នៅពេលពួកគេបានក្លាយជាមនុស្សធំ។ ទោះជាយ៉ាងណាក៏ដោយជាសំណាងអាក្រក់ឪពុកម្ដាយនិងគ្រូបង្រៀនច្រើនតែវាយកូនឬសិស្សដោយសារតែកំហឹងនិងដើម្បីរំសាយកំហឹងក៏ព្រោះតែពួកគេគ្មានចំណេះដឹងអំពីវិធីជំនួស។

## ជំនឿខុសឆ្គងទី ២៖

### "គ្មានវិធីផ្សេងដែលមានប្រសិទ្ធភាពឡើយ!" ឬ "ពួកគេសមនឹងទទួលទណ្ឌកម្មនេះ!"

ការលើកហេតុផលថាសិស្សចង់ឱ្យមានហិង្សាគឺជាវិធីដែលមានបំណងធ្វើឱ្យអ្នកប្រព្រឹត្តកាត់បន្ថយអារម្មណ៍ថាបានប្រព្រឹត្តខុស។ ប្រសិនបើយើងធ្លាប់តែបានស្ដីបន្ទោសស្រែកគំរាមកំហែងបំភិតបំភ័យឬដាក់ទណ្ឌកម្មលើរាងកាយសិស្សរបស់យើងអស់រយៈពេលជាយូរមកហើយនោះការកសាងទំនាក់ទំនងជឿទុកចិត្តគ្នាឱ្យមានប្រសិទ្ធភាពនៅក្នុងរយៈពេលខ្លីពិតជាលំបាកធ្វើឱ្យកើតឡើងណាស់។ ក្រៅពីនេះជាធម្មតាតើរូបអ្នកវាយចៅហ្វាយនាយនិយោជិតសហព័ទ្ធឬមិត្តល្អរបស់អ្នកឬទេនៅពេលដែល" គ្មានវិធីផ្សេងណាមួយដែលមានប្រសិទ្ធភាព"? សង្ឃឹមថាមិនមានបែបនេះទេ!

២ រឿងនិទាន១ដល់៧ត្រូវបានដកស្រង់ចេញពីUNESCO Bangkok, 2006, p. 16-19

## ជំនឿខុសឆ្គងទី ៣៖

### "ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីគឺជាការចាំបាច់ដើម្បីអប់រំកុមារ។ បើគ្មានទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីទេកុមារនឹងមានអារម្មណ៍ទម្រើសនិងគ្មានវិន័យ។"

កុមារត្រូវមានវិន័យ។ ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីគឺជាគំរូដែលគ្មានប្រសិទ្ធភាពមួយនៃការដាក់វិន័យ។ ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីទំនងជាផ្តល់ផលតែនៅពេលអ្នកសង្កេតមើលសើៗនិងនៅក្នុងរយៈពេលខ្លីប៉ុណ្ណោះ។ ប្រការដែលគ្រូនិងអ្នកដទៃទៀតច្រើនតែប្រើទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីម្តងហើយម្តងទៀតចំពោះអាកប្បកិរិយាដដែលពីសំណាក់កុមារដដែលបង្ហាញពីកង្វះប្រសិទ្ធភាពនៃវិធីនេះ។ ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីជាការបង្រៀនសិស្សអំពីអ្វីដែលអ្នកនិយាយប៉ុន្តែអាចកើតឡើងបានតែនៅពេលរូបអ្នកមានវត្តមាននៅទីនោះប៉ុណ្ណោះ។ ការធ្វើឱ្យកុមារបាត់បង់ទំនុកចិត្តនិងអសន្តិសុខវាជាការបំផ្លាញទំនាក់ទំនងរវាងគ្រូនិងសិស្ស។ កុមារហាក់ដូចជាមានអារម្មណ៍ខឹងនៅពេលអ្នកណាម្នាក់ដែលគួរតែបង្រៀននិងថែរក្សាពួកគេបែរជាគំរាមកំហែងវាយដំឬប្រមាថពួកគេទៅវិញ។ ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីអាចធ្វើឱ្យកុមារខ្លាចគ្រូជាងគោរពគ្រូ។តើយើងពិតជាចង់ឱ្យកុមាររៀន"គោរព"ចំពោះមនុស្សដែលប្រើប្រាស់ហិង្សាដើម្បីដោះស្រាយបញ្ហានិងទំនាស់ឬយ៉ាងណា?

**ជំនឿខុសឆ្គងទី៤ និងទី៥៖ "ក្មេងប្រុសមើលទៅរឹងប៉ឹង និងមានកាយសម្បទារឹងមាំ ដូច្នេះការដាក់ទណ្ឌកម្មលើរាងកាយរបស់ពួកគេ គឺមិនអីទេ។ និង "នៅពេលដែលក្មេងស្រីម្នាក់ប្រែជាក្លាហានពេកក្នុងថ្នាក់ នាងគួរតែត្រូវបានគ្រប់គ្រងដោយមិនត្រូវនិយាយស្តីលឺៗ"** ! ជំនឿលើវប្បធម៌ និងយេនឌ័រ បានលើកឡើងថា ក្មេងប្រុសគួរតែរឹងមាំ និងមានប្រៀបជាង ខណៈពេលដែលក្មេងស្រីគួរតែមានភាពទន់ភ្លន់ និងស្តាប់បង្គាប់។ ប្រសិនបើយើងស្តាប់ជំនឿទាំងនេះ យើងនឹងចាត់ទុកចំពោះក្មេងប្រុស និងក្មេងស្រីតាមរបៀបខុសគ្នា រួមមានរបៀបដែលដាក់វិន័យ និងទណ្ឌកម្មទៅលើពួកគេ និងសកម្មភាពអ្វីខ្លះដែលជារង្វាន់លើកទឹកចិត្តពួកគេ។ កុមាររៀនយកតម្រាប់តាមអាកប្បកិរិយាដែលពួកគេឃើញមនុស្សពេញវ័យប្រព្រឹត្ត រួមទាំងគ្រូបង្រៀនរបស់ពួកគេផងដែរ។ ប្រសិនបើក្មេងប្រុស និងក្មេងស្រី ឆ្លងកាត់បទពិសោធន៍អំពើហិង្សានៅក្នុងកុមារភាព នោះវាជារបួសមួយសម្រាប់ពួកគេ និងកាត់បន្ថយសមត្ថភាពរបស់ពួកក្នុងការរៀន។ ពួកគេក៏អាចនឹងប្រព្រឹត្តសារជាថ្មីនូវអាកប្បកិរិយានោះនៅក្នុងភាពពេញវ័យ ឬនឹងស្វែងរកដៃគូដែលប្រើអំពើហិង្សា។ គ្រូបង្រៀនក៏មានការទទួលខុសត្រូវដើម្បីការពារក្មេងប្រុស និងក្មេងស្រីពីអំពើហិង្សាផងដែរ។

## ជំនឿខុសឆ្គងទី ៤៖

### "ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីគឺជាការបង្រៀនឱ្យស្តាប់ឱវាទ"

កាលពីអតីតកាលការបង្រៀនសិស្សមិនឱ្យដេញដោលអំពីសមត្ថកិច្ចអាចជាទម្លាប់មួយប៉ុន្តែពេលវេលាបានកែប្រែអស់ទៅហើយ។ គ្រូជាច្រើនកំពុងទទួលយកបច្ចេកទេសរៀនសូត្រដែលផ្តោតលើកុមារដែលលើកទឹកចិត្តកុមារី និងកុមារាឱ្យស្វែងយល់គិតដោយខ្លួនឯងលើកសំណួរនិងមានសេចក្តីរីករាយក្នុងការរកឃើញចម្លើយ។ បច្ចេកទេសបែបនេះរួមចំណែកយ៉ាងច្រើនទៅក្នុងការអប់រំប្រកបដោយគុណភាព។ ទោះជាយ៉ាងណាក៏ដោយទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីរារាំងសិស្សមិនឱ្យលើកសំណួរមិនឱ្យគិតស៊ីជម្រៅនិងមិនឱ្យសម្រេចគោលដៅផ្ទាល់ខ្លួនបានឡើយ។ ទណ្ឌកម្មលើរាងកាយបញ្ឈប់សិស្សពីការរៀនសូត្រ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ជំនឿខុសឆ្គងទី ៥៖

### “ខ្ញុំអនុវត្តវាជាវិធីចុងក្រោយប៉ុណ្ណោះព្រោះខ្ញុំគ្មានជម្រើសផ្សេងឡើយ។”

ការដោះសារនេះជាការផ្តល់ហេតុផលសម្រាប់យើងនិងបង្រៀនសិស្សរបស់យើងថាការប្រើប្រាស់ហិង្សាត្រូវបានចាត់ជាហេតុផលនៃវិធីចុងក្រោយ។ គេមិនអាចទទួលយកអំណះអំណាងនេះបានឡើយ។ ឧទាហរណ៍តើប្តីអាចចាត់ទុកការវាយប្រពន្ធខ្លួនថាជាវិធីចុងក្រោយឬទេ? ករណីនេះរឹតតែលែងទទួលយកបាននៅពេលពាក់ព័ន្ធជាមួយកុមារី និងកុមារា។ ប្រសិនបើគេចាត់ទុកទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីថាជា “វិធីចុងក្រោយ” វាអាចធ្វើឱ្យសិស្សចាត់ទុកការដាក់វិន័យបែបវិជ្ជមាននានាដទៃទៀតលែងមានសារសំខាន់ដូច្នេះធ្វើឱ្យវិធីទាំងនោះគ្មានប្រសិទ្ធភាព។ ក្រៅពីនេះជាទូទៅឪពុកម្តាយនិងគ្រូបង្រៀនច្រើនតែប្រកាន់យកទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីតាំងពីដើមដំបូងតែមិនមែនជាវិធីចុងក្រោយឡើយនិងបានប្រើប្រាស់ចំពោះករណីនៃកំហុសឆ្គងតូចតាចបំផុតថែមទៀតផង។

## ជំនឿខុសឆ្គងទី ៦៖

### “វាជាវិធីតែមួយដែលអាចឱ្យខ្ញុំគ្រប់គ្រងថ្នាក់រៀនដែលមានសិស្សច្រើនបាន”

ការដោះសារនេះគឺជាករណីទូទៅក្នុងចំណោមគ្រូដែលបង្រៀនសិស្សច្រើន។ តាមធម្មតាវាកើតឡើងដោយសារតែការលំបាកក្នុងការរក្សាបទបញ្ជាផ្ទៃក្នុងថ្នាក់រៀនឬទម្លាប់តាមការនិយម។ កុមារី និងកុមារាពុំដឹងថាមានអ្វីខ្លះដែលជាការរំពឹងទុកអំពីពួកគេនិងផលវិបាកនៃការប្រព្រឹត្តខុសឆ្គងរបស់ពួកគេឡើយ។ ចំណែកគ្រូអាចពុំមានពេលគ្រប់គ្រាន់ដើម្បីបង្កើតទំនាក់ទំនងវិជ្ជមានជាមួយសិស្សដើម្បីសម្រួលឱ្យមានវិន័យបែបវិជ្ជមានឡើយ។ ប្រការនេះអាចកើតឡើងដោយសារតែរបៀបរបស់គ្រូក្នុងការគ្រប់គ្រងសិស្សក្នុងថ្នាក់រៀនតាមវិធីនៃការបញ្ជាដោយពោលថា “ខ្ញុំជាគ្រូហើយយើងនឹងធ្វើតាមរបៀបរបស់ខ្ញុំ!។ នៅក្នុងការព្យាយាមរក្សាអំណាចត្រួតត្រាគ្រូ ក៏អាចប្រើទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីផងដែរដោយមិនត្រឹមតែបញ្ឈប់ការប្រព្រឹត្តលើសិស្សតែម្នាក់នោះឡើយប៉ុន្តែបង្កជាការភ័យខ្លាចនៅក្នុងចិត្តរបស់សិស្សដទៃផងដែរដោយសង្ឃឹមថាសិស្សទាំងនោះមិនប្រព្រឹត្តមិនគប្បីផងដែរ។ ដូចក្នុងជំនឿខុសឆ្គងទី៤ខាងលើផងដែរការពង្រឹងការស្តាប់បង្គាប់ដោយងងឹតងងល់តាមរយៈការគំរាមកំហែងប្រើហិង្សាលើរាងកាយពុំលើកទឹកចិត្តដល់កុមារឱ្យរៀនពីគ្រូឡើយប៉ុន្តែបានត្រឹមតែខ្លាចគ្រូប៉ុណ្ណោះ។ ជាលទ្ធផលពួកគេមិនចង់រៀនដែលធ្វើឱ្យការបង្រៀនកាន់តែលំបាកហើយសិស្សពុំរៀនសូត្របានល្អដែលឆ្លុះបញ្ចាំងអំពីគុណភាពនៃការបង្រៀនរបស់គ្រូ។

## ជំនឿខុសឆ្គងទី ៧៖

### “ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីគឺជាផ្នែកមួយនៃប្រពៃណីរបស់យើង។”

ហេតុការណ៍៖ ជួនកាលទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីត្រូវបានការពារជាផ្នែកមួយនៃការធំដឹងក្តីនៅក្នុងសង្គមមួយ។ គំនិតនៃការជម្រុញជម្រើសផ្សេងសម្រាប់ជំនួសទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីអាចត្រូវបានគេមើលឃើញថាជាការបង្ខំឱ្យទទួលយក”របៀបរបបពីលោកខាងលិច” ដោយពុំពិចារណាគុណតម្លៃអាស៊ី។ សង្គមនៅអាស៊ីពឹងផ្អែកលើឋានុក្រមសង្គម

ដែលទាក់ទងជាមួយវ័យនិងគំនិតដែលថា ក្មេងត្រូវគោរពបម្រើនិងស្ដាប់បង្គាប់មនុស្សចាស់ដែលរួមទាំងគ្រូបង្រៀនផងដែរ។ ទោះបីទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតីកើតមានជាទូទៅនៅអាស៊ីក៏ដោយទំនាក់ទំនងរវាងប្រព័ន្ធជំនឿតាមប្រពៃណីនិងអំពើហិង្សាលើកុមារពុំសុទ្ធតែកើតមានតាមរយៈទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីនោះឡើយ។ ផ្ទុយទៅវិញគុណតម្លៃស្នូលចំនួនពីររបស់សង្គមនៅអាស៊ីគឺ៖ ការរក្សាភាពចុះសម្រុងគ្នាក្នុងសង្គមនិងការរៀនប្រើប្រាស់សមត្ថភាពខាងគំនិតដើម្បីគ្រប់គ្រងរាងកាយជាពិសេសទាក់ទងនឹងការគ្រប់គ្រងខ្លួនឯងនៅក្នុងពេលមានអាសន្ន។ ហិង្សាតាមរយៈទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីគឺជាដំណើរផ្ទុយនឹងគុណតម្លៃស្នូលជាប្រពៃណីរបស់អាស៊ី។[៣] វាបំផ្លាញភាពចុះសម្រុងគ្នានៃសង្គមនៅក្នុងថ្នាក់រៀនពោលគឺទំនាក់ទំនងសិស្សនិងគ្រូ គ្រូនិងសិស្សនិងជាការគំរាមកំហែងចំពោះទំនាក់ទំនងដែលកុមារនឹងបង្កើតឡើងទៅអនាគត។ វាធ្វើឱ្យកុមារបាត់បង់ទំនុកចិត្តនិងការគោរពចំពោះខ្លួនឯងនិងទទួលស្គាល់ពីកង្វះការត្រួតត្រាលើខ្លួនឯងថាការគ្របសង្កត់លើអ្នកដទៃគឺជាវិធីដែលអាចទទួលយកបាន។ ជំនួសឱ្យទណ្ឌកម្មលើរាងកាយគេអាចប្រើប្រាស់វិន័យបែបប្រពៃណីដែលមិនរួមបញ្ចូលហិង្សាដូចជានៅពេលមនុស្សពេញវ័យផ្ដល់ជាគំរូពីការគោរពគ្នានិងអាកប្បកិរិយាអហិង្សាដែលបន្ទាប់មកនឹងបានឆ្លុះបញ្ចាំងជាអាកប្បកិរិយារបស់កុមារ។ ប្រព័ន្ធជំនឿរបស់បុគ្គលនិងប្រពៃណីដែលពង្រឹងការប្រើប្រាស់ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីក៏អាចកែប្រែបាននៅក្នុងរយៈពេលមួយដ៏ខ្លីផងដែរ។

## ១.៣ តើមានផលវិបាកអ្វីខ្លះ ?

ទម្លាប់នៃការដាក់វិន័យដោយអំពើហិង្សាលើរាងកាយនិងផ្លូវចិត្តសូម្បីត្រឹមតិចតួចក៏សុទ្ធតែបង្កអន្តរាយដល់កុមារ។

- **ផលវិបាកចំពោះរាងកាយ៖ “វាបង្កការឈឺចាប់លើរាងកាយរបស់ខ្ញុំ!”**[៤]
    - រាប់ចាប់ពីការឈឺចាប់ខាងរាងកាយស្នាមរបួសនិងជាំតិចតួចរហូតដល់របួសធ្ងន់ធ្ងរបណ្ដាលឱ្យមានពិការភាពឬរហូតដល់បាត់បង់ជីវិត។

**ត្រូវតែឃ្វាលគោជារៀងរាល់ព្រឹកមុនពេលទៅសាលារៀន ដូចនេះខ្ញុំតែងតែទៅរៀនយឺត។**



៣ សូមមើលឧទាហរណ៍ Gourley, 2009

៤ ផលវិបាកទាំងប្រាំនៃទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីនិងរូបត្លុកត្រូវបានដកស្រង់ចេញពី Raising Voices, The Good School toolkit, Cartoon Booklet, What is wrong with corporal punishment?



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ខ្ញុំតែងតែត្រូវបានអ្នកគ្រូវាយសម្រាប់ការមករៀនយឺត។ ថ្ងៃមួយខ្ញុំបានពួននៅគុម្ពោតរហូតដល់ពេលចេញទៅផ្ទះ។



អ្នកគ្រូចាប់បាននៅពេលដែលខ្ញុំពួន និងខឹងយ៉ាងខ្លាំង។ គាត់បានវាយខ្ញុំចំនួន ២០ដង។



គាត់បានវាយខ្ញុំយ៉ាងខ្លាំងរហូតដល់ឪពុកម្តាយរបស់ខ្ញុំត្រូវយកខ្ញុំទៅមន្ទីរពេទ្យ ហើយខ្ញុំខកខានមិនបានទៅរៀនដល់មួយសប្តាហ៍។ វាបង្កការឈឺចាប់លើរាងកាយរបស់ខ្ញុំ!



❖ **ផលវិបាកខាងផ្លូវចិត្ត៖** "វាធ្វើឱ្យខ្ញុំឈឺចិត្ត!"

- ផលវិបាកខាងផ្លូវចិត្តធ្វើឱ្យកុមារខឹងសម្បារលំបាកចិត្តនិងអាម៉ាស់មុខ។ នៅពេលកុមារត្រូវគេបង្អាប់ចំអកបន្ទាបបន្ថោកឬសម្លុតពួកគេអាចបាត់បង់ការគោរពចំពោះខ្លួនឯងនិងក្រៀមក្រំចិត្ត។ ពួកគេអាចគិតអំពីការធ្វើអត្តឃាតសងសឹកឬមានអាកប្បកិរិយាឃោរឃៅផងដែរ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews


បូផា! ឯងតែងតែកខ្វក់គ្រប់ពេល
វេលា! ហេតុអ្វីបានជាឯងមិនអាច
ដូចជាសិស្សដទៃទៀត
ក្មេងស្រីប៉ុន្តែ អ្នកគ្រូ ...







youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

❖ **ផលវិបាកចំពោះអាកប្បកិរិយា៖** "វាជម្រុញឱ្យខ្ញុំធ្វើអំពើមិនល្អ"

- វាជាការបង្រៀនកុមារថាហិង្សាគឺជាអាកប្បកិរិយាដែលទទួលយកបាន។ ប្រការនេះទំនងជាអាចឱ្យកុមារប្រកាន់យកអាកប្បកិរិយាគ្មានសណ្ដាប់ធ្នាប់និងឃោរឃៅដូចជាបំផ្លាញទ្រព្យសម្បត្តិសាលារៀនរករឿងឈ្លោះជាមួយសិស្សរួមថ្នាក់ឬនៅពេលក្លាយជាមនុស្សធំគាត់បន្ត អំពើហិង្សាបែបនេះក្នុងគ្រួសារ។















youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- **ផលវិបាកខាងទំនាក់ទំនង៖** *"វាធ្វើឱ្យខ្ញុំពិបាកជឿលើមនុស្សទាំងឡាយ"*
  - វាធ្វើឱ្យខូចទំនុកចិត្តរបស់ក្មេងចំពោះមនុស្សធំ។ ពួកគេអាចពិបាកបង្កើតទំនាក់ទំនងជាមួយគ្រូមនុស្សធំដទៃទៀតនិងសូម្បីជាមួយក្មេងដទៃ។









youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- **ផលវិបាកចំពោះស្មារតី៖** “វាធ្វើឱ្យខ្ញុំលំបាករៀន”
    - វារាំងខ្ទប់សមត្ថភាពរបស់ពួកគេក្នុងការរៀនសូត្រ។ កុមារមានអារម្មណ៍មិនហ៊ានសាកល្បងធ្វើរឿងថ្មីៗនិងមិនហ៊ានសួរឬឆ្លើយសំណួរ។ ពួកគេច្រើនតែមានអារម្មណ៍អាម៉ាស់និងខ្លាចការចំអក។ ពួកគេអាចខ្វះទឹកចិត្តក្នុងការរៀនសូត្រឱ្យបានពិន្ទុល្អហើយគុណភាពនៃការរៀនសូត្ររបស់ពួកគេអាចធ្លាក់ចុះ។ នៅដំណាក់កាលណាមួយវាអាចធ្វើឱ្យសិស្សគេចសាលានិងអាចនាំឱ្យសិស្សបោះបង់ចោលសាលារៀនតែម្តង។









youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews


ខ្ញុំពិតជាបានរៀនរួចហើយ!
ខ្ញុំត្រៀមខ្លួនរួចរាល់ហើយ!


ភិរម្យ, តើអ្វីជាចម្លើយ?
? ? ?







youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**ការប្រើប្រាស់ហិង្សាដើម្បីដាក់វិន័យដល់កុមារគឺពិតជាការប្រើអំណាចដោយបំពាន។** សារមោះមុតបំផុតដែលតាមធម្មតាមិនមែនជាការចង់បានគឺថាគំរូនៃការដាក់វិន័យដោយហិង្សាលើកុមារធ្វើឱ្យកុមារយល់ថាហិង្សាគឺជាអាប្បកិរិយាដែលអាចទទួលយកបានពេលគឺការដែលបុគ្គលជាអ្នកខ្លាំងជាងប្រើប្រាស់អំណាចដើម្បីបង្ខិតបង្ខំមនុស្សគ្រប់រូបគឺជារឿងធម្មតា។ **តាមរយៈការប្រើហិង្សាយើងបង្រៀនអំពីការប្រើហិង្សា។**

**ឯកសារណែនាំនេះនឹងបង្ហាញអំពីវិធីផ្សេងៗទៀតនៃវិន័យអហិង្សាបែបវិជ្ជមាន**



## ១.៤ តើទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតី មានប្រសិទ្ធភាពឬទេ?

ទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតីនៅតែបន្ត ភាគច្រើនដោយសារគ្រូជឿថាវាមានប្រសិទ្ធភាព។ តើវាពិតជាមានប្រសិទ្ធភាពដែរឬទេ?

ប្រយោគទាំងនេះ[៥] អធិប្បាយអំពីអារម្មណ៍របស់សិស្សនៅកម្ពុជាប្រសិនបើពួកគេជួបប្រទះទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីនៅក្នុងសាលារៀន។

- "ខ្ញុំខឹងណាស់។ សិស្សខ្លះបានឈប់រៀនទៅហើយ"អន់ចិត្តភ័យខ្លាច"
- "មិនចង់រៀនចង់បោះបង់ចោលសាលារៀន"
- "ខឹងនិងចង់សងសឹក - នឹងប្រឹងរៀនដើម្បីក្លាយជាគ្រូបង្រៀនបន្ទាប់មកវាយកុមារដើម្បីជាការសងសឹក"

និងស្មារតីអាចបញ្ឈប់អាកប្បកិរិយាមិនសមរម្យមួយរយៈខ្លី។ គ្រូអាចគិតថាវិធីរបស់គាត់ក្នុងការដាក់វិន័យលើសិស្សពិតជាមានប្រសិទ្ធភាព។

ទោះជាយ៉ាងណាក៏ដោយវិធីទាំងនោះគ្មានប្រសិទ្ធភាពទេ។ ក្មេងច្រើនតែមិនចងចាំឬយល់ពីមូលហេតុដែលត្រូវវាយឬស្តីបន្ទោសឡើយ។

វាមិនជួយក្មេងឱ្យរៀនគោរពវិន័យ ដោយខ្លួនឯងឡើយ។

ដំណោះស្រាយ"ងាយ"នេះកម្របង្កើតលទ្ធផលតាមការចង់បាន ដែលនាំឱ្យសិស្សកែប្រែអាកប្បកិរិយាសម្រាប់រយៈពេលវែងឡើយ។ សូមមើលរូបត្លុក!

ហើយវាមិនបង្កើនការគោរពនៃពួកគេចំពោះគ្រូពួកគេឡើយ។




នៅពេលដែលគ្រូទៅវិញ



អាកប្បកិរិយាមិនគប្បីទាំងនោះក៏ត្រលប់មកដូចវិញ



៥ Ministry of Women's Affairs (2014). Findings from Cambodia's Violence Against Children Survey 2013. Steering committee on Violence Against Children. Secretariat: UNICEF Cambodia រូបត្លុកនេះត្រូវបានដកស្រង់ចេញពី Raising Voices, The Good School toolkit, Cartoon Booklet, What is wrong with corporal punishment


youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ១.៥ ការដាក់វិន័យបែបវិជ្ជមាននិងការគ្រប់គ្រងថ្នាក់រៀនដោយប្រសិទ្ធភាព

**វិន័យបែបវិជ្ជមាន**ណែនាំអំពីអាកប្បកិរិយាកុមារដោយផ្តោតលើការអភិវឌ្ឍជារួមរបស់កុមារ។ តាមរយៈការធ្វើជាគំរូការប្រៀនប្រដៅនិងការផ្តល់នូវការណែនាំច្បាស់លាស់អំពីអាកប្បកិរិយាដែលអាចទទួលយកបានវិន័យបែបវិជ្ជមានមានគោលដៅកសាងជំនាញនិងប្រព័ន្ធគុណតម្លៃរបស់កុមារដែលនឹងលើកទឹកចិត្តដល់ពួកគេឱ្យបង្កើតអាកប្បកិរិយាវិជ្ជមានការគោរពចំពោះខ្លួនឯងនិងមានចរិតរឹងមាំ។

ដើម្បីឱ្យវិធីសាស្រ្តវិន័យបែបវិជ្ជមានមានប្រសិទ្ធភាពគេត្រូវអនុវត្តវិធីនេះជាមួយគ្រប់សមាជិកទាំងអស់នៅក្នុងសាលារៀននិងនៅគ្រប់ពេលទាំងអស់ចាប់ពីអ្នកគ្រប់គ្រងសាលារៀនរហូតដល់គ្រូបង្រៀននិងបុគ្គលិកដទៃទៀតទាំងអស់។ **ត្រូវអនុវត្តវិធីសាស្រ្តនៃការដាក់វិន័យបែបវិជ្ជមាននៅទូទាំងសាលារៀន!**

**ការគ្រប់គ្រងថ្នាក់រៀនគឺជាផ្នែកមួយនៃវិន័យបែបវិជ្ជមាន។** គេគ្មានការគ្រប់គ្រងថ្នាក់រៀនដោយគ្មានវិន័យបែបវិជ្ជមាននោះឡើយ។ នៅពេលយើងប្រើពាក្យ "ការគ្រប់គ្រងថ្នាក់រៀន" យើងសំដៅលើនីតិវិធីយុទ្ធសាស្រ្តនិងវិធីណែនាំដែលគ្រូប្រើប្រាស់ដើម្បីបង្កើតបរិស្ថាននៃថ្នាក់រៀនដែលលើកកម្ពស់ការរៀនសូត្រក៏ដូចជាបង្កើតនិងគ្រប់គ្រងអាកប្បកិរិយា និងសកម្មភាពរៀនសូត្ររបស់សិស្សម្នាក់ៗនិងសិស្សទាំងអស់គ្នានៅក្នុងបរិស្ថាននេះផងដែរ។



## តើវិន័យបែបវិជ្ជមានជាអ្វី?[៦]

ចំពោះគ្រូជាច្រើនវិន័យមានន័យស្មើនឹងទណ្ឌកម្ម។ “ការដាក់វិន័យចំពោះកុមារ” ត្រូវបានបកស្រាយថាគឺជា “ការវាយកុមារ”។ ការយល់បែបនេះពុំត្រឹមត្រូវទេ។

វិន័យបែបវិជ្ជមាន គឺជាគោលវិធីក្នុងការអប់រំកុមារដោយគ្មានអំពើហិង្សា។ វិន័យបែបវិជ្ជមានគឺ គ្មានអំពើហិង្សា សិស្សមជ្ឈមណ្ឌល និងទទួលស្គាល់សិទ្ធិជាសាកលរបស់កុមារ។

**វិន័យវិជ្ជមានគោរពសិទ្ធិទាំងឡាយរបស់កុមារដូចខាងក្រោម[៧]៖**

- អប់រំកុមារដោយមិនប្រើអំពើហិង្សា (មាត្រា ១៩)
- ការពារកុមារពីអំពើហិង្សាគ្រប់ទម្រង់ទាំងអស់ (មាត្រា ១៩)
- អប់រំកុមារដោយគ្មានការរើសអើង (មាត្រា ២)
- គោរពភាពថ្លៃថ្នូរជាមនុស្សរបស់កុមារ (មាត្រា ២៨)
- គាំទ្រកុមារឱ្យអភិវឌ្ឍន៍បុគ្គលិកលក្ខណៈ ទេពកោសល្យ និងសមត្ថភាពផ្លូវចិត្ត និងផ្លូវកាយរបស់ពួកគេឱ្យដល់សក្តានុពលពេញលេញបំផុត (មាត្រា ២៩)
- គោរពមាតាបិតា និងសារតារប្បធម៌របស់កុមារ (មាត្រា ២៩)។

**នៅតាមសាលារៀន វិន័យបែបវិជ្ជមាន ពាក់ព័ន្ធនឹងការគាំទ្រឱ្យសិស្ស[៨]៖**

- រៀនដោយគ្មានការភ័យខ្លាច
- រៀនអ្វីដែលជាអាកប្បកិរិយាដែលអាចទទួលយកបាន
- រៀនធ្វើការសម្រេចចិត្តឱ្យបានល្អ និងទទួលខុសត្រូវ
- រៀនពីកំហុស

**វិន័យបែបវិជ្ជមាននៅតាមសាលារៀន គឺស្វ័យវិន័យរបស់គ្រូបង្រៀន។ ស្វ័យវិន័យមានផលវិជ្ជមានទៅលើការអភិវឌ្ឍរបស់សិស្ស។ សិស្សដែលមានស្វ័យវិន័យតែងតែ៖**

- មានគោលដៅច្បាស់លាស់
- ជឿជាក់លើខ្លួនឯង
- មានការជំរុញចិត្តខ្លួនឯង
- មានបំណងខិតខំសិក្សា
- ទុកចិត្តលើការវិនិច្ឆ័យរបស់ពួកគេ
- គិតអំពីមធ្យោបាយថ្មីក្នុងការដោះស្រាយបញ្ហាចាស់
- មានការតស៊ូ

youtube.com/moeyscambodia
sala.moeys.gov.kh
t.me/moeysnews

៦ រូបត្ថុកនេះត្រូវបានដកស្រង់ចេញពីRaising Voices, The Good School toolkit, Cartoon Booklet, What is wrong with corporal punishment

៧ ផ្នែករង "តើវិន័យបែបវិជ្ជមានគឺជាអ្វី" ត្រូវបានដកស្រង់ចេញពី Durrant, 2010, p. 11-15

៨ កថាខណ្ឌទាំងបីខាងក្រោម សង្ខេបអំពីលក្ខណៈពិសេសទាំងឡាយនៃវិន័យបែបវិជ្ជមាន ដូចមានពន្យល់នៅក្នុង Naker & Sekitoleko, 2009 ទំព័រ ២៧, ២៨&៣០។ សូមមើលផងដែរ UNESCO, 2006 ទំព័រ ២៩&៣០

## នៅពេលគ្រូបង្រៀនប្រើវិន័យបែបវិជ្ជមាន ពួកគេ៖

- ដើរតួនាទីជាអ្នកផ្ដល់ដំបូន្មាន និងជាអ្នកដឹកនាំសម្រាប់សិស្ស
- បង្កើតទំនាក់ទំនងបែបវិជ្ជមាន និងប្រកបដោយការគោរពជាមួយសិស្ស
- អប់រំកុមារទាំងមូល
- ជួយដល់សិស្សក្នុងការរៀនអំពីស្វ័យវិន័យ
- ផ្ដល់ការដឹកនាំ និងការណែនាំច្បាស់លាស់ដល់សិស្សអំពីអាកប្បកិរិយាដែលអាចទទួលយកបានពង្រឹងជាវិជ្ជមាន នូវជម្រើសល្អៗ និងផ្ដល់រង្វាន់ចំពោះអាកប្បកិរិយាល្អៗ
- ប្រើផលវិបាកគ្មានអំពើហិង្សាសម្រាប់រាល់ការប្រព្រឹត្តមិនសមរម្យ
- ផ្ដល់ឱកាសឱ្យសិស្សបានស្វែងយល់ និងកែកំហុសរបស់ពួកគេ
- ជួយដល់សិស្សក្នុងការរៀនធ្វើការសម្រេចចិត្តល្អៗ
- យកចិត្តទុកដាក់ទៅលើតម្រូវការផ្លូវចិត្ត និងផ្លូវកាយរបស់សិស្ស ព្រមទាំងដំណាក់កាលអភិវឌ្ឍន៍ និងកិច្ចការរបស់ពួកគេ។

## តើការគ្រប់គ្រងថ្នាក់រៀនដោយប្រសិទ្ធភាពជាអ្វី?

ការគ្រប់គ្រងថ្នាក់រៀនដោយប្រសិទ្ធភាពផ្អែកលើទំនាក់ទំនងវិជ្ជមានរវាងគ្រូនិងសិស្សទៅតាមបទបញ្ជាផ្ទៃក្នុងនៃវិន័យបែបវិជ្ជមាន និងការរួមបញ្ចូលចំណេះដឹងអំពីរបៀបដែលសិស្សរៀនសូត្រនិងមូលហេតុដែលសិស្សប្រព្រឹត្តមិនគប្បី (សូមមើលជំពូក ៥)។

## ការគ្រប់គ្រងថ្នាក់រៀនដោយប្រសិទ្ធភាពមានជាអាទិ៍៖

- ទំនាក់ទំនងវិជ្ជមានរវាងគ្រូនិងសិស្ស
- ការបង្រៀនតាមបែបច្នៃប្រឌិតនិងការធ្វើជាគំរូល្អ
- បទបញ្ជាផ្ទៃក្នុងថ្នាក់រៀន
- ពង្រឹងបន្ថែមនូវចំណុចវិជ្ជមាន
- ណែនាំសិស្សដោយប្រើប្រាស់វិធានការត្រឹមត្រូវនិងអហិង្សាជំនួសឱ្យទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតី

ចំណុចស្នូលនៃវិន័យបែបវិជ្ជមាននៅក្នុងថ្នាក់រៀនគឺការសង្កេតមើលសិស្សដែលប្រព្រឹត្តបានត្រឹមត្រូវ និងផ្ដល់ការលើកទឹកចិត្តដល់ពួកគេភ្លាមៗ។

ទម្លាប់នៃការរើសអើងយេនឌ័រ (លើក្មេងស្រី)




ទម្លាប់នៃការរើសអើងយេនឌ័រ (លើក្មេងប្រុស)




youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews



# ២

# ការបង្កើតទំនាក់ទំនងវិជ្ជមានរវាងគ្រូនិងសិស្ស

វិន័យប្រកបដោយភាពវិជ្ជមានក្នុងសាលាប៉ះពាល់ជាវិជ្ជមានដល់ទំនាក់ទំនងរវាងគ្រូ និងសិស្សរបៀបដែលគ្រូទំនាក់ទំនងជាមួយសិស្ស និងរបៀបដែលគ្រូបង្រៀនសិស្ស។

**គ្រូប្រើវិន័យប្រកបដោយភាពវិជ្ជមានៈ**

- បង្កើតទំនាក់ទំនងវិជ្ជមានរវាងគ្រូ និងសិស្ស
- បង្កើតបរិយាកាសសិក្សាដែលមានសុវត្ថិភាព និងវិជ្ជមាន

**ទំនាក់ទំនងវិជ្ជមានរវាងគ្រូ និងសិស្សជួយៈ**

- បង្ការមិនឱ្យមានបញ្ហាក្នុងថ្នាក់រៀន
- គ្រប់គ្រងអាកប្បកិរិយារបស់សិស្សទាំងរយៈពេលខ្លី និងរយៈពេលវែង
- លើកទឹកចិត្តឱ្យសិស្សខិតខំរៀនសូត្រ និងព្យាយាមប្រើសមត្ថភាពរបស់ពួកគេឱ្យអស់ពីលទ្ធភាព។

## ២.១ ការផ្តល់ភាពកក់ក្តៅនិងការណែនាំ[៩]

អ្នកប្រហែលជាបានដឹងប្រយោគខ្មែរមួយដែលពោលថា "យើងត្រូវការតែគ្រាប់ភ្នែកនិងឆ្អឹងសិស្សត្រឡប់មកវិញប៉ុណ្ណោះ"។

នៅពេលដែលគោលដៅរបស់យើងគឺចង់ឃើញកុមារទទួលជោគជ័យនៅក្នុងសាលារៀន និងក្នុងជីវិតយើងត្រូវតែកែប្រែប្រយោគមួយនេះទៅជា"កុមារត្រូវការភាពកក់ក្តៅនិងការណែនាំ"។

វិន័យបែបវិជ្ជមាននិងការគ្រប់គ្រងថ្នាក់រៀនទាក់ទងនឹងការផ្តល់ភាពកក់ក្តៅនិងការណែនាំ។

---

៩ អ្នកស្រាវជ្រាវ និងអ្នកជំនាញផ្នែកអប់រំនៅត្រង់ចំណុចនេះសំដៅទៅដល់ "របៀបបង្រៀនដែលមានលក្ខណៈគ្រប់គ្រង" សូមមើល Ertesvåg, 2011a, 2011b, 2009; Walker, 2009; Hughes, 2002; Pellerin, 2005។ របៀបបង្រៀនដែលមានលក្ខណៈគ្រប់គ្រងនេះរួមមានភាពកក់ក្តៅ និងការណែនាំ ( ការគ្រប់គ្រង ) និងត្រូវបានកែសម្រួលចេញពីការស្រាវជ្រាវលើរបៀបធ្វើជាអាណាព្យាបាលដោយ Baumrind, 1967, 1971, 1978, 1991 and Maccoby & Martin, 1983. See as well: Naker & Sokitoleko, 2009; UNESCO, 2006

| ការផ្តល់ភាពកក់ក្តៅរួមមាន៖ | ការផ្តល់ការណែនាំរួមមាន៖ |
| --- | --- |
| ការគោរព និងការទទួលសិស្ស | ការប្រាស្រ័យទាក់ទងលើការរំពឹងទុក |
| កសាងទំនាក់ទំនងវិជ្ជមានរវាងគ្រូ និងសិស្ស | ការបង្កើត និងការថែទាំទម្លាប់ក្នុងថ្នាក់ដើម្បីដោះស្រាយស្ថានភាពខុសៗគ្នា |
| ផ្តល់អំណាចលើការសម្រេចចិត្តរបស់សិស្ស | កំណត់បទដ្ឋានច្បាស់លាស់ និងដែនកំណត់ |
| បើកចិត្តឱ្យទូលាយចំពោះគំនិត និងបញ្ហារបស់សិស្ស | ការប្រាស្រ័យទាក់ទងផលលំបាកអហិង្សាសម្រាប់អាកប្បកិរិយាអវិជ្ជមាន |
| បង្ហាញចំណាប់អារម្មណ៍ដោយស្មោះត្រង់ចំពោះសិស្ស | តាមដានអាកប្បកិរិយារបស់សិស្ស |
| ការចាត់ទុកសិស្សស្រី និងប្រុសស្មើៗគ្នា | ផ្តល់ការអនុវត្តវិធានប្រកបដោយភាពស៊ីសង្វាក់គ្នា |
| | ធានាថាកុមារី និងកុមារាបង្ហាញការគោរព និងគាំទ្រគ្នាទៅវិញទៅមក |
| ត្រូវមានការឆ្លើយតប៖ ដើម្បីជួយពេលសិស្សមិនយល់ ឬមានបញ្ហា | ការផ្តល់ហេតុផល និងការពន្យល់ជាជាងការប្រើអំណាច |
| ការពារសុខមាលភាពរាងកាយ និងផ្លូវចិត្តរបស់សិស្ស | ប្រើការសន្ទនា និងការចូលរួមរបស់សិស្ស |
| ការពារសុខមាលភាពរាងកាយ លើកទឹកចិត្តកុមារី និងកុមារា និងផ្តល់លិខិតសរសើរដល់សិស្សដែលមានអាកប្បកិរិយាល្អស្មើៗគ្នា កាយ និងផ្លូវចិត្តរបស់សិស្ស | ផ្តល់រចនាសម្ព័ន្ធដល់សកម្មភាពរបស់សិស្ស |

**ប្រអប់សកម្មភាព - ការឆ្លុះបញ្ចាំងដោយខ្លួនឯង៖ ហេតុអ្វីការផ្តល់ភាពកក់ក្តៅមានសារសំខាន់**[១០]

ឧទាហរណ៍នៅក្នុងស្ថានភាពដូចតទៅ៖អ្នកកំពុងចាប់ផ្តើមរៀនភាសាថ្មីមួយៗ ឥឡូវចូរគិតអំពីសេណារីយ៉ូដូចតទៅ៖

**ក. តើអ្នកអាចរៀនបានច្រើនឬទេប្រសិនបើអ្នកមានអារម្មណ៍ថា៖**

(១) មានសុវត្ថិភាពជាមួយគ្រូរបស់អ្នកឬ

(២) ខ្លាចគាត់វាយប្រសិនបើអ្នកមានកំហុស?

**ខ. តើអ្នកអាចរៀនបានច្រើនឬទេប្រសិនបើអ្នកដឹងថា៖**

(១) គ្រូរបស់អ្នកនឹងបន្តគាំទ្រអ្នកទោះបីអ្នកមានកំហុសច្រើនប៉ុណ្ណាក៏ដោយឬ

(២) គាត់នឹងចេញពីបន្ទប់រៀនភ្លាមដោយកំហឹងនៅពេលអ្នកឆ្លើយខុស?

**គ. តើអ្នកចង់ធ្វើឱ្យគ្រូសប្បាយចិត្តឬទេចំពោះគ្រូដែល៖**

(១) មានទឹកចិត្តល្អនិងការយោគយល់គ្នាឬ

(២) ស្រែកសន្ធាប់បន្ទុះបង្អាប់និងទិតៀនរូបអ្នក?

**ឃ. តើអ្នកចង់ប្រាប់គ្រូរបស់អ្នកឬទេនៅពេលដែលអ្នកមានបញ្ហាប្រសិនបើអ្នករំពឹងថា៖**

(១) គាត់នៅតែស្តាប់និងជួយអ្នកឬ

(២) ខឹងនិងដាក់ទណ្ឌកម្មលើរូបអ្នក?

១០ សកម្មភាពដកស្រង់ចេញពី Durrant, 2010, ទំព័រ 71

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### ប្រអប់សកម្មភាព - ការឆ្លុះបញ្ចាំងដោយខ្លួនឯង៖ ហេតុអ្វីការផ្ដល់ភាពកក់ក្ដៅមានសារសំខាន់[១១]

ចូរយើងវិលត្រឡប់មករកសេណារីយ៉ូខាងលើអំពីការសិក្សាភាសាថ្មីមួយ។ សូមធ្វើការឆ្លុះបញ្ចាំងអំពីសេណារីយ៉ូនានាដូចតទៅ៖

**ក.តើអ្នកអាចរៀនសូត្របានច្រើនឬទេប្រសិនបើគ្រូរបស់អ្នក៖**

(១) បង្ហាញដល់អ្នកអំពីរបៀបសរសេរពាក្យថ្មីណាមួយឬ

(២)រំពឹងថាអ្នកនឹងអាចគិតឃើញអំពីរបៀបសរសេរពាក្យថ្មីៗដោយខ្លួនឯង និងដាក់ទណ្ឌកម្មចំពោះអ្នកនៅពេលដែលអ្នកសរសេរខុស?

**ខ. តើអ្នកអាចរៀនសូត្របានច្រើនឬទេប្រសិនបើគ្រូរបស់អ្នក៖**

(១) ទទួលស្គាល់និងសរសើរការប្រឹងប្រែងរបស់អ្នកសូម្បីការសរសេរនោះពុំបានត្រឹមត្រូវក៏ដោយឬ

(២) គំរាមដាក់ទណ្ឌកម្មចំពោះអ្នកនៅពេលដែលអ្នកសរសេរខុស?

**គ. តើអ្នកចង់ធ្វើឱ្យគ្រូរីករាយឬទេចំពោះគ្រូដែល៖**

(១) និយាយជាមួយអ្នកអំពីកំហុសរបស់អ្នកនិងបង្ហាញរបៀបកែលម្អនៅពេលក្រោយឬ

(២) វាយអ្នកនៅពេលដែលអ្នកសរសេរខុស?

**ឃ. តើអ្នកអាចរៀនបានច្រើនឬទេនៅពេលគ្រូរបស់អ្នក៖**

(១) ផ្ដល់តម្រុយនិងលើកទឹកចិត្តឱ្យអ្នកប្រឹងប្រែងឬ

(២) ប្រាប់អ្នកថាអ្នកនឹងមិនអាចរៀនចេះនិងមិនអាចធ្វើអ្វីត្រូវឡើយ

**ជាចុងបញ្ចប់ ទាំងការផ្ដល់ភាពកក់ក្ដៅ និងការណែនាំនាំមកនូវ៖**

- ទំនាក់ទំនងវិជ្ជមានរវាងគ្រូ និងសិស្ស
- លទ្ធផលសិក្សារបស់សិស្សកាន់តែប្រសើរ
- អាកប្បកិរិយារបស់សិស្សក្នុងសង្គមកាន់តែប្រសើរ។

### ប្រអប់យោបល់៖ វិធីនានាដើម្បីបង្កើតទំនាក់ទំនងមួយដែលមានប្រយោជន៍ជាមួយសិស្ស[១២]

- ងាយស្រួលប្រាស្រ័យទាក់ទង៖អ្នកអាចផ្ដល់ការលើកសរសើរនៅពេលដែលសិស្សមានភាពក្លាហានក្នុងការលើកជាសំណួរឬនៅពេលដែលពួកគេផ្ដល់ចម្លើយដែលត្រឹមត្រូវ។
- ស្ដាប់៖សូមរក្សាភាពអត់ធ្មត់នៅពេលសិស្សព្យាយាមសម្ដែងគំនិតឬរាយការណ៍អំពីឧប្បទ្វហេតុណាមួយ និងលើកសំណួរនានាដែលនឹងជួយពួកគេគិតក្នុងការផ្ដើតជាពាក្យ។
- មានការយល់ដឹងអំពីយេនឌ័រ៖ លើកទឹកចិត្តកុមារី និងកុមារា ក្នុងការចូលរួម និងដឹកនាំនៅក្នុងថ្នាក់ស្មើៗគ្នា គោរពគ្នាទៅវិញទៅមក និងឆ្លើយតបទៅនឹងការយល់ឃើញខុសៗគ្នារវាងកុមារី និងកុមារា។ ចាត់ទុកគ្រូបង្រៀនស្រី និងប្រុសស្មើៗគ្នាដើម្បីបង្ហាញពីសារសំខាន់នៃសមភាពយេនឌ័រ។

---

១១ សកម្មភាពដកស្រង់ចេញពី Durrant, 2010 ទំព័រ 78

១២ ប្រអប់យោបល់ត្រូវបានដកស្រង់ពី Raising Voices ឯកសារណែនាំដ៏មានសារសំខាន់សម្រាប់សាលារៀន ជំហាន 3 ទំព័រ 15

- ផ្តល់ការណែនាំ៖ណែនាំសិស្សដោយជួយពួកគេក្នុងការស្វែងយល់ពីជម្រើសនានានិងដោយគាំទ្រពួកគេក្នុងការធ្វើសេចក្តីសម្រេចរបស់ពួកគេដោយខ្លួនឯងផ្ទាល់ប្រសើរជាងការដោះស្រាយបញ្ហាជំនួសពួកគេ។
- បង្ហាញពីការគោរព៖ទោះបីសិស្សបង្ហាញពីការការចែករំលែកគំនិតឬសាកសួរក៏ដោយសូមបង្ហាញពីការគោរពភ្លាមៗតាមរយៈពាក្យសំដីនិងកាយវិការ។
- ផ្តល់ព័ត៌មាន៖សូមជួយសិស្សក្នុងការទទួលបានព័ត៌មានដែលអ្នកកត់សម្គាល់ថាពួកគេត្រូវការ (ដូចជាព័ត៌មានអំពីសកម្មភាពណាខ្លះដែលត្រូវអនុវត្តនៅក្រោយរៀនចប់ឬព័ត៌មានអំពីវិជ្ជាជីវៈនានាដែលត្រូវគិតអំពីថាតើពួកគេចង់ក្លាយជាមនុស្សបែបណា)
- ផ្តល់ការតស៊ូមតិ៖នៅពេលអ្នកសង្ស័យថាសិស្សណាម្នាក់ងាយរងគ្រោះនិងត្រូវការជំនួយសូមធ្វើការតស៊ូមតិដើម្បីឱ្យមានអន្តរាគមន៍គាំទ្រក្នុងនាមពួកគេ។

## ២.២ បទពិសោធន៍ជា"អារម្មណ៍ល្អ" ច្រើនជាងបទពិសោធន៍ជា"អារម្មណ៍មិនល្អ"

### ប្រអប់សកម្មភាព – ការចងចាំនូវអារម្មណ៍កាលពីកុមារ[១៣]

សូមគិតត្រឡប់មកកុមារភាពរបស់អ្នក។ ត្រូវចាំថាមនុស្សធំម្នាក់បានធ្វើឱ្យអ្នកមានអារម្មណ៍ល្អកាលដែលអ្នកនៅជាកុមារហើយបន្ទាប់មកត្រូវចងចាំអំពីមនុស្សធំដែលធ្វើឱ្យអ្នកមានអារម្មណ៍មិនល្អ។

ចូរកត់ត្រាប្រយោគមួយចំនួនអំពីពាក្យដែលបុគ្គលទាំងនេះបានធ្វើឱ្យអ្នកមានអារម្មណ៍ល្អនិងមិនល្អ។

| 'ធ្វើឱ្យខ្ញុំមានអារម្មណ៍ល្អ' | 'ធ្វើឱ្យខ្ញុំមានអារម្មណ៍មិនល្អ' |
|---|---|
| o និទានរឿងល្អៗប្រាប់ខ្ញុំ | o ស្រែកដាក់ខ្ញុំ |
| o ចិត្តល្អចំពោះខ្ញុំ | o ប្រមាថខ្ញុំ |
| o ... | o ... |
| o ... | o ... |
| o ... | o ... |
| o ... | o ... |
| o ... | o ... |
| o ... | o ... |

**សួរខ្លួនឯងនូវសំណួរដូចតទៅ៖**

- តើកុមារសម័យនេះជួបរឿងរ៉ាវដូចគ្នានេះឬទេ?
- តើរឿងរ៉ាវរបស់ពួកគេខុសគ្នាពីអ្វីដែលយើងបានជួបប្រទះកាលពីក្មេងឬទេ?
- ប្រសិនបើរឿងរ៉ាវទាំងនោះធ្វើឱ្យយើងមានអារម្មណ៍មិនល្អហេតុអ្វីយើងចង់ឱ្យកុមារសម័យនេះមានអារម្មណ៍បែបនោះដែរ?
- ក្នុងនាមជាមនុស្សធំតើអ្នកអាចធ្វើអ្វីបានដើម្បីជួយកុមារនៅក្នុងការថែទាំរបស់យើងឱ្យទទួលបានបទពិសោធន៍កាន់តែច្រើនថែមទៀតអំពី"អារម្មណ៍ល្អ"?

១៣ សកម្មភាពត្រូវបានដកស្រង់ចេញពី Raising Voices ឯកសារណែនាំដ៏មានសារសំខាន់សម្រាប់សាលារៀន ម៉ូឌុល 3.1

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ត្រូវចងចាំ៖ អ្នកពុំចាំបាច់ធ្វើខ្លួនឱ្យក្លាយជាគ្រូបង្រៀនម្នាក់ដែលល្អឥតខ្ចោះនោះទេ។ គោលដៅគឺការព្យាយាមបង្កើតទំនាក់ទំនងមួយជាមួយសិស្សរបស់អ្នកដែលក្នុងនោះមានបទពិសោធន៍ជា"អារម្មណ៍ល្អ" ច្រើនជាងបទពិសោធន៍ជា "អារម្មណ៍មិនល្អ"។

## ២.៣ ការស្វែងយល់ពីការវិវត្តរបស់កុមារ

### ចាប់ពីកំណើតដល់អាយុប្រាំឆ្នាំ (កុមារតូច)



នៅអាយុនេះ ពិភពលោកសង្គមរបស់កុមារត្រូវបានដឹកនាំយ៉ាងសំខាន់តាមរយៈសមាជិកគ្រួសាររបស់ពួកគេ។ ឪពុកម្តាយ និងអ្នកថែទាំជាមនុស្សដំបូងក្នុងជីវិតរបស់កុមារ[១៤] ។ ពួកគេមានសិទ្ធិគ្រប់គ្រងលើបរិស្ថានសម្រាប់កុមាររស់នៅ និងមនុស្សដែលកុមារមានទំនាក់ទំនងជាមួយ។ កុមារតូចៗអាចប្រាប់ពីភាពខុសគ្នារវាងកុមារី និងកុមារា និងចាប់ផ្តើមញែកឱ្យឃើញភាពខុសគ្នារវាងសកម្មភាពរបស់មនុស្ស "ប្រុសៗ" និង "ស្រី"។ អហិង្សា ទំនាក់ទំនងឪពុកម្តាយ-កូនប្រកបដោយការទទួលខុសត្រូវ និងស្មោះត្រង់គឺសំខាន់ដល់ការលូតលាស់របស់កុមារ។

អ្នកបង្កើតចូលរួមក្នុងការឆ្លើយតបនឹងតម្រូវការរាងកាយ និងផ្លូវចិត្ត ក៏ដូចជាផ្តល់សុវត្ថិភាព ភាពកក់ក្តៅ និងការលើកទឹកចិត្ត។

### ចាប់ពី ៦ ដល់ ១២ ឆ្នាំ (កុមារស្ថិតក្នុងវ័យកណ្តាល)

ការចូលរៀនក្នុងសាលាបឋម កុមារអាចពង្រីកពិភពលោករបស់ពួកគេ ក៏ដូចជាទំនាក់ទំនងជាមួយគ្រូ និងមិត្តរួមថ្នាក់ផងដែរ។ ឥឡូវនេះ កុមារកំពុងចំណាយពេលកាន់តែច្រើននៅសាលារៀនច្រើនជាងនៅផ្ទះ ហើយគ្រូដើរតួជាគំរូសំខាន់។ កិច្ចការអភិវឌ្ឍន៍សំខាន់សម្រាប់កុមារនៅអាយុនេះ[១៥] ៖



- ការផ្សារភ្ជាប់ទៅនឹងសាលាបឋមសិក្សាប្រកបដោយភាពជោគជ័យ
- ការសម្របទៅនឹងជីវិតក្នុងសាលារៀន (ឧទាហរណ៍ ការចូលរៀនក្នុងសាលា និងមកទាន់ពេលវេលា)
- លទ្ធផលសិក្សា (ឧទាហរណ៍ រៀនអាន ឬធ្វើលំហាត់គណិតវិទ្យា)
- រៀនអនុវត្តតាមវិធានសីលធម៌ និងអ្វីដែលចាត់ទុកថាជាអាកប្បកិរិយាប្រឆាំងនឹងសង្គម
- ចុះសម្រុងជាមួយមិត្តភក្តិ (ឧទាហរណ៍ ការទទួលយកអ្នកដទៃ និងបង្កើតមិត្តថ្មី)
- ដាក់បញ្ចូលតួនាទីយេនឌ័រទៅក្នុងអាកប្បកិរិយារបស់ពួកគេ ជំនឿទុកចិត្តលើខ្លួនឯង និងជម្រើសនៃការរៀនសូត្រ
- រៀនយល់អំពីរាងកាយរបស់ពួកគេ និងបម្លាស់ប្តូររាងកាយនៅពេលពេញវ័យ

វាមិនមែនជាការភ្ញាក់ផ្អើលអ្វីទេដែលទំនាក់ទំនងអហិង្សា ភាពវិជ្ជមាន កុមារមជ្ឈមណ្ឌល និងទំនាក់ទំនងរវាងគ្រូ និងសិស្សជួយសិស្សក្នុងការសម្រេចបានកិច្ចការទាំងនេះ។ ទំនាក់ទំនងដូចនោះក៏នាំឱ្យទទួលបានលទ្ធផលគាប់ប្រសើរសម្រាប់កុមារនៅពេលទំនាក់ទំនងនោះឈានដល់ការអភិវឌ្ឍផ្នែកស្មារតី និងចិត្តសាស្ត្រសង្គម និងលទ្ធផលសិក្សាទាំងអស់ផងដែរ[១៦] ។

---

១៤ Kern, 2009, p. 366

១៥ Masten & Coatsworth, 1998 ទំព័រ 207

១៦ Hattje, 2008; Roorda, Koomen, Spilt & Oort, 2011; Pasternak, 2013; Klem & Connell, 2004

| របៀបគាំទ្រកុមារមានអាយុ៦ ទៅ ១២ ឆ្នាំ [១៧] | |
|---|---|
| សិស្សម្នាក់ៗមានចំណុចពិសេសរៀងៗខ្លួន។ ពួកគេទាំងអស់អភិវឌ្ឍខ្លួននៅពេល និងល្បឿនរបស់ពួកគេ។ ទាំងនេះបណ្ដាលឱ្យមានភាពខុសគ្នាក្នុងចំណោមសិស្សដែលមានអាយុដូចៗគ្នា។ | **សិស្សត្រូវការវិធីសាស្ត្របង្រៀនម្នាក់ៗ។** |
| សិស្សមានភាពចង់ដឹងចង់ឮ និងការលើកទឹកចិត្តទៅសិក្សារៀនសូត្រពីធម្មជាតិ។ ពួកគេចង់រៀនសូត្រដើម្បីបង្កើនផ្នែកទាំងនោះឱ្យសមស្របនឹងអាយុនិងដំណាក់កាលលូតលាស់របស់ពួកគេដោយឯករាជ្យ។ | **សិស្សត្រូវការឱកាសរៀនសូត្រដែលមានភាពច្នៃប្រឌិត និងផ្តល់អំណាច។** |
| សិស្សចង់ធ្វើឱ្យគ្រូរបស់ពួកគេសប្បាយរីករាយ។ សិស្សចូលចិត្តនិងគោរពគ្រូរបស់ពួកគេ[១៨]។ នេះជាទំនាក់ទំនងវិជ្ជមានដែលលើកទឹកចិត្តសិស្សឱ្យខំរៀននិងចង់ក្លាយជាសិស្សល្អ។ | **សិស្សត្រូវការទំនាក់ទំនងដែលមានភាពជឿជាក់ និងអាចទុកចិត្តបានជាមួយគ្រូពួកគេ។** |
| សិស្សរៀនអំពីការរំពឹងទុករបស់សង្គមចំពោះតួនាទីយេនឌ័រ នៅពេលដែលកុមារីមានភាពអកម្ម និងរាបសារ ខណៈពេលដែលកុមារាមានភាពជាមេដឹកនាំពីធម្មជាតិជាង និងមិនសូវជាបង្ហាញនូវអារម្មណ៍របស់គេឡើយ។ ផ្នត់គំនិតទាំងនេះបានជះឥទ្ធិពលដល់សមត្ថភាពក្នុងការសិក្សារបស់កុមារី និងកុមារា រាំងស្ទះចំណង់ចំណូលចិត្តនៅលើមុខវិជ្ជា សកម្មភាពក្នុងសាលារៀន ព្រមទាំងសុខភាពផ្លូវកាយ និងផ្លូវចិត្ត។ | **សិស្សត្រូវការរៀនអំពីសមភាពយេនឌ័រ សិទ្ធិស្មើគ្នាសម្រាប់កុមារី និងកុមារា។** |
| សិស្សមានចម្ងល់ច្រើនអំពីរាងកាយរបស់ពួកគេ និងរបៀបដែលរាងកាយរបស់ពួកគេបានផ្លាស់ប្តូរនៅពេលដែលពេញវ័យ។ ពួកគេស្វែងរកព័ត៌មាន និងការណែនាំដើម្បីជួយពន្យល់នូវអ្វីដែលគេឃើញ និងមានអារម្មណ៍។ នៅពេលដែលពួកគេឡើងថ្នាក់កម្រិតខ្ពស់នៅបឋមសិក្សា កុមារីស្វែងរកការណែនាំពីរបៀបដែលគ្រប់គ្រងរដូវរបស់ខ្លួន។ | **សិស្សត្រូវការការណែនាំអំពីអ្វីដែលត្រូវរំពឹងទុកនៅពេលដែលពួកគេបានចូលដល់ភាពពេញវ័យ ដើម្បីជួយគ្រប់គ្រងស្ថានការណ៍នៅដំណាក់កាលដោយពុំមានភាពភ័យខ្លាច ឬភាពស្រពេចស្រពិល។** |
| សិស្សចង់ធ្វើតាមការណែនាំ និងទទួលយកការតម្រង់ទិសដៅ។ ជាទូទៅ ពួកគេក៏ចេះសហការគ្នាផងដែរ។ ពួកគេចង់ឱ្យគ្រូមានមោទនភាពចំពោះពួកគេ។ ដូច្នេះហើយ ពួកគេចង់ជៀសវាងស្ថានភាពណាដែល ធ្វើឱ្យគ្រូរបស់ពួកគេដកសេចក្តីស្រឡាញ់ និងការលើកទឹកចិត្ត[១៩]។ | **សិស្សត្រូវការវិធានច្បាស់លាស់ ការលើកទឹកចិត្ត និងមតិតបវិជ្ជមាន។** |
| ទណ្ឌកម្មផ្នែករាងកាយ ក៏ដូចជាកង្វះចំណាប់អារម្មណ៍ធ្វើឱ្យសិស្សមានអារម្មណ៍ថាត្រូវបានគេបដិសេធចោល និងមិនមានការលើកទឹកចិត្ត។ សិស្សប្រហែលជាគិតថា"គ្រូរបស់ខ្ញុំមិនចូលចិត្តខ្ញុំទេ"។ វាធ្វើឱ្យសិស្សឈឺចាប់ និងធ្វើឱ្យពួកគេមានអារម្មណ៍ថាមានភាពអៀនខ្មាសណាស់។ វាធ្វើឱ្យពួកគេ លែងឱ្យតម្លៃខ្លួនឯង។ ពួកគេអាចបាត់បង់ចំណាប់អារម្មណ៍ក្នុងការមកសាលារៀន។ ពួកគេអាចបដិសេធក្នុងការសហការ បង្កការរំខានក្នុងថ្នាក់រៀន និងមានអាកប្បកិរិយា"មិនគប្បី" ហើយឈប់ស្តាប់គ្រូ។ | **សិស្សត្រូវការការស្វែងយល់ ការយល់ចិត្ត ការសន្ទនា និងវិធានដាក់វិន័យវិជ្ជមានដើម្បីបំពេញកិច្ចការសាលាបានល្អ។** |
| ការលើកទឹកចិត្តតិចតួចពេក ឬច្រើនហួសហេតុពេកធ្វើឱ្យសិស្សមានអារម្មណ៍ធុញទ្រាន់ ឬរំខាន។ សិស្សចង់ប្រតិកម្មតបតឱ្យបានលឿនទៅលើអារម្មណ៍បែបនោះដោយប្រើអាកប្បកិរិយាបង្កការរំខានដល់ថ្នាក់រៀនជាដើម។ | **ត្រូវចងចាំថាសិស្សទាំងអស់មានលក្ខណៈពិសេសរៀងខ្លួនៗ។ ពួកគេត្រូវការវិធីសាស្ត្របង្រៀនម្នាក់ៗ និងការរំពឹងទុកច្បាស់លាស់ផ្អែកលើអាយុ និងដំណាក់កាលនៃការលូតលាស់របស់ពួកគេ។** |

១៧ រូបភាពផ្ទាល់ខ្លួនផ្អែកលើសេចក្តីសង្ខេបនៃ Largo & Beglinger 2010; Largo 2011

១៨ In a recent study, Discipline Methods in Cambodian Schools, investigating 1,081 students in 24 primary schools, almost every female (99.8%) and male (99.4%) student from grade 4 and 5 reported liking their teacher (Royal University of Phnom Penh, 2015).

១៩ សូមមើលផងដែរ៖ Parens 2011

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | |
|---|---|
| ក្មេងតូចៗចង់ធ្វើត្រាប់តាម និងចម្លងអាកប្បកិរិយាដែលពួកគេអង្កេតមើលអ្នកដទៃ។ គ្រូជាគំរូសំខាន់សម្រាប់សិស្ស។ សិស្សនឹងចម្លងយកអាកប្បកិរិយាគ្រូ។ | **សិស្សត្រូវការគំរូល្អវិជ្ជមាន។** |

**សេចក្តីបញ្ចប់៖** ការបង្កើតទំនាក់ទំនងរវាងសិស្ស និងគ្រូជាវិជ្ជមានត្រូវកើតឡើងទីមួយ។ ការអប់រំសិស្សត្រូវកើតឡើងទីពីរ។

## ប្រអប់យោបល់៖ ដើម្បីអប់រំដល់កុមារទាំងអស់ - របៀបដែលកុមាររៀនបានល្អបំផុតក្នុងសាលា[២០]

| ទំហំនៃការលូតលាស់ | ការលូតលាស់កុមារវ័យកណ្តាល | អនុសាសន៍សម្រាប់គ្រូបង្រៀន |
|---|---|---|
| របៀបសិស្សរៀន | សិស្សរៀនតាមរយៈការធ្វើត្រាប់តាមអាកប្បកិរិយារបស់អ្នកដទៃ។ | ត្រូវធ្វើជាគំរូល្អ ( សូមមើលជំពូក ២.៤ ) |
| | សិស្សរៀនតាមរយៈការប្រើវត្ថុ។ | វាជួយសិស្សពេលពួកគេអាចប្រើវិញ្ញាណទាំងអស់ដូចជា ការប៉ះ ការមើល ការស្តាប់ និងការស្រង់ក្លិន។<br>ផ្តល់ការរៀនសូត្រតាមរយៈការរុករក។ ឧទាហរណ៍ ប្រសិនបើអ្នកបង្រៀនធរណីមាត្រ ឱ្យសិស្សរកមើលវត្ថុមានរាងជាត្រីកោណនៅក្នុងទីធ្លាសាលា។ |
| | ការសិក្សាតាមរយៈសេចក្តីណែនាំ ( សូមមើលជំពូក ២.៦ ) | ការធ្វើឱ្យសិស្សមានការចង់ដឹងចង់ឮ។ បង្រៀនប្រកបដោយគំនិតច្នៃប្រឌិត។ ធ្វើឱ្យសិស្សរបស់អ្នកភ្ញាក់ផ្អើល។ ឧទាហរណ៍៖ ប្រើសកម្មភាពដូចជា ភ្លៀងធ្លាក់ភ្លាមៗ ហើយឱ្យសិស្សប្រាប់អ្នកពាក្យផ្សេងៗគ្នាចាប់ផ្តើមដោយអក្សរ "r"ដូចជាពាក្យថា"rain" |
| ការលើកទឹកចិត្តសិស្សឱ្យសិក្សា | សិស្សរៀនប្រសិនបើ៖<br>❖ ពួកគេមានអារម្មណ៍ថាមានសុវត្ថិភាព និងទទួលបានការគោរព<br>❖ ពួកគេឆ្លងកាត់រឿងរ៉ាវថ្មី<br>❖ ពួកគេមានអារម្មណ៍ថាទទួលបានការលើកទឹកចិត្ត គាំទ្រ និងលើកទឹកចិត្ត | បង្កើតទំនាក់ទំនងប្រកបដោយភាពជឿជាក់ កក់ក្តៅជាមួយសិស្សរបស់អ្នក គោរពសិស្សរបស់អ្នក។<br>ត្រូវរួមបញ្ចូលទាំងកុមារី និងកុមារាក្នុងការសម្រេចចិត្តដែលពាក់ព័ន្ធចំពោះថ្នាក់រៀន និងថ្នាក់រៀន។<br>ត្រូវផ្តល់ឱកាសឱ្យបានច្រើនដល់សិស្សដើម្បីរកប្រធានបទថ្មីដោយប្រើសមត្ថភាពរបស់ពួកគេ។<br>លើកទឹកចិត្តឱ្យមានការខិតខំប្រឹងប្រែងបន្ថែម មិនមែនត្រឹមតែជោគជ័យ និងភាពល្អប្រសើរនោះទេ( សូមមើលជំពូក៥.៣ )។ |
| អាកប្បកិរិយាក្នុងសង្គម | ការចុះសម្រុងជាមួយដៃគូ និងការបង្កើតមិត្តភាពគឺជាកិច្ចការសំខាន់សម្រាប់ការលូតលាស់។ ទោះជាយ៉ាងណា កុមារអាចឆ្លងកាត់ការមានជម្លោះជាមួយដៃគូមានការសម្លុតគ្នា។ កុមារា និងកុមារី អាចនឹងឆ្លងកាត់អំពើហិង្សាយេនឌ័រពីមិត្តភក្តិនៅក្នុងទីធ្លាសាលារៀន។ | ពង្រឹងទំនាក់ទំនងក្នុងសង្គម និងការសហការក្នុងចំណោមសិស្សទាំងអស់។ ឧទាហរណ៍ការច្រៀងជាមួយសិស្សក្នុងថ្នាក់។<br>បង្ការមិនឱ្យមានការរើសអើង និងគ្រប់រូបភាពនៃអំពើហិង្សាយេនឌ័រ។ គាំទ្រ និងលើកទឹកចិត្តសិស្សដែលទទួលរងការសម្លុត ឬមានអារម្មណ៍ឯកោ។ ឧទាហរណ៍៖ ស្តាប់ បង្ហាញការគោរព និងផ្តល់ដើម្បីគាំទ្រ។ លើកកម្ពស់សមភាពយេនឌ័រនៅក្នុងសាលារៀន។ |

២០ រូបភាពផ្ទាល់ខ្លួនផ្អែកលើសេចក្តីសង្ខេបនៃ Largo & Beglinger 2010; Masten & Coatsworth 1998

| ទំហំនៃការលូតលាស់ | ការលូតលាស់កុមារវ័យកណ្ដាល | អនុសាសន៍សម្រាប់គ្រូបង្រៀន |
|---|---|---|
| បទបញ្ជាផ្ទៃក្នុងសម្រាប់គ្រប់គ្រងការប្រព្រឹត្ត | កុមារដែលចូលរៀនក្នុងសាលាបឋមសិក្សាជាការប្រឈមមុខលើកទីមួយក្នុងជីវិតរបស់ពួកគេជាមួយស្ថាប័នក្នុងស្ថាប័ន និងទំនៀមទម្លាប់ និងតម្លៃក្នុងសង្គមរបស់ពួកគេ។ | ផ្ដល់គោលការណ៍ច្បាស់លាស់ដល់សិស្សរបស់អ្នក។ (សូមមើលជំពូក ២.១) |
| ការលូតលាស់ផ្នែករាងកាយ | កុមារមានតម្រូវការធម្មជាតិដើម្បីឱ្យរាងកាយសកម្ម។ កុមារភាគច្រើនមានរាងកាយសកម្មចន្លោះអាយុ ៧ និង ៩ ឆ្នាំ។ | ផ្ដល់ឱកាសសម្រាប់ធ្វើសកម្មភាពរាងកាយឱ្យបានទៀងទាត់។ ការធ្វើដូចនេះជៀសវាងការបាត់បង់ការផ្ដោតការយកចិត្តទុកដាក់ និងបង្កើនឆន្ទៈក្នុងការរៀនសូត្រ។ ត្រូវរួមបញ្ចូលសកម្មភាពរាងកាយក្នុងថ្នាក់រៀន។ ឧទាហរណ៍៖ ធ្វើលំហាត់ប្រាណរាងកាយសប្បាយៗខ្លះៗ។ |
| តន្ត្រី បង្កើតសកម្មភាពសប្បាយៗ | ការច្រៀង ការរាំ និងការលេងតន្ត្រីគឺជាសកម្មភាពសប្បាយៗ និងបង្កើនការពេញចិត្តផ្លូវអារម្មណ៍របស់សិស្ស។ វាថែមទាំងគាំទ្រការសហការក្នុងសង្គមក្នុងចំណោមមិត្តរួមថ្នាក់។ វាអាចគាំទ្រការលើកទឹកចិត្តសិស្សឱ្យរៀនសូត្រ។ | ផ្ដល់ឱកាសច្រៀង រាំ និងលេងតន្ត្រីក្នុងថ្នាក់រៀន និងសាលាឱ្យបានទៀងទាត់។ |

## ការអភិវឌ្ឍខាងស្មារតីនិងផ្លូវចិត្តរបស់សិស្ស[២១]

ការរៀនសូត្រគឺជាលទ្ធផលនៃអន្តរកម្មដ៏ស្មុគស្មាញមួយរវាងសមត្ថភាពសិស្សក្នុងការវិភាគព័ត៌មាននិងវិសាលភាពនៃបរិស្ថានសាលារៀនកុមារមេត្រីនិងដែលគាំទ្រ។

ដើម្បីអាចឱ្យសិស្សរៀនសូត្រនិងមានសុក្កានុពលពេញលេញសាលារៀនគួរតែមានសុវត្ថិភាពនិងផ្ដល់នូវបរិស្ថានរៀនសូត្រដែលមានលក្ខណៈកុមារមេត្រីនិងដែលលើកទឹកចិត្ត។

រូបខាងក្រោមបង្ហាញជំហាននៃការរៀនសូត្រចំនួនបួនរបស់សិស្ស។ ជំហានទាំងនេះរួមមាន៖

១. ការចាប់យកព័ត៌មាន (រួមបញ្ចូលការយកចិត្តទុកដាក់និងការស្ដាប់)

២. ការវិភាគព័ត៌មាន (រួមបញ្ចូលការប្រៀបធៀបការត្រិះរិះរកហេតុផលភាពអត់ធ្មត់និងការប្រមូលអារម្មណ៍)

៣. ការស្វែងយល់

៤. ការប្រើប្រាស់ព័ត៌មាន (រួមបញ្ចូលសំណុំលក្ខណៈនានារបស់សិស្សដូចជាសភាវគតិការសម្រេចបានត្រឹមត្រូវទំនុកចិត្តនិងប្រឌិតញាណនិងរួមបញ្ចូលបទពិសោធន៍ផងដែរ)។

ដើម្បីសម្រេចបានជំហានទាំងបួនសិស្សត្រូវ៖

- ❖ ទទួលកិច្ចការពារ
- ❖ ការទទួលយក
- ❖ មានការគោរព
- ❖ កម្មវត្ថុនៃថ្នាក់រៀននិងសាលារៀន។

២១ ផ្នែករងនេះត្រូវបានដកស្រង់ចេញពី Raising Voices, The Good School toolkit, What is a good schol? p. 8-9



t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

បរិស្ថានរៀនសូត្រកុមារមេត្រីនិងប្រកបដោយការលើកទឹកចិត្តបែបនេះអាចបង្កើតឡើងបានប្រសិនបើសាលារៀនចាត់ទុកជាអាទិភាពនូវ៖

- ទំនាក់ទំនងល្អរវាងសិស្សនិងគ្រូ
- ការធ្វើជាគំរូនិងការប្រៀនប្រដៅឱ្យបានខ្លាំងក្លា
- បរិស្ថានរៀនសូត្រដែលមានសុវត្ថិភាពនិង
- ស្តង់ដារច្បាស់លាស់



## ២.៤ ការធ្វើជាគំរូវិជ្ជមាន[២២]

គ្រូល្អគឺជាអ្នកដែលផ្តល់គំរូវិជ្ជមានសម្រាប់សិស្ស។







២២ ផ្នែកនេះត្រូវបានដកស្រង់ចេញពី Raising Voices, The Good School Toolkit, Cartoon Booklet, What is a good teacher?

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews


ហឹម... ពិសិដ្ឋប៉ាអាចនិយាយបាន ថាគឺលោក លឹមដែលជា លោកគ្រូថ្នាក់ទី៣របស់ប៉ា។
ជាគ្រូម្នាក់? ហេតុអ្វីទៅ?


គាត់តែងតែជួយប៉ាយ៉ាងច្រើន ណាស់នៅរាល់ពេលប៉ាមិនបាន យល់មេរៀន។

youtube.com/moeyscambodia
sala.moeys.gov.kh
t.me/moeysnews




ប៉ាតែងតែចង់ធ្វើឱ្យគាត់សប្បាយចិត្ត។ គាត់បានធ្វើឱ្យប៉ាមានអារម្មណ៍ថា ប៉ាអាចធ្វើអ្វីបានគ្រប់យ៉ាងបាន!


ពិតមែនឬ? គ្រូរបស់កូនពេលខ្លះធ្វើឱ្យកូនមានអារម្មណ៍ថាកូនល្ងង់ណាស់!







youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews


មិនដែលទេ ?
ទេ មិនដែលសោះ។ ប៉ាតែងតែមាន
អារម្មណ៍កក់ក្តៅពេលរៀនជាមួយគាត់។
ប៉ាទុកចិត្តលើគាត់ !


អ៎ាវប៉ា !កូនសង្ឃឹមថាកូននឹង
បានរៀនជាមួយលោកលឹម
នៅសាលារបស់កូនដែរ។

## ២.៥ ការស្វែងយល់អំពីសិស្សរបស់អ្នក[២៣]

**ប្រអប់សកម្មភាព - តើខ្ញុំជាអ្នកណា?**

១. នៅពេលចាប់ផ្ដើមឆ្នាំសិក្សាចូរថតចម្លងប័ណ្ណខាងក្រោមនិងសូមឱ្យសិស្សបំពេញប័ណ្ណនោះ។

គំរូប័ណ្ណនេះមានក្នុងឧបសម្ព័ន្ធ១។

២. ចូរប្រើព័ត៌មាននេះដើម្បីជជែកជាមួយសិស្សអ្នករៀបចំកិច្ចតែងការនិងបង្កើតសកម្មភាពរៀនសូត្រ។

៣. នៅចុងឆមាសទីមួយចូរស្នើសិស្សរបស់អ្នកឱ្យបំពេញប័ណ្ណនោះម្ដងទៀតនិងបន្ទាប់មកពិនិត្យមើលរាល់ការកែប្រែជាពិសេសដែលទាក់ទងនឹងអ្វីដែលសិស្សម្នាក់ៗជឿថាគាត់ជាសិស្សពូកែឬមិនពូកែធ្វើអ្វីម៉្យាងក៏ដូចជានៅពេលពួកគេសប្បាយរីករាយឬមានអារម្មណ៍មិនស្រួលនៅក្នុងថ្នាក់រៀន។

៤. ចូរប្រើប្រាស់ព័ត៌មាននេះដើម្បីបង្កើនទំនុកចិត្តរបស់សិស្សនិងធ្វើឱ្យថ្នាក់រៀនជាកន្លែងរីករាយសម្រាប់ការសិក្សា។

**ប័ណ្ណ - ខ្ញុំជានរណា?**

ឈ្មោះសិស្ស: ______ ខ្ញុំចង់ឱ្យគេហៅថា ______

រឿងមួយដែលអ្នកត្រូវដឹងអំពីខ្ញុំគឺ ______

______

ខ្ញុំចង់ធ្វើការជាមួយ ______ ខ្ញុំពិតជាពូកែខាង ______

ខ្ញុំមិនពូកែឡើយខាង ______ ខ្ញុំរីករាយបំផុតនៅក្នុងថ្នាក់ នៅពេល ______

______

ខ្ញុំគ្មានអារម្មណ៍សុខស្រួលឡើយក្នុងថ្នាក់ ក្នុងពេល ______

______

២៣ ជំពូកនេះត្រូវបានដកស្រង់ចេញពីUNESCO, 2006, p. 44-45

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ការស្វែងយល់ពីប្រវត្តិគ្រួសារសិស្សរបស់អ្នក

របៀបដែលសិស្សណាម្នាក់ប្រព្រឹត្តអ្វីមួយនៅក្នុងថ្នាក់រៀនរបស់អ្នកអាចឆ្លុះបញ្ចាំងអំពីការខកចិត្តចំពោះខ្លួនឯងនៅក្នុងជីវិតក្នុងគ្រួសារឬនៅក្នុងការប្រឈមចំពោះកាលៈទេសៈលំបាកនានាផ្សេងទៀតនៅក្នុងនិងនៅក្រៅសាលារៀន។ យើងត្រូវតែមានការប្រុងប្រយ័ត្ននៅក្នុងការបកស្រាយអំពីអាកប្បកិរិយារបស់សិស្ស។

អ្វីដែលយើងគិតថាជាអាកប្បកិរិយាឆ្គាំឆ្គងអាចមិនមែនជាបញ្ហាណាមួយខាងវិន័យឡើយ។ ឧទាហរណ៍កុមារអាចស្វែងរកការយកចិត្តទុកដាក់បន្ថែមពីរូបអ្នកដោយសារគាត់ពុំបានទទួលការយកចិត្តទុកដាក់ពីអ្នកណាម្នាក់ឡើយនៅផ្ទះ។

វាអាចជាប្រតិកម្មរបស់កុមារនោះឬការខកចិត្តចំពោះបញ្ហានានានៅក្នុងផ្ទះ ឬនៅកន្លែងដទៃដែលគាត់នាំយកមកបញ្ចូលនៅក្នុងថ្នាក់រៀន។

ដូច្នេះមិនមែនអាកប្បកិរិយារបស់សិស្សទេដែលជាបញ្ហាប៉ុន្តែ**គឺស្ថានភាពដែលក្នុងនោះអាកប្បកិរិយាសិស្សនោះត្រូវគេសង្កេតឃើញ។**




**ត្រូវចងចាំ៖** សិស្សម្នាក់ៗគឺជាបុគ្គលម្នាក់។ សិស្សម្នាក់ៗនាំមកនូវប្រវត្តិខុសៗគ្នាវិធីខុសគ្នាមួយនៃការឆ្លើយតបនឹងពិភពលោកនិងសុបិនខុសៗគ្នាមួយសម្រាប់អនាគត។ តាមរយៈការចំណាយពេលដើម្បីស្វែងអំពីសិស្សរបស់អ្នកជាលក្ខណៈបុគ្គលនិងតាមរយៈការស្វែងយល់ពីគ្រួសាររបស់ពួកគេបង្ហាញថាអ្នកបានយកចិត្តទុកដាក់ចំពោះពួកគេនិងគោរពលក្ខណៈដោយឡែករបស់ពួកគេ។

## ២.៦ ការស្វែងយល់ពីវិធីសាស្ត្របង្រៀនតាមបែបប្រពៃណី[២៤]

វិធីសាស្ត្របង្រៀនតាមបែបប្រពៃណីទំនងជាបានផ្អែកលើការសន្មតដូចខាងក្រោមដោយផាត់ចោលសំណុំលក្ខណៈសំខាន់ៗនៃការរៀនសូត្រ៖

១. គ្រូពឹងផ្អែកលើការកត់ត្រាយ៉ាងច្រើននិងការរម្លឹកឡើងវិញឱ្យបានត្រឹមត្រូវ

២. គ្រូបង្រៀនផ្តោតលើការបញ្ជូនព័ត៌មានជាជាងលើរបៀបនៃការទទួលព័ត៌មាន

វិធីសាស្ត្រទាំងពីរនេះផ្តោតតែលើជំហានដំបូងនៃដំណើរការរៀនសូត្រ-ការចាប់យកព័ត៌មាន។ វិធីនេះផាត់ចោលទិដ្ឋភាពសំខាន់ៗចំនួនបីផ្សេងទៀតនៃដំណើរការរៀនសូត្រ៖ ការវិភាគការស្វែងយល់និងការប្រើប្រាស់ព័ត៌មាន។

**តើយើងអាចកែប្រែវិធីនេះបែបណា?**

- គេគួរប្រើប្រាស់វិធីបង្រៀនដែលកាន់តែមានភាពច្នៃប្រឌិតដើម្បីបំពេញចំណង់ចំណូលចិត្តពីកំណើតរបស់សិស្សក្នុងការសិក្សានិងបង្កើតឱ្យមានការរំភើបរីករាយ។
- ភាពច្នៃប្រឌិតនិងប្រើប្រាស់ឧទាហរណ៍ពីជីវភាពប្រចាំថ្ងៃដែលបណ្តាលឱ្យសិស្សមានការចង់ដឹងបន្ថែមអំពីការរៀនសូត្រនិងបំណងស្វែងយល់និងដោះស្រាយបញ្ហាចាស់ៗតាមរយៈគំនិតថ្មីៗ។
- សិស្សក្មេងៗត្រូវការប្រើប្រាស់វិញ្ញាណទាំងអស់របស់ខ្លួនដើម្បីអាចរៀនប្រកបដោយប្រសិទ្ធភាព។

៣. គ្រូត្រូវប្រឹងប្រែងដើម្បីប្រើប្រាស់ការប្រៀបប្រដៅបែបវិជ្ជមានដើម្បីលើកទឹកចិត្តឱ្យបានតែឧត្តមភាព ប៉ុន្តែមិនមែនការប្រឹងប្រែងឡើយ។ គ្រូប្រើប្រាស់ចំណាត់ថ្នាក់សិស្សនិងពាលន្ទរប្រយោគដូចជា

វិធីនេះមិនមានលក្ខណៈស្ថាបនាឡើយ យ៉ាងហោចណាស់សម្រាប់សិស្សដែលនឹងមិនអាចឈានដល់"លេខមួយ"ឬសូម្បីឱ្យបានត្រឹមលេខ១០។ វិធីនេះធ្វើឱ្យសិស្សទាំងនោះបាក់ទឹកចិត្ត។ ពួកគេនឹងបាត់បង់ចំណាប់អារម្មណ៍ចំពោះសាលារៀននិងអាចបោះបង់ចោលការសិក្សា។ វិធីនេះមិនទទួលស្គាល់ការប្រឹងប្រែងរបស់សិស្សនិងឆន្ទៈក្លាយជាសិស្សល្អនិងក្នុងការព្យាយាមឱ្យបានខ្លាំងក្លាបំផុតឡើយ។ វិធីនេះក៏មិនទទួលស្គាល់ភាពខុសៗគ្នានៃជំនាញរបស់សិស្សឡើយ។

**តើយើងអាចធ្វើបែបណាដើម្បីផ្លាស់ប្តូរវិធីនេះ?**

- **គ្រូគួរផ្តល់ឱ្យកុមារី និងកុមារានូវការទូន្មានបែបវិជ្ជមានជាទៀងទាត់**ដែលលើកទឹកចិត្តពួកគេឱ្យប្រឹងប្រែងខ្លាំងក្លានិងដើម្បីបានលទ្ធផលល្អបំផុត។ នេះមានន័យថា**វាមិនគ្រប់គ្រាន់ទេក្នុងការជ្រើសយក សិស្សពូកែបំផុតប្រចាំសប្តាហ៍ខែ ឬត្រីមាស។** សិស្សដទៃទៀតដែលរួមទាំងសិស្សដែលប្រឈមការលំបាកក្នុងការរៀនសូត្រដោយសារតែមូលហេតុខុសៗគ្នាជាច្រើនក៏ត្រូវការនូវការលើកទឹកចិត្តផងដែរ។

៤ គ្រូមានអារម្មណ៍ថាខ្លួនរងការប្រមាថនៅពេលសិស្សម្នាក់មិនយល់ ឬប្រឡងធ្លាក់ឬប្រព្រឹត្តមិនគប្បី។

៥. គ្រូនៅតែប្រើប្រាស់ការដាក់ទណ្ឌកម្មលើរាងកាយនិងផ្អែកស្មារតីដើម្បីពង្រឹងអំណាចរបស់ខ្លួននៅក្នុង

- ជាក់ស្តែងជាញឹកញាប់គឺសិស្សទាំងនោះដែលត្រូវការនូវការលើកទឹកចិត្ត។ ការលើកទឹកចិត្តនឹងជួយពួកគេឱ្យមានឆន្ទៈខ្ពស់ក្នុងការបន្តស្ថិតនៅក្នុងសាលារៀននិងបន្តការសិក្សា។

២៤ ជំពូកនេះត្រូវបានដកស្រង់ចេញពីRaising Voices, The Good School Toolkit, Cartoon Booklet, What is a good teacher?p. 16-17

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

វិធីទាំងពីរនេះផ្តោតលើឋានានុក្រមច្បាស់លាស់ដែលក្នុងនោះគ្រូប្រើអំណាចរបស់ខ្លួនដោយបំពាន។ កុមារត្រូវតែរំពឹងថាស្តាប់បង្គាប់គ្រូរបស់ពួកគេនិងនៅតែស្ងៀមស្ងាត់លើកលែងគ្រូនិយាយទៅពួកគេ។ វិធីទាំងនេះមានគោលដៅបង្កការភ័យខ្លាចផលវិបាកនៃការប្រព្រឹត្តល្មើសចំពោះបទបញ្ជាផ្ទៃក្នុង។

**វិធីទាំងនេះ៖**

- មិនអើពើចំពោះតម្រូវការភាពកក់ក្ដៅនិងការណែនាំព្រមទាំងជំហានខុសៗគ្នានៃដំណើរការរៀនសូត្រ
- ធ្វើឱ្យសិស្សបាក់ទឹកចិត្តរៀនសូត្រដោយសារតែពួកគេមានអារម្មណ៍“ខ្ជិល“ ឬ “មិនឆ្លាតគ្រប់គ្រាន់“ ឬ “តែងតែខុស“
- មិនបង្រៀនសិស្សអំពីភាពខុសគ្នារវាងត្រូវនិងខុសឬរបៀបធ្វើសេចក្ដីសម្រេចត្រឹមត្រូវឡើយ
- ផាត់ចោលការចូលរួមរបស់សិស្សនៅក្នុងថ្នាក់រៀននិងក្នុងសាលា។

**ផ្ទុយទៅវិញ៖**

- គ្រូគួរតែ**ពង្រឹងទំនាក់ទំនងកុមារមេត្រីអហិង្សាជាមួយសិស្សរបស់ខ្លួននិងដើរតួជាគំរូ**ដើម្បីបំពេញតម្រូវការនានារបស់សិស្ស៖កិច្ចការពារការទទួលយកការគោរពនិងជាកម្មវត្ថុនៃថ្នាក់រៀននិងសាលារៀន។
- គ្រូគួរតែមាន**ការយល់ដឹងកាន់តែច្រើនថែមទៀតអំពីការអភិវឌ្ឍរបស់កុមារ**ដែលរួមទាំងការយល់ដឹងអំពីមូលហេតុដែលសិស្សប្រព្រឹត្តមិនគប្បីផងដែរ។

## ២.៧ តើគ្រូល្អមានលក្ខណៈបែបណា ?

គ្រូល្អប្រើប្រាស់វិន័យបែបវិជ្ជមាននិងការគ្រប់គ្រងថ្នាក់រៀនឱ្យមានប្រសិទ្ធភាព។ រូបខាងក្រោមប្រមូលផ្ដុំសំឡេងរបស់គ្រូល្អដែលសង្ខេបបុគ្គលិកលក្ខណៈស្នូលរបស់គ្រូល្អ។

សំឡេងរបស់គ្រូបង្រៀនល្អ




youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews



# ៣

# ការរម្ងាប់កំហឹង

## ៣.១ តើព្រះពុទ្ធបង្រៀនអ្វីខ្លះអំពីភាពក្រេវក្រោធ/កំហឹង[២៥]

ភាពក្រេវក្រោធជាអាកប្បកិរិយាមួយក្នុងចំណោមអាកប្បកិរិយាចំនួនបីបន្ទាប់ពីភាពលោភលន់និងភាពល្ងង់ខ្លៅដែលត្រូវបានឱ្យនិយមន័យនៅក្នុងទ្រឹស្តីព្រះពុទ្ធសាសនា។ ចំណុចទាំងនេះមានសារសំខាន់ណាស់ចំពោះវដ្តសង្សារនិងការចាប់កំណើតឡើងវិញ។ ដូច្នេះការទប់កំហឹងមានសារសំខាន់ណាស់។

ក្នុងទ្រឹស្តីព្រះពុទ្ធសាសនាគ្មានទេការចាត់ទុកភាពក្រេវក្រោធថា"ត្រឹមត្រូវ" ឬថា"មានហេតុផល"សមស្របនោះ។ នៅទីបំផុតរាល់ភាពក្រេវក្រោធសុទ្ធសឹងជាកំហុសឆ្គង។

ប៉ុន្តែសូម្បីអ្នកជំនាញដែលមានគតិបណ្ឌិតទទួលស្គាល់ថាជួនកាលពួកគេក៏មានកំហឹងផងដែរ។ នេះមានន័យថាសម្រាប់មនុស្សយើងភាគច្រើនការជៀសវាងកំហឹងមិនមែនជាជម្រើសប្រកបដោយភាពប្រាកដនិយមនោះឡើយ។ យើងទាំងអស់គ្នាសុទ្ធតែមានកំហឹង។ ដូច្នេះតើយើងត្រូវធ្វើអ្វីខ្លះចំពោះកំហឹងរបស់យើង ?

### ទីមួយទទួលស្គាល់ថាអ្នកកំពុងខឹង

ចំណុចនេះអាចស្តាប់ទៅដូចជាផ្តេសផ្តាស ប៉ុន្តែតើប៉ុន្មានដងដែលអ្នកជួបមនុស្សណាម្នាក់ដែលកំពុងខឹងខ្លាំង ប៉ុន្តែដែលនៅតែអះអាងថាខ្លួនមិនខឹង ? ដោយសារហេតុផលខ្លះៗអ្នកខ្លះមិនទទួលស្គាល់ថាខ្លួនកំពុងខឹងឡើយ។ ការធ្វើបែបនេះគ្មានប្រយោជន៍ទេ។ អ្នកមិនអាចដោះស្រាយអ្វីមួយបានល្អឡើយប្រសិនបើអ្នកមិនទទួលស្គាល់ថាមានវានៅទីនោះ។

ទ្រឹស្តីព្រះពុទ្ធបង្រៀនពីមនសិកា។ មនសិកាអំពីខ្លួនឯងគឺជាផ្នែកសំខាន់មួយនៃការមនសិកានោះ។ នៅពេលអារម្មណ៍ឬការគិតដែលមិនបរិសុទ្ធកើតមានឡើងចូរកុំសង្កត់អារម្មណ៍ឬការគិតនោះកុំគេចវេសពីវាឬបដិសេធវាឡើយ។ ផ្ទុយទៅវិញចូរធ្វើការសង្កេតអំពីវានិងទទួលស្គាល់វាឱ្យបានពេញលេញ។ ភាពស្មោះត្រង់ចំពោះខ្លួនឯងគឺជាខ្លឹមសារនៅក្នុងទ្រឹស្តីព្រះពុទ្ធសាសនា។

### តើអ្វីខ្លះដែលធ្វើឱ្យរូបអ្នកមានកំហឹង ?

ប្រការសំខាន់គឺត្រូវយល់ថាកំហឹងគឺជាអ្វីមួយដែលរូបអ្នកបានបង្កើតឡើង។

យើងច្រើនតែគិតថាកំហឹងបង្កឡើងដោយអ្វីម៉្យាងនៅក្រៅខ្លួនយើងដូចជាមនុស្សដទៃឬព្រឹត្តិការណ៍ដែលបង្កជាការរំខាន។ ប៉ុន្តែ៖ "គ្មានអ្នកណាម្នាក់ធ្វើឱ្យអ្នកខឹងនោះទេ។ រូបអ្នកខ្លួនឯងដែលធ្វើឱ្យខ្លួនឯងខឹង។"

---

២៥ ជំពូកនេះត្រូវបានដកស្រង់ចេញពី O'Brian, 2015

ទ្រឹស្តីព្រះពុទ្ធសាសនាបង្រៀនយើងថាកំហឹងត្រូវបានបង្កើតឡើងដោយចិត្តរបស់យើង។ កំហឹងគាបសង្កត់យើងមិនឱ្យសង្កេតមើលស៊ីជម្រៅអំពីខ្លួនយើង។ ក្នុងករណីជាច្រើនកំហឹងគឺជាទម្រង់មួយនៃការការពារខ្លួន។ វាកើតចេញពីភាពភ័យខ្លាចដែលមិនអាចដោះស្រាយបានឬនៅពេលចុចលើគន្លឹះអត្តា។

## កំហឹងគឺជាការបណ្តោយខ្លួន

កំហឹងគ្មានភាពរីករាយនិងទាក់ទាញចិត្តទេ។ កំហឹងមានទំពក់។ ការចាប់កំហុសលើអ្វីមួយឬលើអ្នកណាម្នាក់គឺជារបស់ឆ្ងាញ់។ ជាពិសេសនៅពេលពាក់ព័ន្ធនឹងអត្តារបស់យើង (ដែលកើតមានស្ទើរតែក្នុងគ្រប់ករណីទាំងអស់) យើងអាចការពារកំហឹងរបស់យើង។យើងរកហេតុផលដើម្បីដោះបន្ទាល់និងរហូតដល់បង្កើនកំហឹងថែមទៀត។

ទ្រឹស្តីព្រះពុទ្ធបង្រៀនថា គេមិនអាចមានហេតុផលល្អដើម្បីមានកំហឹងឡើយ។ ទង្វើរបស់យើងបណ្តុះមេត្តាធម៌ពោលគឺសេចក្តីល្អនៃភាពសណ្តោសចំពោះភាវៈទាំងអស់ដោយពុំជាប់ជំពាក់នឹងភាពកំណាញ់។ “ភាវៈទាំងអស់” រួមទាំងសិស្សដែលធ្វើឱ្យអ្នកវង្វេងអ្នកធ្វើការជាមួយគ្នាដែលឆក់យកគុណសម្បត្តិពីគំនិតរបស់អ្នកនិងរហូតដល់បុគ្គលណាម្នាក់ដែលជិតស្និទ្ធនិងជាទីទុកចិត្តរបស់អ្នកបែរជាក្បត់រូបអ្នកទៀតផង។

អាស្រ័យដោយមូលហេតុនេះនៅពេលយើងខឹងយើងត្រូវប្រុងប្រយ័ត្នបំផុត ដោយមិនត្រូវធ្វើកាយវិការនៅក្រោមកំហឹងរបស់យើងដើម្បីធ្វើឱ្យអ្នកដទៃឈឺចាប់នោះឡើយ។ យើងត្រូវតែប្រុងប្រយ័ត្នដោយមិនរក្សាទុកកំហឹងនិងត្រូវទុកឱកាសឱ្យខ្លួនឯងបានរស់នៅនិងរីកចម្រើន។

## ធ្វើបែបណាដើម្បីដោះខ្លួនបាន

អ្នកបានទទួលស្គាល់កំហឹងរបស់ខ្លួននិងបានកំណត់អត្តសញ្ញាណអ្វីដែលបង្កឱ្យកំហឹងកើតឡើងនៅក្នុងខ្លួនរបស់អ្នក។ ប៉ុន្តែអ្នកនៅតែខឹង។ បន្ទាប់ពីនេះតើត្រូវធ្វើអ្វីខ្លះ ?

អ្នកត្រូវការភាពអត់ធ្មត់។ ភាពអត់ធ្មត់មានន័យថារង់ចាំដោយមិនធ្វើសកម្មភាពឬមិននិយាយរហូតទាល់តែអ្នកអាចធ្វើបែបនេះបានដោយមិនបង្កអន្តរាយ។ នៅក្នុងការអត់ធ្មត់មានបង្កប់នូវគុណសម្បត្តិនៃសេចក្តីទៀងត្រង់ដ៏ធំធេង។ វាក៏មានគុណសម្បត្តិនៃការមិនពង្រីករឿងរ៉ាវឱ្យកាន់តែធំផងដែរដោយអនុញ្ញាតឱ្យមានឱកាសសម្រាប់បុគ្គលដទៃក្នុងការនិយាយដើម្បីឱ្យបុគ្គលដទៃសំដែងអំពីខ្លួនឯងនៅក្នុងពេលដែលអ្នកមិនមានប្រតិកម្មតបសូម្បីអ្នកមានប្រតិកម្មនៅក្នុងអារម្មណ៍របស់ខ្លួនឯងក៏ដោយ។

ប្រសិនបើអ្នកប្រតិបត្តិសមាធិនេះជាពេលដើម្បីប្រើប្រាស់វាហើយ។ ចូរអង្គុយឱ្យស្ងៀមជាមួយកំដៅនិងភាពតានតឹងនៃកំហឹង។ ក្រសោបយកកំហឹងរបស់អ្នកជាមួយភាពអត់ធ្មត់និងសេចក្តីករុណាចំពោះភាវៈទាំងអស់ដែលរួមទាំងខ្លួនឯងផងដែរ។




## កុំបង្កើនកំហឹង

វាជាការលំបាកក្នុងការមិនធ្វើសកម្មភាពស្ថិតនៅមួយកន្លែង ដោយស្ងប់ស្ងៀមក្នុងពេលដែលអារម្មណ៍របស់យើងស្រែកដាក់យើង។ កំហឹងធ្វើឱ្យយើងមួម៉ៅនិងបណ្តាលឱ្យយើងចង់ធ្វើអ្វីម្យ៉ាង។ អ្នកខ្លះប្រាប់ឱ្យយើងក្តាប់ដៃហើយដាល់ទៅលើខ្នើយឬស្រែក

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដាក់ជញ្ជាំងឱ្យបានខ្លាំងដើម្បី"បញ្ចេញ"កំហឹងរបស់យើង។ ទ្រឹស្តីព្រះពុទ្ធមិនឯកភាពឡើយ។

នៅពេលដែលអ្នកបញ្ចេញកំហឹងរបស់ខ្លួនអ្នកគិតថាអ្នកធ្វើឱ្យកំហឹងចាកចេញពីប្រព័ន្ធរបស់អ្នកប៉ុន្តែនោះមិនពិតឡើយ។ នៅពេលអ្នកសំដែងកំហឹងរបស់ខ្លួនដោយផ្ទាល់មាត់ឬកាយវិការហិង្សារូបអ្នកមានអារម្មណ៍អំពីពន្លកនៃកំហឹងហើយវាកើតមានកាន់តែខ្លាំងនៅក្នុងរូបអ្នក។ មានតែការយល់ដឹងនិងសេចក្តីករុណាដែលអាចកាត់បន្ថយកំហឹង។

### សេចក្តីករុណាទាមទារភាពក្លាហាន

ជួនកាលយើងយល់ច្រឡំថាភាពឈ្លានពានកើតចេញពីភាពខ្លាំងហើយការមិនធ្វើសកម្មភាពកើតចេញពីភាពទន់ខ្សោយ។ ទ្រឹស្តីព្រះពុទ្ធបង្រៀនថាអ្វីដែលត្រូវគឺខ្លឹមសារច្រាសមកវិញទេ។

ការចុះញ៉មចំពោះឥទ្ធិពលនៃកំហឹងការអនុញ្ញាតឱ្យកំហឹងឈ្នះយើងគឺភាពទន់ខ្សោយ។ ម្យ៉ាងវិញទៀតគេត្រូវការភាពក្លាហានដើម្បីអាចទទួលស្គាល់ការភ័យខ្លាចនិងភាពកំណាញ់ដែលតាមធម្មតាគឺជាឫសគល់នៃកំហឹងរបស់យើង។គេត្រូវការវិន័យដើម្បីអាចធ្វើសមាធិនៅក្នុងអណ្តាតភ្លើងនៃកំហឹង។

ព្រះពុទ្ធមានដីកាថា "ពាររម្ងាប់ដោយការមិនចងពារ។ ផ្ចាញ់មារដោយអំពើល្អ។ ផ្ចាញ់ភាពកំណាញ់ដោយក្តីសប្បុរស។ ផ្ចាញ់មនុស្សកុហកដោយសេចក្តីទៀងត្រង់" (Dhammapada, v. 233)។

## ៣.២ តើយើងធ្វើបែបណាដើម្បីជំនះកំហឹង?

ជំហាននានាដូចតទៅនេះនឹងជួយអ្នកក្នុងការជំនះកំហឹងរបស់ខ្លួននៅពេលអ្នកស្ថិតនៅក្នុងពេលកំពុងបង្រៀន។

សូម្បីអ្នកពុំមានពេលដើម្បីគ្រប់គ្រងកំហឹងក៏ដោយយើងលើកទឹកចិត្តឱ្យអ្នកសាកល្បងជំហាននានាដូចខាងក្រោម។ អ្នកត្រូវការពេលមិនច្រើនជាង១ឬ២នាទីឡើយ។

១. ទទួលស្គាល់កំហឹងរបស់ខ្លួន។ ប្រាប់ខ្លួនឯងថា៖ "សិស្សនេះធ្វើឱ្យអញខឹង។"
២. ដើរទៅកបង្អួចនិងដកដង្ហើមយ៉ាងវែង។ ចូរបន្តដកដង្ហើមវែងៗពីរឬបីដង។ រៀងរាល់លើកចូរព្យាយាមដកដង្ហើមឱ្យបានកាន់តែវែង។ សម្លឹងតាមបង្អួចឬបិទភ្នែកមួយភ្លែត។
៣. រំខានការគិតរបស់ខ្លួនពីរឬបីនាទី។ ត្រូវចងចាំនូវបទពិសោធន៍ពីអតីតកាលដែលធ្វើឱ្យអ្នកមានអារម្មណ៍ល្អ។ ឬឧបមាថាអ្នកអង្គុយក្នុងយានអវកាសសម្លឹងមើលពីទីឆ្ងាយចុះមកផែនដី។ ឧបមាថាពីទីឆ្ងាយបញ្ហាដែលអ្នកជួបប្រទះឥឡូវនេះទំនងជាមានទំហំតូចនិងមិនសំខាន់។
៤. ធ្វើចលនាសាច់ដុំផ្ទៃមុខនិងព្យាយាមញញឹម។
៥. វិលមកថ្នាក់រៀនវិញ។ សម្លឹងមើលសិស្សដែលធ្វើឱ្យអ្នកខឹងជាមួយទឹកមុខមាំប៉ុន្តែមិននិយាយ។ នៅស្ងៀម៥វិនាទី។
៦. ក្នុងពេលអ្នកនៅស្ងៀមចូរព្យាយាមស្វែងរកមូលហេតុដែលអាចមានដែលធ្វើឱ្យសិស្សប្រព្រឹត្តមិនគប្បីឬដែលធ្វើឱ្យអ្នកខឹង។ តាមធម្មតាត្រូវតែមានមូលហេតុ។
៧. ដកខ្លួនចេញពីជម្លោះ។ ចូររក្សាភាពស្ងប់ស្ងៀម។ ប្រាប់ខ្លួនឯងថា "ចូររក្សាភាពស្ងប់ស្ងៀម"។ ចូរកុំបង្កគ្រោះថ្នាក់។
៨. ចូរគិតអំពីវិធានការឆ្លើយតបវិជ្ជមានសមស្រប និងអហិង្សា។

**ខាងក្រោមនេះជាគំនិតដទៃទៀតខ្លះៗដែលអ្នកអាចសាកល្បង៖**

- នៅពេលអ្នកខឹងសិស្សណាម្នាក់ត្រូវផ្តល់ឱ្យពួកគេនូវការបញ្ជាក់ច្បាស់ថាអ្នកកំពុងមិនពេញចិត្ត និងចង់ឱ្យមានការពិភាក្សាបញ្ហានេះនៅពេលក្រោយ។ ឧទាហរណ៍អ្នកអាចពោលជាមួយការរក្សាភាពកក់ក្តៅប៉ុន្តែជាមួយសំឡេងធ្ងន់ៗ៖ "ឫទ្ធិរឿងនេះធ្វើឱ្យខ្ញុំខឹង។ ខ្ញុំដឹងឯងមានហេតុផលរបស់ឯងដែលនាំឱ្យឯងប្រព្រឹត្តបែបនេះ។ ប៉ុន្តែខ្ញុំនឹងពិភាក្សាបញ្ហានេះជាមួយឯងនៅពេលក្រោយ។ សម្រាប់ពេលនេះយើងបន្តការរៀនសូត្ររបស់យើង។"
- ដើរចេញពីថ្នាក់រៀនរយៈពេល១ទៅ២នាទី (និងអនុវត្តតាមជំហានដូចអធិប្បាយខាងលើ)។

**អ្វីដែលអ្នកអាចធ្វើបាននៅក្រោយម៉ោងសិក្សា៖**

- ជួបជាមួយសហការី។ ចែករំលែកបទពិសោធន៍របស់ខ្លួន។ ចូរព្យាយាមស្វែងរកមូលហេតុដែលអាចមានដែលនាំឱ្យសិស្សប្រព្រឹត្តមិនគប្បីឬដែលធ្វើឱ្យអ្នកខឹង។ ចូរពិភាក្សាអំពីអ្វីដែលអាចជាវិធានការឆ្លើយតបវិជ្ជមានសមស្របអហិង្សា។
- ចូរធ្វើការឆ្លុះបញ្ចាំងសំណួរចំនួនពីរដូចតទៅ៖

១. តើខ្ញុំខឹងនឹងបានចំណេញអ្វី?

២. តើខ្ញុំខឹងនឹងបានផលអ្វី?

**អ្វីដែលអ្នកអាចធ្វើនៅក្រោយម៉ោងសិក្សា៖**

- ចេញដើរឬធ្វើលំហាត់ប្រាណខ្លះៗដើម្បីធ្វើឱ្យរាងកាយនិងអារម្មណ៍ស្ងប់
- សរសេរពីអារម្មណ៍របស់អ្នក។ ចូរអាននិងអានឡើងវិញជាច្រើនដងរហូតអ្នកអាចគិតអំពីបញ្ហានេះដោយស្ងៀមស្ងាត់
- ធ្វើសមាធិឬការបន្ធូរអារម្មណ៍។

**ត្រូវចងចាំ៖**ក្នុងពេលពិភាក្សាអំពីបញ្ហាកំហឹងចូរជៀសវាងពាក្យដូចជា "មិនដែល" ឬ "តែងតែ"។ចូរប្រើពាក្យ "ខ្ញុំ" នៅក្នុងស្ថានភាពព្រួយបារម្ភ។ជំនួសពាក្យ "ឯងធ្វើឱ្យខ្ញុំខឹង" ចូរពោលថា "ខ្ញុំមានអារម្មណ៍ខឹង"។ នេះជាវិធីមួយនៃការទទួលខុសត្រូវលើផ្លូវចិត្តនិងកំហឹងរបស់ខ្លួន។ ចូរកុំបង្គ្រោះថ្នាក់ចំពោះអ្នកដទៃដោយសារតែកំហឹងរបស់អ្នកឱ្យសោះ។

## ៣.៣ អ្វីដែលយើងនិយាយសុទ្ធតែនាំមកនូវផលវិបាក

- នៅពេលយើងខឹងឬចាប់ផ្តើមបាត់បង់ភាពអត់ធ្មត់យើងមានហានិភ័យក្នុងការពោលពាក្យមិនគប្បី៖
- ចេញបញ្ជា –"អង្គុយចុះភ្លាមហើយត្រូវនៅឱ្យស្ងៀម!"
- ហាមនិយាយ –"ឈប់ធ្វើអញ្ចឹងភ្លាម!"
- ប្រយោគប្រកបដោយកំហឹង –"ឯងមានរឿងធំជាងអ្វីដែលឯងដឹងទៅទៀត។"
- ប្រយោគទិទៀន –"តែប៉ុណ្ណឹងទេជាស្អីដែលឯងអាចធ្វើបានល្អបំផុតនោះ!"
- ប្រយោគយេនឌ័របទដ្ឋាន–"ឈប់និយាយ ក្មេងស្រីមិនគួរនិយាយលឺៗនោះទេ។"
- ប្រយោគគំរាម –"បើឯងមិនឈប់និយាយទេអញនឹងបញ្ជូនឯងទៅទីចាត់ការ។"
- ប្រយោគមាក់ងាយ –"ដល់អង្កាល់បានឯងអាចរៀនសរសេរឱ្យល្អជាងហ្នឹង?"

ចូរព្យាយាមជៀសវាងប្រយោគបែបនេះ!

### ប្រអប់សកម្មភាព៖ "កុំ" – តើរូបខ្ញុំអវិជ្ជមានកម្រិតណា?[២៦]

តាមធម្មតាមនុស្សយើងភាគច្រើនប្រើសេចក្តីបង្គាប់ "កុំ" ដល់សិស្សដែលនេះជាទម្រង់វិន័យអវិជ្ជមាន៖ "កុំជជែកក្នុងថ្នាក់" "កុំរត់ក្នុងថ្នាក់"។ យើងអាចពុំបានដឹងដោយខ្លួនឯងឡើយថាយើងចេញសេចក្តីបង្គាប់បែបនេះញឹកញាប់កម្រិតណាទេ។ ពាក្យទាំងនេះត្រូវបានស្តែងចេញមកដោយធម្មជាតិប៉ុន្តែសិស្សរបស់យើងដឹង។

- ដើម្បីឱ្យដឹងថាអ្នកប្រើពាក្យបង្គាប់ "កុំ" ញឹកញាប់កម្រិតណាចូរជ្រើសរើសសិស្សម្នាក់នៅក្នុងថ្នាក់រៀនរបស់អ្នក

២៦ សកម្មភាពនេះត្រូវបានដកស្រង់ចេញពី UNESCO, 2006, p. 13

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

(ឬសុំឱ្យគ្រូជំនួយចូលរួមសង្កេត) ហើយផ្តល់ឱ្យគាត់នូវប្រអប់មួយដែលមានគ្រាប់ក្រួសនិងក្រណាត់សំពត់ឬថង់ផ្លាស្ទិកមួយ។ ស្នើឱ្យសិស្សរូបនោះស្តាប់អ្នកពេញមួយសប្តាហ៍។ នៅពេលសិស្សឮអ្នកចេញបញ្ជា “កុំ” សុំឱ្យសិស្សនោះយកក្រួសមួយគ្រាប់ចេញពីប្រអប់និងដាក់ចូលទៅក្នុងថង់។ នៅចុងសប្តាហ៍ចូររាប់ចំនួនគ្រាប់ក្រួសនៅក្នុងថង់។ តើអ្នកភ្ញាក់ផ្អើលឬទេ ?

- ជំនួសឱ្យការចេញបញ្ជា”កុំ”ជាប្រចាំ (ទោះបីជួនកាលវាជាការចាំបាច់ក៏ដោយ) ចូររៀនកែប្រយោគទៅជាវិជ្ជមានទន្ទឹមនឹងពោលឱ្យបានច្បាស់អំពីអាកប្បកិរិយាដែលខ្លួនចង់ឃើញ។ ឧទាហរណ៍ជំនួសឱ្យការនិយាយថា “កុំរត់នៅក្នុងថ្នាក់រៀន” ចូរព្យាយាមនិយាយថា “ចូរដើរក្នុងថ្នាក់រៀន”។ ប្រយោគនេះបង្ហាញច្បាស់ថាតើអ្នកចង់ឱ្យសិស្សធ្វើសកម្មភាពបែបណា។ ជួនកាលអ្នកអាចចង់ផ្តល់មូលហេតុដែលនាំឱ្យមានបទបញ្ជាផ្ទៃក្នុងណាមួយជាពិសេសនៅពេលអ្នកពោលជាលើកដំបូងអំពីបទបញ្ជាផ្ទៃក្នុងនោះ។ ការពន្យល់អំពីបទបញ្ជាផ្ទៃក្នុងណាមួយអាចធ្វើបានបែបនេះ៖ “ចូរដើរនៅក្នុងថ្នាក់រៀន។ បើអ្នករត់អ្នកអាចជំពប់ជើងនឹងតុនិងធ្វើឱ្យរបួសហើយបន្ទាប់មកអ្នកអាចត្រូវទៅរកពេទ្យដើម្បីព្យាបាល។”



៤

# ការដាក់វិន័យបែបវិជ្ជមាន

## ៤.១ បង្រៀនសិស្សអំពីបំណិនជីវិត[២៧]



២៧ គំនូរត្លុកនេះត្រូវបានដកស្រង់ចេញពី Raising Voices, The Good School Toolkit, Cartoon Booklet, What is positive discipline?

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews


សាលារៀនរបស់យើងលើកទឹកចិត្ត
ស្វ័យវិន័យបែបវិជ្ជមានចំពោះ
សិស្សម្នាក់ៗ។
**យើងបង្រៀនសិស្សពីបំណិនជីវិត។**

1. ការគិតរួច សឹមគូរ
2. ការគិត និងរៀបចំផែនការ
   រយៈពេលយូរ
3. ការតស៊ូ
4. ទំនុកចិត្ត
5. ភាពអត់ធ្មត់
6. គំនិតច្នៃប្រឌិត
7. ភាពស្មោះត្រង់។



បំណិនជីវិតទាំងនេះជួយឱ្យយើងធ្វើ
ការសម្រេចចិត្តបានយ៉ាងល្អប្រសើរ
ដើម្បីជោគជ័យនៅក្នុងជីវិត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

*ហេតុអ្វីយើងបង្រៀនសិស្សរបស់យើងអំពីបំណិនជីវិត ?* យើងដឹងថាអ្នកដែលទទួលជោគជ័យមានចំណុចដូចគ្នាជាច្រើន។

ពួកគេមានគោលដៅច្បាស់លាស់



ពួកគេជឿជាក់លើខ្លួនឯង





ពួកគេខិតខំប្រឹងប្រែងធ្វើការ។



ពួកគេគិតអំពីមធ្យោបាយថ្មីក្នុងការដោះស្រាយបញ្ហាចាស់។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ពួកគេគជាបុគ្គលដែលមានភាពតស៊ូ។



នៅពេលដែលជំនាញទាំងអស់នេះបានរួមបញ្ចូលគ្នា បុគ្គលម្នាក់នោះនឹងមានវិន័យបែបវិជ្ជមាន។



## ៤.២ ហេតុអ្វីកុមារ"ប្រព្រឹត្តមិនគប្បី"?[២៨]

តាមធម្មតាកុមារប្រព្រឹត្តមិនគប្បីដោយសារតែហេតុផលណាមួយ។ ពួកគេអាចពុំដឹងអំពីមូលហេតុនោះទេប៉ុន្តែតាមធម្មតាមានមូលហេតុណាមួយជាកំណត់។

**តើអាកប្បកិរិយាមិនគប្បីជាអ្វី**? អាកប្បកិរិយាមិនគប្បីផ្សំដោយៈ

- ❖ អាកប្បកិរិយាមិនជាទីចង់បានដែលមិនស្របគ្នាជាមួយការរំពឹងទុករបស់យើងឬមិនស្របជាមួយវិន័យក្នុងថ្នាក់រៀន
- ❖ អាកប្បកិរិយាដែលបង្អាក់អន្តរកម្មវិជ្ជមានក្នុងសង្គមនិងរំខានចំពោះវិន័យផ្ទាល់ខ្លួនឬ
- ❖ អាកប្បកិរិយាដែលធ្វើឱ្យកុមារឬអ្នកដទៃទៀតស្ថិតក្នុងគ្រោះថ្នាក់។

**ប្រការសំខាន់គឺត្រូវកំណត់រកឫសគល់នៃតម្រូវការដើម្បីអាចយល់បានពីមូលហេតុដែលពួកគេប្រព្រឹត្តមិនគប្បី។**

ក្នុងករណីភាគច្រើនកុមារប្រព្រឹត្តមិនគប្បីដោយសារពួកគេមានតម្រូវការដែលមិនទាន់បំពេញបាន។

មានតម្រូវការបីបែបដែលនៅពុំទាន់បំពេញបានៈ

### តម្រូវការរាងកាយ

- ❖ ខ្ញុំឃ្លាន។
- ❖ ខ្ញុំហត់នឿយ។
- ❖ ខ្ញុំមានជំងឺ។
- ❖ ខ្ញុំមានអារម្មណ៍ក្តៅណាស់



### តម្រូវការស្មារតី

- ❖ ខ្ញុំមិនយល់
- ❖ មេរៀននេះងាយស្រួលពេក ឬ ពិបាកខ្លាំងពេក។
- ❖ ខ្ញុំមានអារម្មណ៍ថាមិនទាន់បានត្រៀមខ្លួននៅឡើយទេ។
- ❖ ខ្ញុំមួម៉ៅ ខកចិត្ត ព្រោះខ្ញុំមិនអាចធ្វើវាបាន។
- ❖ ខ្ញុំព្យាយាមហើយ ប៉ុន្តែខ្ញុំពុំមានជំនាញសមស្របសោះ
- ❖ វិធីសាស្រ្តរបស់គ្រូ មិនសមស្របសម្រាប់ខ្ញុំនោះឡើយ



### តម្រូវការផ្លូវចិត្ត

- ❖ ខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនមែនជាចំណែកមួយនៃគ្រួសារនោះទេ។
- ❖ ខ្ញុំមានអារម្មណ៍ថា ខ្ញុំត្រូវបានបដិសេធ
- ❖ ខ្ញុំមានអារម្មណ៍ថាគ្មានការគោរពចំពោះខ្ញុំទេ
- ❖ ខ្ញុំខឹង
- ❖ ខ្ញុំឈឺចាប់ណាស់
- ❖ ខ្ញុំចង់សងសឹក
- ❖ ខ្ញុំត្រូវការឱ្យមានការយកចិត្តទុកដាក់ចំពោះខ្ញុំ
- ❖ ខ្ញុំខ្លាចគ្រូរបស់ខ្ញុំ



២៨ ផ្នែកនេះត្រូវបានដកស្រង់ចេញពី Raising Voices, The Good School Toolkit,Module 3.5

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៤.៣ ការដាក់វិន័យបែបវិជ្ជមានៈជម្រើសជំនួសការដាក់ទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតី[២៩]

ការលំបាកដំបូងរបស់អ្នកជាគ្រូបង្រៀនគឺត្រូវស្វែងយល់ពីមូលហេតុដែលកុមារប្រព្រឹត្តមិនគប្បី ហើយបន្ទាប់មកធ្វើការសម្រេចថាតើអាកប្បកិរិយានោះសមនឹងទទួលការដាក់វិន័យដែរឬទេ។

ដូចដែលអ្នកបានសិក្សានៅក្នុងជំពូក៤.២អាកប្បកិរិយាមិនគប្បីកើតចេញពីកត្តានានានៅក្រៅការត្រួតត្រារបស់កុមារនិងផ្អែកលើតម្រូវការដែលពុំទាន់បំពេញបាន។ ឧទាហរណ៍កុមារប្រព្រឹត្តមិនសមរម្យដោយសារពួកគេស្រេកឃ្លានឿយហត់ឬមានអារម្មណ៍មួម៉ៅ។ ដូចដែលពន្យល់នៅក្នុងជំពូក២.៤ ទង្វើមិនគប្បីអាចជាប្រតិកម្មឬការខកចិត្តរបស់កុមារចំពោះបញ្ហានៅឯផ្ទះឬកន្លែងដទៃដែលនាំមកក្នុងថ្នាក់រៀន។

ក្នុងករណីទាំងនេះការដាក់វិន័យចំពោះសិស្សនឹងមិនអាចបំបាត់អាកប្បកិរិយាមិនគប្បីឡើយ។ ផ្ទុយទៅវិញអន្តរាគមន៍ដទៃទៀតនិងការគាំទ្រដល់សិស្សអាចត្រូវការឱ្យមានជាចាំបាច់ដូចជាការស្តាប់សិស្សនិងការផ្តល់សេចក្តីណែនាំ( សូមអានឡើងវិញ "វិធីបង្កើតទំនាក់ទំនងដែលមានប្រយោជន៍ជាមួយសិស្ស" ក្នុងជំពូក២.១ )។

សិស្សអាចត្រូវទទួលការដាក់វិន័យនៅពេលដែលពួកគេពាក់ព័ន្ធក្នុងអាកប្បកិរិយាមិនគប្បីណាមួយដូចខាងក្រោម។ **រាល់ចំណាត់ការក្នុងការដាក់វិន័យគួរតែប្រើប្រាស់វិធីអហិង្សា**!

### កម្រិត ១ – កំហុសតូចតាច

- ជជែក ស្រែកឡូឡា ញ៉ាំអាហារ ឬ បង្កការរំខានក្នុងថ្នាក់រៀន
- ការដាក់ឈ្មោះក្រៅឱ្យគ្រូ ឬ ការធ្វើត្រាប់តាមគ្រូ

### កម្រិត ២ – កំហុសស្រាល

- ប្រព្រឹត្តកំហុសកម្រិត ១ ជាច្រើនលើក
- មករៀនយឺតពេលជាប្រចាំ
- ពង្រាយសំរាមជាច្រើនលើក
- កុហក
- ប្រើប្រាស់ទ្រព្យសម្បត្តិសាលារៀនខុសគោលដៅ
- ការលួចតិចតួច
- ធ្វើបាប ឬឆាឆៅអ្នកដទៃ
- មិនធ្វើលំហាត់ដាក់ឱ្យធ្វើនៅផ្ទះ

### កម្រិត ៣ – កំហុសមធ្យម

- ប្រព្រឹត្តកំហុសកម្រិត ២ ជាច្រើនលើក
- មិនគោរពគ្រូ បុគ្គលិកសិក្សា នាយកសាលា ឬ បុគ្គលដទៃ
- លួច
- មានរបស់ហាមឃាត់ជាប់ខ្លួន
- ប្រើប្រាស់ភាសាមិនគប្បី
- បដិសេធការធ្វើលំហាត់
- គេចសាលា
- លួចចម្លងក្នុងពេលប្រឡង
- ចូលកន្លែងហាមឃាត់
- ចេញក្រៅសាលាដោយគ្មានការអនុញ្ញាតនៅក្នុងម៉ោងរៀន
- លេងល្បែងស៊ីសង

### កម្រិត ៤ – កំហុសធ្ងន់ធ្ងរ

- ប្រព្រឹត្តកំហុសកម្រិត ៣ ជាច្រើនលើក
- ប្រព្រឹត្តសកម្មភាពផ្លូវភេទ ក្នុងសាលារៀន ឬ ក្នុងពេលសិក្សា
- បំផ្លាញទ្រព្យសម្បត្តិសាលា
- សេពគ្រឿងញៀន
- វាយតប់មកលើគ្រូ បុគ្គលិកសិក្សា ឬ សិស្សដទៃទៀត
- បៀតបៀនផ្លូវភេទ
- ហិង្សា ឬការប្រទូសរ៉ាយខ្លាំង
- ការក្លែងបន្លំ
- មានអាវុធ ប្រព្រឹត្តអំពើហិង្សា ឬបទព្រហ្មទណ្ឌ
- ជំរិតយកប្រាក់ពីកុមារដទៃ

---

២៩ ជំពូកនេះត្រូវបានដកស្រង់ចេញពី Raising Voices, The Good School Toolkit, Step 4, p. 103-107

## អ្វីដែលគួរធ្វើ




ផ្ដោតសំខាន់លើការកែលម្អអាកប្បកិរិយា....




ផ្ដោតសំខាន់លើការជួយឱ្យកុមាររៀនសូត្រ....


youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## អ្វីដែលមិនគួរធ្វើ




...មិនធ្វើឱ្យសិស្សមានអារម្មណ៍អាម៉ាស់




...មិនឱ្យពួកគេទូទាត់សងនូវកំហុសរបស់ពួកគេ

ដើម្បីជម្រុញវិន័យបែបវិជ្ជមានវិធីដែលយើងប្រើប្រាស់ក្នុងការដាក់វិន័យត្រូវចែកចេញជាបួនកម្រិត។ ចំពោះសេចក្តីពិស្តារបន្ថែមអំពីការឆ្លើយតបនឹងវិន័យបែបវិជ្ជមានសូមយោងទៅ**ឧបសម្ព័ន្ធ ២**។

## ការឆ្លុះបញ្ចាំង

ចំពោះបញ្ហាតូចតាចប្រចាំថ្ងៃត្រូវជួយកុមារឱ្យគិតអំពីអាកប្បកិរិយារបស់ពួកគេ។

**ការព្រមានផ្ទាល់មាត់**




youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ការកំណត់ឱ្យនៅក្រៅថ្នាក់






**ការសរសេរលិខិត**




youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**ការសុំទោសផ្ទាល់មាត់**



ប្រអប់ដាក់វិន័យ




## ការដាក់វិន័យ

ចំពោះបញ្ហាដែលកើតមានជាប្រចាំត្រូវជួយសិស្សឱ្យយល់ពីផលវិបាក។

ការបង្ខំឱ្យធ្វើអ្វីមួយ
ទាល់តែរួច




youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

អ្នកអាចរកគំរូនៃកិច្ចសន្យាកែប្រែអាកប្បកិរិយានៅក្នុងឧបសម្ព័ន្ធទី ៤។




**ការជជែកពីវិន័យជាមួយសិស្ស**



## ការផ្តល់សំណង

ចំពោះហេតុការណ៍ដែលបង្កការខូចខាតត្រូវជួយកុមារឱ្យរ៉ាប់រងការទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេ។ ការសុំអភ័យទោសជាសាធារណៈនៅក្នុងថ្នាក់រៀន




**ការប្តូរ/ ការជួសជុល**




youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**ការពាក់ព័ន្ធពីឪពុកម្តាយ**



## ជម្រើសចុងក្រោយ

ចំពោះកំហុសធ្ងន់ធ្ងរបំផុតនិងជាច្រើនលើកត្រូវជួយស្តារនីតិសម្បទាសិស្ស។

**ការស្តីបន្ទោសជាផ្លូវការដោយនាយកសាលា**




youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**ការអញ្ជើញឪពុកម្តាយ**





# ៥ ការគ្រប់គ្រងថ្នាក់រៀនឱ្យមានប្រសិទ្ធភាព

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

## ៥.១ តើគ្រូបង្រៀនបែបណាដែលមានប្រសិទ្ធភាព ? [៣០]

**គ្រូដែលមានប្រសិទ្ធភាព៖**

- យល់ច្បាស់អំពីអ្វីដែលគាត់/នាងនឹងបង្រៀន
- គ្រោងទុកជាមុននិង
- ធានាថាសិស្សយល់ពីអ្វីដែលកំពុងបង្រៀន។

**ប្រអប់សកម្មភាព៖ ការឆ្លុះបញ្ចាំង - តើគ្រូបង្រៀនបែបណាដែលមានប្រសិទ្ធភាព ?**

- តើលក្ខណៈសម្បត្តិអ្វីខ្លះទៀតរបស់គ្រូដែលមានប្រសិទ្ធភាពដែលអ្នកអាចគិតឃើញ ?
- ចូរបំផុសគំនិតដោយខ្លួនឯងឬជាមួយសហការីរបស់អ្នកអំពីលក្ខណៈសម្បត្តិដទៃទៀតរបស់គ្រូដែលមានប្រសិទ្ធភាព។
- ចូរសរសេរគំនិតរបស់អ្នកនិងចាត់បញ្ចូលក្នុងតារាងអាទិភាពអំពីអ្វីដែលសំខាន់ចំពោះអ្នក។ចូរកត់ត្រាលក្ខណៈសម្បត្តិដែលមានសារសំខាន់បំផុតចំពោះអ្នក។

ក្នុងស្ថានភាពជាក់ស្តែងគ្រូដែលមានប្រសិទ្ធភាពប្រើប្រាស់ឧបករណ៍នានាដើម្បីជួយពួកគេនៅក្នុងការរៀបចំផែនការ។ នៅក្នុងជំពូកនេះអ្នកនឹងរៀនអំពីឧបករណ៍បែបនេះមួយ៖ **កិច្ចតែងការដ៏ល្អមួយ**។

កិច្ចតែងការដ៏ល្អមួយមានលក្ខណៈសម្បត្តិដូចតទៅ។ កិច្ចតែងការល្អ ...

- ចែងយ៉ាងច្បាស់និងជាក់លាក់អំពីអ្វីដែលនឹងត្រូវបង្រៀន
- ពន្យល់អំពីអ្វីដែលសិស្សត្រូវរៀន
- បញ្ជាក់ពីវិធីសាស្ត្រដែលគ្រូនឹងប្រើប្រាស់នៅក្នុងផ្នែកនីមួយៗនៃមេរៀន
- កំណត់មេរៀនទៅតាមពេលវេលា។

៣០ This chapter has been adapted from the Raising Voices, The Good School Toolkit, Step 3, Module 3.4

**ប្រអប់ផ្តល់យោបល់៖** គំរូនៃកិច្ចតែងការបង្រៀនដ៏ល្អមួយ

ឈ្មោះគ្រូ៖ ....................................................................................................

កាលបរិច្ឆេទ៖ ....................................................................................................

ថ្នាក់៖ ....................................................................................................

មុខវិជ្ជា៖....................................................................................................

រយៈពេល៖....................................................................................................

ចំនួនសិស្ស៖....................................................................................................

១. គោលបំណង៖

- ចំណេះដឹង
- ជំនាញ
- អាកប្បកិរិយា

២. ជំនួយក្នុងការបង្រៀន និងរៀនសូត្រ

- សម្រាប់គ្រូ
- សម្រាប់សិស្ស

៣. ដំណើរការបង្រៀន

| សកម្មភាពគ្រូបង្រៀន | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| ❖ គ្រូពិនិត្យមើលវត្តមាន<br>❖ គ្រូពិនិត្យមើលក្រចកដៃរបស់សិស្ស | **ជំហានទីមួយ** (៣ នាទី)<br>❖ អនាម័យ និងភាពស្អាត<br>❖ បង្កើនវិន័យក្នុងថ្នាក់រៀន | ❖ ប្រធានថ្នាក់រាយការណ៍ទៅគ្រូ<br>❖ សិស្សបង្ហាញដៃរបស់ពួកគេ |
| | **ជំហានទីពីរ** (២ នាទី)<br>❖ ពិនិត្យមើលកិច្ចការផ្ទះ<br>❖ រំលឹកមេរៀនចាស់ | ❖ សិស្សអនុវត្តលំហាត់<br>❖ សិស្សឆ្លើយសំណួរ |
| | **ជំហានទីបី** (២០ នាទី)<br>❖ មេរៀនថ្មី/វគ្គ | |
| | **ជំហានទីបួន** (១០ នាទី)<br>❖ រំលឹកមេរៀន<br>❖ ការសាកល្បង | |
| | **ជំហានទីប្រាំ** (៥ នាទី)<br>❖ កិច្ចការផ្ទះ | |

## ៩.២ តើចងក្រងបទបញ្ជាផ្ទៃក្នុងថ្នាក់រៀនជាមួយសិស្សដោយរបៀបណា?

ថ្នាក់រៀនទាំងអស់ត្រូវការបទបញ្ជាផ្ទៃក្នុងដើម្បីអាចដំណើរការប្រកបដោយប្រសិទ្ធភាព។ "បទបញ្ជា" ទាំងនេះត្រូវបានឱ្យឈ្មោះថា "បទបញ្ជាផ្ទៃក្នុងថ្នាក់រៀន" ឬ "ក្រមអនុវត្ត"

### ជាទូទៅការចងក្រងគោលការណ៍បែបនេះរួមមានដូចតទៅ៖

- ❖ អ្វីដែលសំខាន់បំផុត គឺជំរុញឱ្យសិស្សចូលរួមក្នុងការកំណត់របៀបដាក់វិន័យក្នុងថ្នាក់រៀន
- ❖ ត្រូវតែខ្លីនិងច្បាស់លាស់
- ❖ ដាក់តាំងបទបញ្ជាផ្ទៃក្នុងទាំងនេះនៅក្នុងថ្នាក់រៀនដើម្បីឱ្យឃើញទាំងអស់គ្នា
- ❖ ធានាថាទាំងសិស្សស្រី និងសិស្សប្រុសបានរួមចំណែកនៅក្នុងតារាងវិន័យ
- ❖ មិនត្រូវចងក្រងបទបញ្ជាផ្ទៃក្នុងថ្នាក់រៀនដែលអ្នកមិនអាចបានឬមិនអាចតាមដានជាប្រចាំបាននោះឡើយ
- ❖ ចងក្រងបញ្ជាផ្ទៃក្នុងដែលមានលក្ខណៈវិជ្ជមាន។ជំនួសឃ្លា "ហាមវាយគ្នា" សរសេរថា "ត្រូវគោរពគ្នាទៅវិញទៅមក"
- ❖ ជ្រើសយកបទបញ្ជាផ្ទៃក្នុងទាំងឡាយណាដែលអ្នកទាំងអស់គ្នានៅក្នុងថ្នាក់បានឯកភាពជាមួយគ្នា
- ❖ អ្នកនិងសិស្សរបស់អ្នកគួរចុះហត្ថលេខាលើគោលការណ៍ទាំងនេះ

**នៅទីនេះអ្នកអាចឃើញឧទាហរណ៍មួយ៖**

### គោលការណ៍ថ្នាក់រៀនរបស់យើង៖

**ក្នុងឋានៈជាសិស្ស ខ្ញុំត្រូវ៖**

- ❖ ព្យាយាមធ្វើកិច្ចការរបស់ខ្ញុំឱ្យបានល្អបំផុត
- ❖ មានចិត្តល្អនិងជួយមិត្តរួមថ្នាក់
- ❖ ចាត់ទុកកុមារី និងកុមារាទាំងអស់ដោយការគោរពស្មើគ្នា និងលើកទឹកចិត្តទាំងកុមារី និងកុមារាដើម្បីចូលរួមក្នុងថ្នាក់រៀន
- ❖ បង្ហាញពីការគោរពចំពោះគ្រូ
- ❖ គោរពបទបញ្ជាផ្ទៃក្នុងថ្នាក់រៀន
- ❖ មកសាលាដោយបានធ្វើកិច្ចការនៅផ្ទះនិងរៀបចំសម្ភារៈសិក្សារបស់ខ្ញុំ
- ❖ ចំណាយពេល១៥នាទីរៀងរាល់ថ្ងៃដើម្បីសិក្សាឬអាននៅឯផ្ទះ
- ❖ ជជែកជាមួយឪពុកម្ដាយជារៀងរាល់ថ្ងៃអំពីសកម្មភាពរបស់ខ្ញុំនៅសាលារៀន

**ក្នុងឋានៈជាគ្រូ ខ្ញុំត្រូវ៖**

- ❖ បង្ហាញពីការគោរពចំពោះសិស្សគ្រប់រូប
- ❖ លើកទឹកចិត្តការចូលរួមរបស់កុមារី និងកុមារានៅក្នុងសាលារៀនរបស់យើង
- ❖ ចាត់ទុកទាំងអ្នករួមការងារស្រី និងប្រុសដោយការគោរព
- ❖ រៀបចំកិច្ចតែងការ
- ❖ ផ្ដល់បរិយាកាសប្រកបដោយសុវត្ថិភាពដែលអំណោយផលសម្រាប់ការរៀនសូត្រ
- ❖ ជួយសិស្សគ្រប់រូបឱ្យលូតលាស់ទៅតាមសក្ដានុពលពេញលេញរបស់ខ្លួន
- ❖ ផ្ដល់សកម្មភាពដែលមានប្រយោជន៍និងសមស្របសម្រាប់កិច្ចការនៅផ្ទះ
- ❖ ពង្រឹងការគោរពបទបញ្ជាផ្ទៃក្នុងថ្នាក់រៀនឱ្យបានត្រឹមត្រូវនិងជាប្រចាំ
- ❖ ផ្ដល់ឱ្យសិស្សនិងឪពុកម្ដាយនូវការវាយតម្លៃបានច្បាស់លាស់អំពីការរីកចម្រើននិងលទ្ធផល
- ❖ ប្រើប្រាស់សកម្មភាពពិសេសនានាដើម្បីធ្វើឱ្យការរៀនសូត្រមានបរិយាកាសរីករាយ។
- ❖ ធ្វើជាគំរូដ៏ល្អ។

**ហត្ថលេខាគ្រូ** **ហត្ថលេខាសិស្ស**

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ប្រអប់យោបល់៖ កិច្ចតែងការសម្រាប់សរសេរបទបញ្ជាផ្ទៃក្នុងថ្នាក់រៀនជាមួយសិស្ស[៣១]

### គោលបំណង

- ស្វែងយល់ពីមូលហេតុដែលបទបញ្ជាផ្ទៃក្នុងដែលមានប្រយោជន៍និងចាំបាច់
- ផ្តល់ឱ្យសិស្សនូវឱកាសដើម្បីបង្កើតបទបញ្ជាផ្ទៃក្នុងថ្នាក់រៀនរបស់ខ្លួនឯងផ្ទាល់
- អនុវត្តការធ្វើសេចក្តីសម្រេចជាក្រុម

### ការរៀបចំ

- ក្តារខៀនដីស
- សៀវភៅលំហាត់
- ក្រដាសផ្ទាំងធំ

### ផ្នែកទី១ - ហេតុអ្វីយើងត្រូវការបទបញ្ជាផ្ទៃក្នុង

១. សុំឱ្យសិស្សពន្យល់ដល់អ្នកអំពីថាតើគេលេងល្បែងបាល់ទាត់ដោយរបៀបណា (ឬប្រើល្បែងផ្សេងទៀតដែលពួកគេអាចស្គាល់រួមជាមួយឧទាហរណ៍)។

២. ដើរក្នុងថ្នាក់រៀននិងសួរសិស្សថាតើអ្វីជាបទបញ្ជាផ្ទៃក្នុងសំខាន់ជាងគេនៃល្បែងនេះ។ចូរសរសេរលើក្តារខៀន។

៣. សួរសិស្សហេតុអ្វីអ្នកលេងបាល់ទាត់ត្រូវការបទបញ្ជាផ្ទៃក្នុងទាំងនេះ។ តើអ្វីអាចនឹងកើតឡើងប្រសិនបើពុំមានបទបញ្ជាផ្ទៃក្នុង? តើអ្នកលេងបាល់ទាត់ដឹងថាតើត្រូវធ្វើដូចម្តេចឬទេ? តើពួកគេលេងបានល្អឬទេ? តើពួកគេមានអារម្មណ៍មួម៉ៅនិងឈប់លេងឬទេ? ធ្វើបែបណាទើបដឹងថាអ្នកណាឈ្នះ?

៤. ចូរពន្យល់ថានៅក្នុងស្ថានភាពជាច្រើនគេត្រូវការបទបញ្ជាផ្ទៃក្នុងដើម្បីប្រតិបត្តិការ។ ចូរពន្យល់ថាស្ថានភាពនៅក្នុងថ្នាក់រៀនពុំខុសគ្នាពីស្ថានភាពក្នុងទីលានបាល់ទាត់ឡើយ។ យើងត្រូវមានបទបញ្ជាផ្ទៃក្នុងទើបសិស្សអាចរៀននិងប៉ិនប្រសប់ដូចក្រុមអ្នកលេងបាត់ទាត់! ស្នើឱ្យសិស្សគិតអំពីអ្វីដែលអាចកើតឡើងប្រសិនបើគ្មានបទបញ្ជាផ្ទៃក្នុងសម្រាប់ថ្នាក់រៀន។តើសិស្សមករៀនទាន់ពេលឬទេ? តើសិស្សទាំងអស់នឹងធ្វើកិច្ចការផ្ទះឬទេ? តើពួកគេគោរពគ្នាទៅវិញទៅមកឬទេ?

៥. បែងចែកទៅជាក្រុមតូចៗ។ ស្នើឱ្យក្រុមនីមួយៗបំផុសគំនិតជាមួយគ្នានិងបង្កើតបទបញ្ជាផ្ទៃក្នុងចំនួន១០ដែលពួកគេគិតថាជា បទបញ្ជាផ្ទៃក្នុងដែលល្អសម្រាប់ថ្នាក់រៀនរបស់ពួកគេ (ដូចជាគ្រប់គ្នាត្រូវមកសាលារៀនឱ្យទាន់ពេលគ្រប់គ្នាត្រូវស្តាប់ពេលដែលអ្នកណាម្នាក់កំពុងនិយាយអាចអនុញ្ញាតឱ្យមានសំណួរតែក្នុងករណីដែលអ្នកមិនយល់ប្រសិនបើអ្នកឯកភាពក្នុងការធ្វើអ្វីមួយអ្នកត្រូវធ្វើកិច្ចការនោះ មិនអនុញ្ញាតឱ្យមានការវាយតប់ឬការមាក់ងាយឡើយ)។ វាអាចជាបទបញ្ជាផ្ទៃក្នុងដែលពួកគេមានពីមុនឬជាវិន័យថ្មីដែលពួកគេគិតថាថ្នាក់រៀននេះគួរតែមាន។ ស្នើឱ្យសិស្សណាម្នាក់ក្នុងក្រុមនីមួយៗសរសេរវិន័យទាំងនោះក្នុងសៀវភៅលំហាត់របស់ពួកគេ។ រយៈពេល១០-១៥នាទីក្រោយមកស្នើសិស្សទាំងនោះឱ្យមកជួបជុំគ្នាវិញ។

៦. ស្នើក្រុមនីមួយៗឱ្យបង្ហាញបទបញ្ជាផ្ទៃក្នុងរបស់ក្រុមខ្លួន។ នៅពេលដែលពួកគេអានបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនត្រូវសរសេរនៅលើក្តារខៀន។ ប្រសិនបើបទបញ្ជាផ្ទៃក្នុងដដែលៗត្រូវបានលើកឡើងត្រូវសរសេរតែម្តងប៉ុណ្ណោះ ប៉ុន្តែត្រូវដាក់សញ្ញាផ្កាយជាសម្គាល់នៅជិតបទបញ្ជាផ្ទៃក្នុងណាមួយនោះរៀងរាល់ពេលដែលមានការកត់សម្គាល់ឡើងវិញ។ នៅក្រោយពេលដែលបទបញ្ជាផ្ទៃក្នុងទាំងអស់ត្រូវបានកត់ត្រាលើក្តារខៀន

៣១ កិច្ចតែងការនេះត្រូវបានដកស្រង់ចេញពី Raising Voices, The Good School toolkit, Step 4, p. 90-91

រួចហើយត្រូវរួមបញ្ចូលគ្នានូវគោលការណ៍ដែលស្រដៀងគ្នាដើម្បីបង្កើតជាគោលការណ៍តែមួយ។

៧. គោលគំនិតគឺបង្កើតបទបញ្ជាផ្ទៃក្នុងមួយចំនួនតូចប៉ុណ្ណោះដែលងាយស្រួលអនុវត្ត។ ចូរព្យាយាមរួមបញ្ចូលបទបញ្ជាផ្ទៃក្នុងទាំងនេះឱ្យមានត្រឹម១០-១២ចំណុចតែប៉ុណ្ណោះ។

៨. ក្នុងករណីជាច្រើនគ្រប់បទបញ្ជាផ្ទៃក្នុងដែលគ្រូចង់បាននឹងមាននៅក្នុងតារាងនេះ។ ប៉ុន្តែប្រសិនបើពុំដូច្នោះទេចូរដឹកនាំការពិភាក្សាដើម្បីសួរអំពីបទបញ្ជាផ្ទៃក្នុងខ្លះដែលអ្នកគិតថានៅខ្វះ។ ចូរព្យាយាមធ្វើឱ្យសិស្សជាអ្នកស្នើគំនិតនោះឡើង។

៩. ចូររក្សាពាក្យដែលមានការគោរពនិងបទបញ្ជាផ្ទៃក្នុងវិជ្ជមាន។ ជំនួស "ហាមរំខានគ្រូ" ចូរសរសេរ "លើកដៃដើម្បីសុំការអនុញ្ញាតឡើងនិយាយ"។ ជំនួស "ហាមលួច" ចូរសរសេរ "គោរពទ្រព្យរបស់អ្នកដទៃ"។

**ផ្នែកទី២ - ការប្តេជ្ញាគោរពបទបញ្ជាផ្ទៃក្នុង**

១. ក្រោយម៉ោងរៀនបានបញ្ចប់ចូរសរសេរបទបញ្ជាផ្ទៃក្នុងថ្មីលើក្រដាសផ្ទាំងធំឬក្រដាសកាតុងនិងបង្កើតជាផ្ទាំងព័ត៌មាន។ នៅថ្ងៃបន្ទាប់ស្នើឱ្យសិស្សគ្រប់គ្នាចុះហត្ថលេខានៅលើផ្ទាំងព័ត៌មាននោះដោយពន្យល់ថា ហត្ថលេខារបស់ពួកគេមានន័យថាពួកគេប្តេជ្ញាគោរពបទបញ្ជាផ្ទៃក្នុងទាំងនោះ។

២. ស្នើឱ្យសិស្សចម្លងបទបញ្ជាផ្ទៃក្នុងទាំងនោះដាក់នៅលើផ្ទៃខាងក្នុងនៃក្របសៀវភៅលំហាត់របស់ពួកគេដើម្បីពួកគេអាចចងចាំជាប់ជានិច្ចនូវបទបញ្ជាផ្ទៃក្នុងដែលពួកគេបានឯកភាព។

៣. នៅថ្ងៃណាដែលថ្នាក់រៀនមាន "សំណាងមិនល្អ" ឬសិស្សមិនគោរពបានតាមវិន័យណាមួយចូររម្លឹកពួកគេអំពីបទបញ្ជាផ្ទៃក្នុងទាំងនោះនិងអំពីហត្ថលេខារបស់ពួកគេ។ ប្រសិនបើចាំបាច់ចូរចំណាយពេលខ្លះដើម្បីពិនិត្យឡើងវិញនូវបទបញ្ជាផ្ទៃក្នុងនានានិងពិភាក្សាពីមូលហេតុដែលពួកគេសរសេរវិន័យទាំងនោះ។

**ប្រអប់យោបល់ក្នុងថ្នាក់រៀន**

**ជារឿយៗ សិស្សមានហេតុការណ៍ត្រូវរាយការណ៍ ឬគំនិតត្រូវកែលម្អ៖**

- ដាក់ប្រអប់ក្នុងថ្នាក់រៀន ហើយបិទស្លាកលើប្រអប់នោះ "ប្រអប់យោបល់"។
- ពន្យល់ប្រាប់សិស្សថាពួកគេអាចប្រើប្រអប់នេះដើម្បីប្រគល់ការផ្តល់មតិយោបល់អនាមិក មិនថាហេតុការណ៍នៃបញ្ហា ឬរបៀបកែលម្អថ្នាក់រៀន និងថ្នាក់។
- ពិនិត្យមើលប្រអប់ឱ្យបានទៀងទាត់។
- យកចិត្តទុកដាក់លើការស្នើសុំរបស់សិស្សឱ្យបានល្អ និងចេញជាសកម្មភាព។
- ប្រាប់សិស្សអំពីសកម្មភាពដែលត្រូវអនុវត្តផ្អែកលើការស្នើសុំ។ សកម្មភាពទាំងនេះជួយឱ្យសិស្សទទួលបានអារម្មណ៍ថាទទួលបានការគោរព និងផ្តល់អំណាច។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៥.៣ ការលើកទឹកចិត្តឱ្យមានអាកប្បកិរិយាល្អ

ស្នូលនៃវិន័យបែបវិជ្ជមានក្នុងថ្នាក់រៀនគឺត្រូវពិនិត្យមើលសិស្សដែលធ្វើត្រូវនិងត្រូវលើកសរសើរពួកគេភ្លាមៗ។

ការពង្រឹងអាកប្បកិរិយាវិជ្ជមាននិងការលើកទឹកចិត្តមានសារសំខាន់ណាស់សម្រាប់សិស្ស។វាជំរុញទឹកចិត្តឱ្យពួកគេរៀនសូត្រ។

**ខាងក្រោមនេះជាបទបញ្ញត្តិក្នុងខ្លះៗ៖**

- **ផ្ដល់ការសរសើរចំពោះអាកប្បកិរិយាល្អតែមិនមែនកិច្ចការល្អទេ**
  **ឧទាហរណ៍៖** ជំនួសការនិយាយ *"អរគុណចំពោះការមិននិយាយ"* ចូរពោលថា *"ពួកអ្នកធ្វើបានល្អណាស់ក្នុងការគោរពអ្នកដទៃដោយរក្សាភាពស្ងប់ស្ងៀម"*។

- **ផ្ដល់ការលើកទឹកចិត្តចំពោះកុមារី និងកុមារាដោយស្មើភាពគ្នា និងសម្រាប់រឿងដូចគ្នា**
  នៅពេលខ្លះយើងមានការរំពឹងទុកផ្សេងៗគ្នាសម្រាប់កុមារី និងកុមារា នៅក្នុងថ្នាក់រៀន។ ឧទាហរណ៍៖ នៅពេលក្មេងប្រុសនិយាយដើម្បីឆ្លើយសំណួរមួយបានត្រឹមត្រូវ យើងតែងតែសរសើគាត់។ ទោះជាយ៉ាងណាក៏ដោយ យើងអាចនិយាយប្រាប់ក្មេងស្រីថានាអាចនឹងនិយាយលឺសម្រាប់អាកប្បកិរិយាដូចគ្នា។

- **ផ្ដោតលើអ្វីដែលសិស្សកំពុងធ្វើបានត្រឹមត្រូវជាងអ្វីដែលពួកគេធ្វើមិនត្រឹមត្រូវ**
  **ឧទាហរណ៍៖** "ល្អណាស់ដែលឯងបានស្លៀកពាក់ឯកសណ្ឋានមកសាលារៀនក្នុងថ្ងៃនេះ! សម្រាប់ថ្ងៃស្អែកសូមចាំថាត្រូវបោកគក់វាឱ្យបានស្អាតផងដែរ។"

- **ចូរព្យាយាមជៀសវាងការប្រៀបធៀបសិស្សណាម្នាក់ជាមួយសិស្សដទៃទៀត**
  តាមធម្មតាការធ្វើបែបនេះនាំឱ្យពួកគេមានអារម្មណ៍មិនល្អ។

- **ចូរលើកទឹកចិត្តឱ្យមានកិច្ចប្រឹងប្រែងពោលគឺមិនត្រឹមតែជោគជ័យនិងឧត្តមភាពប៉ុណ្ណោះទេ។**

**ប្រអប់យោបល់៖តម្រុយសម្រាប់ការលើកសរសើរចំពោះអាកប្បកិរិយាកិច្ចប្រឹងប្រែងនិងជោគជ័យ**

ចូរប្រើខ្សែភ្នែកការងក់ក្បាលញញឹមការទះស្មាសំដីសរសើរដូចជា "ល្អណាស់!" ឬ"ធ្វើការបានល្អ!"ការចំណាយពេលបន្ថែមត្រឹម៥នាទីនៅចុងម៉ោងក្នុងថ្ងៃនីមួយៗ ការលើកសរសើរបន្ថែមការលើកសរសើរកិច្ចប្រឹងប្រែងនៅចំពោះមុខសិស្សដទៃក្នុងថ្នាក់រៀន។នៅពេលលើកសរសើរគួរតែធ្វើភ្លាមៗការលើកទឹកចិត្ត តិចតួចប៉ុន្តែធ្វើឱ្យសប្បាយចិត្ត។

### ប្រអប់សកម្មភាព៖ការលើកសរសើរចំពោះអាកប្បកិរិយាល្អ [៣២]

- ❖ សូមអានប្រយោគដូចតទៅនិងឆ្លុះបញ្ចាំងពីរឬបីនាទីអំពីខ្លឹមសារនៃប្រយោគនោះ
- ❖ គិតអំពីថាតើអាចកែប្រែប្រយោគទាំងនេះពីអវិជ្ជមានទៅជាវិជ្ជមាននិងជាការលើកទឹកចិត្តដែរឬទេ
- ❖ ចូរសរសេរប្រយោគទាំងនោះជាខ្លឹមសារវិជ្ជមាន។

**ឧទាហរណ៍៖** សិស្សម្នាក់នៅក្នុងថ្នាក់រៀនរបស់អ្នកស្លៀកពាក់បានស្អាតបាត។ អ្នកចង់លើកសរសើរគាត់ដូច្នេះអ្នកពោលថា "ឯងស្លៀកពាក់បានស្អាតបាតណាស់ថ្ងៃនេះ។មិត្តភក្តិក្នុងថ្នាក់រៀនអាចរៀនសូត្រគំរូល្អនេះពីឯងដោយសារពួកគេមិនរៀបរយសោះ"។

**ប្រយោគវិជ្ជមានដែលអាចប្រើការបាន៖** "ឯងស្លៀកពាក់បានស្អាតបាតណាស់ថ្ងៃនេះ! ឯងធ្វើបានល្អណាស់!"

ជៀសវាងការប្រៀបធៀបក្នុងចំណោមសិស្សានុសិស្ស ជាពិសេសនៅពេលដែលការប្រៀបធៀបនេះបង្ហាញថា អ្នកដែលមានយេនឌ័រមួយ ល្អជាងអ្នកដែលមានយេនឌ័រផ្សេងទៀត។ ការប្រៀបធៀបធ្វើឱ្យសិស្សអាក់អន់ស្រពន់ចិត្ត និងជាការបំបាក់ទឹកចិត្តពួកគេ។

| ល.រ | ប្រយោគ | ចម្លើយវិជ្ជមានរបស់អ្នក |
|---|---|---|
| ១ | កុមារម្នាក់ពុំដែលស្លៀកពាក់ឯកសណ្ឋានមកសាលារៀនឡើយលើកលែងតែថ្ងៃនេះ។ អ្នកពោលថា "ឯកសណ្ឋានរបស់ឯងកខ្វក់ណាស់! តើមានអ្វីកើតឡើងចំពោះឯង ?" | |
| ២ | សិស្សម្នាក់កំពុងរៀនយ៉ាងសកម្មដើម្បីសរសេរភាសាអង់គ្លេសឱ្យបានល្អប៉ុន្តែនៅតែបន្តសរសេរខុស។អ្នកពោលថា "ខ្ញុំគិតថាឯងមិនពូកែភាសាអង់គ្លេសទេ។ បើឯងមិនអាចកែលម្អបានទេនៅសប្តាហ៍ក្រោយឯងនឹងត្រូវធ្លាក់មុខវិជ្ជានេះ" | |
| ៣ | សិស្សម្នាក់បង្កការរំខានជាខ្លាំងនៅក្នុងថ្នាក់រៀនហើយកំពុងជជែកយ៉ាងច្រើន។ អ្នកធុញទ្រាន់ចំពោះសិស្សនេះនិងពោលថា៖ "ឈប់ជជែកភ្លាម! បើឯងមិនឈប់និយាយឯងនឹងទទួលផលមិនល្អឡើយ!" | |
| ៤ | កុមារម្នាក់រត់ក្នុងទីធ្លាសាលារៀនហើយអ្នកបារម្ភថាគាត់នឹងមានរបួស។ គាត់ក៏រំលោភលើវិន័យផងដែរ។ អ្នកពោលថា "ឈប់រត់ឥឡូវនេះភ្លាមបើពុំនោះទេឯងនឹងទទួលទណ្ឌកម្ម!" | |
| ៥ | កុមារម្នាក់មករៀនយឺតពេលជាលើកទីបីក្នុងសប្តាហ៍នេះ។ អ្នកធ្វើមិនដឹងចំពោះភាពយឺតយ៉ាវរបស់នាងកន្លងមកប៉ុន្តែអ្នកចាប់អារម្មណ៍ថាអ្នកត្រូវនិយាយអ្វីម៉្យាង។ អ្នកពោលថា"នេះជាលើកទីបីហើយដែលឯងមករៀនយឺតពេលក្នុងសប្តាហ៍នេះ! តើឯងមានរឿងអ្វី ?" | |
| ៦ | អាកាសខាងក្រៅក្តៅខ្លាំងណាស់ហើយកុមារម្នាក់ខ្ជះខ្ជាយទឹកដោយទុកឱ្យទឹកហូរចោលក្នុងពេលដាក់ក្បាលនៅពីក្រោមទឹករ៉ូប៊ីនេដើម្បីឱ្យត្រជាក់។អ្នកពោលថា៖ "តើឯងមានរឿងអី ? ឯងកំពុងខ្ជះខ្ជាយទឹក!! ឯងចង់ដឹងថាអារម្មណ៍ក្តៅនោះមានបែបណាទេ ? ឯងត្រូវចេញទៅឈរនៅកណ្តាលថ្ងៃរហូតដល់ពេលដែលខ្ញុំអាចឱ្យឯងចូលមកក្នុងវិញ!" | |
| | ក្មេងប្រុស បាននឹងកំពុងលេងជន្លក្មេងស្រីនៅក្នុងសាលារៀនរបស់គេដោយរត់ដេញតាមនិងលាត់សំពត់របស់ពួកនាង។ អ្នកអាចនិយាយថា ស្តាប់ណាក្មេងខិល ខ្ញុំនឹងឱ្យឯងស្លៀកសំពត់ និងរៀបឬកដូចជាក្មេងស្រីដើម្បីជាមេរៀនដល់ឯង។ | |

អ្នកអាចរកឃើញចម្លើយវិជ្ជមាននិងដែលផ្តល់ការលើកទឹកចិត្តសម្រាប់ប្រយោគនីមួយៗនៅក្នុងឧបសម្ព័ន្ធ៤។

៣២ សកម្មភាពនេះត្រូវបានដកស្រង់ចេញពីRaising Voices, The Good School toolkit, Step 4, Modul 4.7

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៥.៤ របៀបធ្វើការជាមួយសិស្សដែលមានៈ

### ការឆ្លើយតបបែបច្នៃប្រឌិតចំពោះបញ្ហាអាកប្បកិរិយា

អ្នកប្រហែលជាបានស្គាល់នូវឥរិយាបថដូចខាងក្រោមៈ

- សិស្សមិនស្ដាប់
- សិស្សពីរនាក់វាយតប់គ្នា
- សិស្សមករៀនយឺតជាប្រចាំ

ត្រូវលើកទឹកចិត្តខ្លួនឯងតាមរយៈការឆ្លើយតបអហិង្សាបែបច្នៃប្រឌិតនិងតាមរបៀបផ្សេងមួយចំនួនដែលគ្រូនានានៅកម្ពុជាបានប្រើប្រាស់រួចមកហើយ។



## ការយកចិត្តទុកដាក់៖ តើត្រូវធ្វើបែបណា?[៣៣]

សិស្សដែលមានសុខភាពល្អទាំងអស់ត្រូវការឱ្យមានការយកចិត្តទុកដាក់។ សិស្សទាំងអស់ចូលចិត្តឱ្យមានការយកចិត្តទុកដាក់វិជ្ជមាន។ តាមធម្មតាពួកគេប្រឹងប្រែងជាខ្លាំងដើម្បីទទួលបានការយកចិត្តទុកដាក់។ ទោះជាយ៉ាងណាក៏ដោយប្រសិនបើកុមារមិនទទួលបានការយកចិត្តទុកដាក់ជាវិជ្ជមានទេនោះពួកគេនឹងព្យាយាមទទួលបានការយកចិត្តទុកដាក់តាមវិធីដែលពួកគេអាចធ្វើបានសូម្បីជាវិធីអវិជ្ជមានក៏ដោយ។ជាក់ស្តែងអ្វីដែលយើងបានឃើញជាញឹកញាប់ជា "អាកប្បកិរិយាមិនគប្បី" គឺគ្រាន់តែជាសម្រែកទាមទារការយកចិត្តទុកដាក់ប៉ុណ្ណោះ៖ "ណែ! សូមកត់សម្គាល់អំពីខ្ញុំ! ខ្ញុំនៅទីនេះហើយខ្ញុំសំខាន់ណាស់!"

| អាកប្បកិរិយា | មូលហេតុ | ដាក់វិន័យតាមបែបវិជ្ជមានចំពោះសិស្សដែលស្វែងរកការយកចិត្តទុកដាក់ |
|---|---|---|
| **លឹមហួរ**ប្រព្រឹត្តមិនគប្បីស្ទើរតែគ្រប់ពេលនៅក្នុងថ្នាក់រៀននៅក្នុងថ្ងៃភាគច្រើនប្រចាំសប្តាហ៍។ គាត់គប់ក្រដាសទៅសិស្សដទៃគាត់ជជែកជាមួយមិត្តរួមថ្នាក់ដោយគ្មានការអនុញ្ញាតរំខានថ្នាក់រៀននិងសើចខ្លាំងៗនៅក្នុងពេលមិនសមស្រប។ គាត់មានបញ្ហាដោយអង្គុយមិនស្ងៀម។ គាត់ជាតួត្លុកនៅក្នុងថ្នាក់រៀន។ | **លឹមហួរ**ជាសិស្សម្នាក់ក្នុងចំណោមអ្នកដែលប្រកាន់អាកប្បកិរិយាមិនគប្បីដើម្បីទាក់ទាញការយកចិត្តទុកដាក់បន្ថែមពីគ្រូ។ | ❖ លើកសរសើរគាត់នៅពេលគាត់មិនទាក់ទាញការចាប់អារម្មណ៍និងមិនប្រព្រឹត្តមិនគប្បី<br>❖ ករណីអាចធ្វើបានធ្វើមិនដឹងមិនឮ<br>❖ សម្លឹងសិស្សរូបនោះតែមិនចេញស្តី<br>❖ ឈរជិតឱ្យបានច្រើន<br>❖ ផ្តោតលើសិស្សតាមឈ្មោះកំណត់អាកប្បកិរិយាដែលត្រូវបញ្ឈប់ប្រាប់សិស្សអំពីអ្វីដែលជាការរំពឹងចង់ឱ្យគាត់ធ្វើនៅក្នុងពេលនោះទុកឱ្យគាត់ធ្វើការសម្រេចចិត្តអំពីអ្វីគាត់ចង់ធ្វើបន្ទាប់ពីនេះនិងផលវិបាកដែលគាត់ត្រូវទទួល<br>❖ ធ្វើអ្វីដែលគ្មានការរំពឹងទុកដូចជាបិទភ្លើងចាក់ភ្លេងនិយាយកាន់តែខ្សោយប្តូរសំឡេងនិយាយទៅកាន់ជញ្ជាំង<br>❖ បំបែរអារម្មណ៍សិស្សដូចជាលើកសំណួរផ្ទាល់ស្នើឱ្យធ្វើអ្វីម៉្យាងផ្តល់ជម្រើសប្តូរសកម្មភាព។ |

**សូមចងចាំ៖** បទបញ្ជាផ្ទៃក្នុងជាទូទៅសម្រាប់ការឆ្លើយតបចំពោះសិស្សដែលស្វែងរកការយកចិត្តទុកដាក់គឺ៖ជៀសវាងការយកចិត្តទុកដាក់តាមតម្រូវការសូម្បីសម្រាប់អាកប្បកិរិយាដែលមានប្រយោជន៍ក៏ដោយ។ ត្រូវជួយសិស្សឱ្យមានការលើកទឹកចិត្តដោយខ្លួនឯង។ ចូរផ្តល់ការយកចិត្តទុកដាក់តាមវិធីដែលពួកគេគ្មានការរំពឹងទុក។ យកចិត្តទុកដាក់ចំពោះពួកគេនៅពេលពួកគេធ្វើ "ត្រឹមត្រូវ"។

៣៣ ជំពូករងនេះត្រូវបានដកស្រង់ចេញពី UNESCO, 2006, p. 40-41

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ការស្វែងរកឥទ្ធិពលៈតើត្រូវធ្វើបែបណា ?[៣៤]

ការឆ្លើយតបតាមធម្មជាតិរបស់យើងនៅក្នុងពេលប្រទាញប្រទង់ដើម្បីអំណាចគឺធ្វើឱ្យមានអារម្មណ៍បង្កហេតុនិងឱ្យខឹង។ ការប៉ុនប៉ងគឺត្រូវបញ្ឈប់ការប្រទាញប្រទង់គ្នានេះនៅក្នុងពេលជាមួយគ្នាតាមរយៈការប្រើប្រាស់ទម្រង់ខ្លះៗនៃទណ្ឌកម្មលើរាងកាយនិងផ្នែកស្មារតីប៉ុន្តែការធ្វើដូចនេះនឹងផ្តល់នូវការពន្យាពេលដ៏ខ្លីប៉ុណ្ណោះ។

| អាកប្បកិរិយា | មូលហេតុ | ដាក់វិន័យតាមបែបវិជ្ជមានចំពោះសិស្សបែបនេះ |
|---|---|---|
| **គន្ធា** តែងតែមានពាក្យចុងក្រោយ។ នាងមករៀនយឺតពេល។ នាងតែងព្យាយាមយកឈ្នះនិងមានការអត់ឱននិងភាពអត់ធ្មត់តិចតួចបំផុតចំពោះអ្នកដទៃ។ នៅពេលគ្រូកំពុងពន្យល់ប្រធានបទថ្មីគាត់រំខានគ្រូតាមវិធីបង្ករឿងនិងបែបឈ្លានពាន។ | **គន្ធា** ព្យាយាមចង់ដឹងថាខ្លួនមានឥទ្ធិពលប៉ុណ្ណា។ គន្ធាជាសិស្សស្វែងរកឥទ្ធិពល។ នាងមាន<br><br>អារម្មណ៍ថានាងសំខាន់តែកាលណានាងប្រជែងនឹងអំណាចរបស់គ្រូប៉ុណ្ណោះ។ | ❖ ដកខ្លួនចេញពីទំនាស់<br>❖ កុំមានអារម្មណ៍ធ្លាក់ចូលក្នុងការបង្ករឿងនិងកុំខឹង<br>❖ ធ្វើចិត្តឱ្យល្អប៉ុន្តែម៉ឺងម៉ាត់<br>❖ រក្សាភាពស្ងប់ស្ងាត់<br>❖ ផ្តល់ជម្រើស<br>❖ ដាក់សិស្សនៅក្នុងស្ថានភាពនៃការទទួលខុសត្រូវនិងផ្តល់ឱ្យគាត់នូវអំណាចស្របច្បាប់ដូចជា "មិនអីទេអ្នកមិនចាំបាច់មករៀនទាន់ម៉ោងឡើយ។ ខ្ញុំ យល់។ ប៉ុន្តែតើអ្នកជួយខ្ញុំបានទេដោយចូលក្នុងថ្នាក់នៅពេលដែលសិស្សនានាមកដល់ ?" |

**ត្រូវចងចាំៈ** ដើម្បីឈ្លោះគ្នាត្រូវមានមនុស្សពីរនាក់។ ចូររក្សាភាពស្ងប់ស្ងៀមផ្តល់ជម្រើសនិងទុកឱ្យផលវិបាកនៃអាកប្បកិរិយារបស់សិស្សកើតឡើងទៅចុះ។ អ្នកអាចបានទទួលកិច្ចសហការពីពួកគេដោយកត់ត្រាអំពីការជួយរបស់ពួកគេ។ ជំនួសឱ្យការស្វែងរកអំណាចលប់ដើម្បីរូបអ្នកចូរដាក់សិស្សនៅក្នុងស្ថានភាពមួយនៃការទទួលខុសត្រូវនិងផ្តល់ឱ្យគាត់នូវអំណាចស្របច្បាប់។

---

៣៤ ជំពូករងនេះត្រូវបានដកស្រង់ចេញពីUNESCO, 2006, p. 42

## ការបញ្ចៀសបរាជ័យៈ តើធ្វើបែបណា?[៣៩]

សិស្សខ្លះខ្លាចភាពបរាជ័យឬមានអារម្មណ៍ថាពួកគេពុំមានលក្ខណៈគ្រប់គ្រាន់និងមិនអាចប្រឈមនឹងការរំពឹងទុករបស់ខ្លួនឯង ឪពុកម្តាយឬរបស់ខ្លួនឡើយ។ សិស្សណាម្នាក់ដែលមានអារម្មណ៍ថាល្ងង់នឹងមិនប្រឹងប្រែងរៀនសូត្រឱ្យបានល្អនៅក្នុងថ្នាក់ឡើយ។ ដើម្បីទូទាត់ចំពោះអារម្មណ៍ មិនគ្រប់គ្រាន់របស់ពួកគេពួកគេអាចជ្រើសយកការប្រព្រឹត្តតាមវិធីនានាដែលបង្ហាញថាពួកគេមិនគ្រប់គ្រាន់៖ "ខ្ញុំគ្រាន់តែមិនអាចធ្វើចំណោទទាំងនេះប៉ុណ្ណោះ។""ខ្ញុំមិនពូកែខាងវិទ្យាសាស្ត្រទេ។""សៀវភៅនេះលំបាកអានណាស់សម្រាប់ខ្ញុំ។" នេះមិនមានន័យថាពួកគេពុំមានលក្ខណៈគ្រប់គ្រាន់នោះឡើយ។

វិធីនៃការដាក់វិន័យបែបអវិជ្ជមានដូចជាចំអកឬបញ្ឈឺ ("តើឯងមិនអាចធ្វើបានល្អជាងនេះទេឬអី?" "ហេតុអ្វីបានជាឯងមិនដឹងចម្លើយ?") ធ្វើឱ្យសិស្សទាំងនេះមានអារម្មណ៍កាន់តែខ្លាំងថាខ្លួនមិនបានការ។

សិស្សដែលមានអារម្មណ៍ថាខ្លួនគ្មានសមត្ថភាពឬគ្មានការនិយមអាចលើកតំកើងអួតឬវាយតប់គ្នា។ ជួនកាលពួកគេអាចប្រែក្លាយជាអ្នករករឿងឈ្លោះនៅក្នុងការប៉ុនប៉ងធ្វើឱ្យសិស្សដទៃខ្លាចនិងគ្មានសមត្ថភាពផងដែរ។ ពួកគេអាចបាត់បង់ចំណាប់អារម្មណ៍លើសាលារៀនគេចសាលានិងអាចបោះបង់ចោលការសិក្សានិងសាលា។

| អាកប្បកិរិយា | មូលហេតុ | ដាក់វិន័យតាមបែបវិជ្ជមានលើសិស្សបែបនេះ |
|---|---|---|
| **ពិសិដ្ឋ** ជាសិស្សមិនសូវនិយាយស្ដីដោយមិនដែលចូលរួមក្នុងការពិភាក្សាក្នុងថ្នាក់រៀនឡើយ។ គាត់ចុះញ៉មយ៉ាងងាយ។ គាត់តែងពោលថា៖ "ខ្ញុំមិនឆ្លាតទេ។" | **ពិសិដ្ឋ** ជាសិស្សគ្មានការលើកទឹកចិត្តដោយមានការគោរពចំពោះខ្លួនឯងតិចតួច។ គាត់ខ្លាចបរាជ័យនិងគិតថាគាត់មិនអាចធ្វើតាមការរំពឹងទុករបស់គ្រូបានឡើយ។ | ❖ បង្ហាញសិស្សថាអ្នកយកចិត្តទុកដាក់ចំពោះពួកគេ<br>❖ ចាប់ផ្តើមពីស្ថានភាពបច្ចុប្បន្ន (មិនមែនពីអ្វីដែលពួកគេគួរតែសម្រេចឱ្យបាននោះទេ)<br>❖ បង្កើតការរំពឹងទុកប្រាកដប្រជា<br>❖ លុបបំបាត់ការរិះគន់ចំពោះការងាររបស់ពួកគេ<br>❖ លើកទឹកចិត្តដល់កិច្ចប្រឹងប្រែងរបស់ពួកគេសូម្បីតិចតួច<br>❖ លើកទឹកចិត្តឱ្យមានការបើកចំហចំពោះកំហុសដើម្បីពួកគេអាចរៀនសូត្រពីកំហុស |

**ត្រូវចងចាំ៖** អ្នកត្រូវស្តារការជឿជាក់របស់ពួកគេលើខ្លួនឯងនិងលើកទឹកចិត្តពួកគេដោយលើកសរសើរចំពោះគ្រប់ជោគជ័យដែលពួកគេសម្រេចបានទោះបីតូចតាចក៏ដោយ។ត្រូវរៀបចំចាត់ចែងដោយចេតនាដើម្បីពួកគេបានទទួលជោគជ័យលើកិច្ចការតូចតាចនិងស្វែងរកឱកាសដើម្បីលើកសរសើរពួកគេចំពោះអាកប្បកិរិយានិងការប្រឹងប្រែងវិជ្ជមានរបស់ពួកគេ។

**ត្រូវចងចាំ៖**

១. អ្នកដឹងច្បាស់ណាស់ពីអ្វីដែលអ្នកចង់បាននិងអ្វីដែលអ្នកមិនចង់បាន

២. អ្នកបង្ហាញនិងប្រាប់សិស្សរបស់អ្នកពីអ្វីដែលអ្នកចង់បាន

៣. នៅពេលអ្នកទទួលបានអ្វីដែលអ្នកចង់បានត្រូវទទួលស្គាល់អំពីវា

៤. នៅពេលដែលអ្នកទទួលបានរបស់ផ្សេងត្រូវឆ្លើយតបភ្លាមៗដោយសមស្របនិងជាវិជ្ជមាន។

៣៩ ជំពូករងនេះត្រូវបានដកស្រង់ចេញពីUNESCO, 2006, p. 43-44

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ឯកសារយោង

Baumrind, D. (1967). Child care practices ateceeding three patterns of preschool behavior. Genetic Psychology Mono graphs, 75, 43-88.

Baumrind, D. (1971). Current patterns of parental authority. Developmental Psychology Monograph, 4, (1,Pt.2).

Baumrind, D. (1978). Parental disciplinary patterns and social competence in children. Youth and Society, 9, 239-276.

Baumrind, D. (1991). Parenting styles and adolescent development. In J. Brooks-Grunn, R. Lerner & A.C. Peterson (Eds.), The Encyclopedia of Adolescence. New York: Garland.

Durrant, J. E. (2010). Positive Discipline in everyday teaching.Guidelines for educators. Save the Children Sweden.

Ertesvåg, S.K. (2011a). Improving Authoritative Teaching. Paper presented at the ICSEI Congress 2011 International Congress for School Effectiveness and Improvement. Linking Research, Policy and Practice to Promote Qual ity in Education, Limassol Cyprus, January 4-7 2011. Retrieved on 6 October 2015 from http://www.icsei.net/icsei2011/Full%20Papers/0146_B.pdf

Ertesvåg, S.K. (2011b). Measuring authoritative teaching.Teaching and teacher education, 27(1), 51-61.

Ertesvåg, S.K. (2009). Classroom leadership - The effect of a school development programme. Educational Psychology, 29(5), 515-539.

Hattje, J. (2008). Visible learning. A synthesis of over 800 meta-analyses relating to achievement. London: Routledge.

Hughes, J.N. (2002). Authoritative Teaching: Tipping the balance in favour of school versus peer effect. Journal of School Psychology, 40(6), 485-492.

Gourley, S. (2009).The middle way.Bridging the gap between Cambodian culture and children's rights.NGO commit tee on the rights of the child. Cambodia: Phnom Penh.

Kern, K.A. (2009). Attachment in middle childhood.In Cassidy, J. & Shaver, P.R. (Eds).Handbook of Attachment. Theory, Research and Clinical Applications, pp. 366-382. New York: Guilford Press.

Klem, A.M. & Connell, J.P. (2004). Relationships matter: Linking Teacher support to students' engagement and achievement. Journal of School Health, 74(7): 262-273.

Largo, R.H. (2011). Babyjahre. Entwicklung und Erziehung in den ersten vier Jahren. München: Pieper.

Largo, R.H. & Beglinger, M. (2010). Schülerjahre. Wie Kinder besser lernen. München: Pieper

Maccoby, E. E. & Martin, J. A. (1983). Socialization in the context of the family: Parent-child interaction. In P. H. Mussen (Ed.), Handbook of child psychology. Vol. 4: Socialization, personality, and social development (pp. 1–101). New York: Wiley.

Ministry of Education, Youth and Sport (2015).Child Friendly School Programme. Dimension 3: Child Health, Safety and Protection, Preventing Violence Against Children. Kingdom of Cambodia.

Ministry of Women's Affairs (2014). Findings from Cambodia's Violence Against Children Survey 2013. Steering committee on Violence Against Children. Secretariat: UNICEF Cambodia

Naker, D. & Sekitoleko, D. (2009).Positive Discipline.Alternatives to Corporal Punishment.Creating a Good School with out Corporal Punishment. (Ed.). Raising Voices, Uganda: Kampala.

Masten, A.S. & Coatsworth, J.D. (1998).The development of competences in favourable and unfavourable environ ments.American Psychological Association, 1998, 53(2): 205-220.

O'Brian, B. (2015). What Buddhism Teaches About Anger. Retrieved on 20 May 2015 from http://buddhism.about.com/od/basicbuddhistteachings/a/anger.htm

Parens, H. (2011). Handling children's aggression constructively. Toward taming human destructiveness. Lanham, MD: Jason Aronson/Rowman & Littlefield Publishers.

Pasternak, R. (2013). Discipline, learning skills and academic achievement, Journal of Arts and Education, Vol. 1(1): 1-11.

Pellerin, L.A. (2005). Applying Baumrind's parenting typology to high school: towards a middle-range theory of au thoritative socialization. Social Science Research, 34, 283-330.

Raising Voices (2009). The Good School toolkit, Kampala, Uganda, retrieved on 20 May 2015 from http://raisingvoices.org/good-school/download-good-school-toolkit/

Roorda, D.L., Koomen, H.M.Y., Spilt, J.L. & Oort, F.J. (2011). The influence of affective teacher-student relationships on students' school engagement and achievement: A meta-analytic approach, Review of Education & Educational Research, 82(4): 493-529.

Royal University of Phnom Penh, Ministry of Education, Youth and Sport (2015). Findings from the Survey: Disciplinary Methods in Cambodian Schools. Towards Positive Discipline and Effective Classroom Management. Cambo dia: Royal University of Phnom Penh.

UNESCO Bangkok (2006). Positive discipline in the inclusive, learning-friendly classroom: a guide for teachers and teacher educators. Bangkok, Thailand.

United Nations (1989).Convention on the Rights of the Child.Office of the High Commissioner for Human Rights.

Walker, J.M. (2008). Looking at teacher practices through the lens of parenting style. Journal of Experimental Education, 25(3), 453-460.

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១. គំរូប័ណ្ណ - តើខ្ញុំជាអ្នកណា ?

### ប័ណ្ណ - ខ្ញុំជាអ្នកណា ?

ឈ្មោះសិស្ស៖ ______ ខ្ញុំចង់ឱ្យគេហៅថា ______

រឿងមួយដែលអ្នកត្រូវដឹងអំពីខ្ញុំគឺ ______

ខ្ញុំចង់ធ្វើការជាមួយ ______ ខ្ញុំពូកែខាង ______

ខ្ញុំមិនពូកែខាង ______ ខ្ញុំរីករាយបំផុតនៅក្នុងថ្នាក់ នៅពេល ______

ខ្ញុំមានអារម្មណ៍មិនល្អក្នុងថ្នាក់ នៅពេល ______

ឈ្មោះសិស្ស៖ ______ ខ្ញុំចង់ឱ្យគេហៅថា ______

រឿងមួយដែលអ្នកត្រូវដឹងអំពីខ្ញុំគឺ ______

ខ្ញុំចង់ធ្វើការជាមួយ ______ ខ្ញុំពូកែខាង ______

ខ្ញុំមិនពូកែខាង ______ ខ្ញុំរីករាយបំផុតនៅក្នុងថ្នាក់ នៅពេល ______

ខ្ញុំមានអារម្មណ៍មិនល្អក្នុងថ្នាក់ នៅពេល ______

ឈ្មោះសិស្ស៖ ______ ខ្ញុំចង់ឱ្យគេហៅថា ______

រឿងមួយដែលអ្នកត្រូវដឹងអំពីខ្ញុំគឺ ______

ខ្ញុំចង់ធ្វើការជាមួយ ______ ខ្ញុំពូកែខាង ______

ខ្ញុំមិនពូកែខាង ______ ខ្ញុំរីករាយបំផុតនៅក្នុងថ្នាក់ នៅពេល ______

ខ្ញុំមានអារម្មណ៍មិនល្អក្នុងថ្នាក់ នៅពេល ______

## ឧបសម្ព័ន្ធ២. វិន័យបែបវិជ្ជមានជាការឆ្លើយតបនឹងអាកប្បកិរិយាហាមឃាត់របស់សិស្ស៖ ជម្រើសផ្សេងទៀតក្រៅពីទណ្ឌកម្មលើរាងកាយ និងស្មារតី [៣៦]

សិសិស្សណាម្នាក់ដែលប្រព្រឹត្តកំហុសណាមួយដូចមានកត់សម្គាល់នៅក្នុងជំពូក៤.៣អាចទទួលការដាក់វិន័យ ដូចខាងក្រោម។ ការដាក់វិន័យទាំងនេះ ផ្អែកទៅតាមវិធានការឆ្លើយតបចំនួន ៤ បែប។

### ការឆ្លុះបញ្ចាំង

ចំពោះបញ្ហាតូចតាចដែលកើតឡើងប្រចាំថ្ងៃ សិស្សនឹងត្រូវស្នើឱ្យឆ្លុះបញ្ចាំងលើអាកប្បកិរិយាឆ្គាំឆ្គងរបស់ពួកគេ។ កុមាររៀនសូត្រពីកំហុសរបស់ខ្លួន នៅពេលដែលពួកគេយល់ថាហេតុអ្វីទង្វើរបស់ពួកគេជាកំហុស និងនៅពេលដែលពួកគេត្រូវបានផ្តល់ឱកាសដើម្បីគិតពីផលវិបាកនៃអាកប្បកិរិយារបស់ពួកគេ។ វិធានការវិន័យ បែបនេះ រួមមាន ៖

ក. ការព្រមានផ្ទាល់មាត់៖ វិធានការនេះ រួមមាន ការនិយាយទៅសិស្ស និងការពន្យល់ប្រាប់ពួកគេអំពីអ្វីដែលជាកំហុសរបស់ពួកគេ។ វាក៏ជាការពន្យល់ប្រាប់ពួកគេផងដែរថា ប្រសិនបើពួកគេប្រព្រឹត្តបែបនេះម្តងទៀត វិធានការវិន័យបន្ថែមអាចយកមកអនុវត្តចំពោះពួកគេ។

ខ. កំណត់ពេលឱ្យនៅក្រៅថ្នាក់៖ វិធានការនេះពាក់ព័ន្ធនឹងការឱ្យកុមារចេញពីថ្នាក់រៀន៥ ឬ ១០ នាទី ឬ ឱ្យអង្គុយនៅកន្លែងស្ងាត់ និងគិតពីអាកប្បកិរិយារបស់ពួកគេ។ ដើម្បីអាចត្រលប់ចូលមកក្នុងថ្នាក់រៀនវិញ សិស្សរូបនេះត្រូវតែអាចរៀបរាប់អំពីអ្វីដែលខ្លួនធ្វើខុស និងវិធីដើម្បីចៀសវាងមិនប្រព្រឹត្តកំហុសនេះឡើងវិញ។ រយៈពេល៥ ឬ ១០ នាទី ក្រោយមកគ្រូសុំឱ្យកុមារពន្យល់ពីអ្វីដែលកុមារនោះបានធ្វើខុស។ ទង្វើនេះគួរតែធ្វើឡើងដោយម៉ឺងម៉ាត់ដោយគ្មានការធ្វើឱ្យកុមារនោះអាម៉ាស់ឡើយ។បន្ទាប់ពីនោះ គ្រូគួរអញ្ជើញសិស្សរូបនោះឱ្យត្រឡប់ចូលមកក្នុងថ្នាក់រៀនវិញ។ ប្រការសំខាន់ត្រូវចងចាំថា វិធានការនេះគឺមិនត្រឹមតែជាការបញ្ជូនសិស្សឱ្យចេញក្រៅថ្នាក់រៀនប៉ុណ្ណោះទេ។ គ្រូគួរបញ្ជូនកុមារឱ្យទៅកន្លែងណាមួយដែលសិស្សត្រូវអង្គុយគិត ដូចជា កៅអីនៅក្នុងបន្ទប់បុគ្គលិក ឬបង់ខាងក្រៅថ្នាក់របស់អ្នក។ ការទុកពេលឱ្យនៅក្រៅថ្នាក់រៀនបែបនេះមិនមែនជាការដាក់ទណ្ឌកម្មឡើយប៉ុន្តែជាការផ្តល់ឱកាសឱ្យកុមារធ្វើការឆ្លុះបញ្ចាំងពីកំហុសរបស់អាកប្បកិរិយារបស់ខ្លួន។

គ. ការសរសេរលិខិត៖ នេះអាចជាការសរសេរលិខិត ឬតែងសេចក្តីមួយអំពីមូលហេតុ ដែលពួកគេប្រព្រឹត្តបែបណាមួយ និងអ្វីដែលពួកគេត្រូវធ្វើ ដើម្បីបញ្ចៀសកំហុសបែបនេះទៅថ្ងៃមុខ។ ប្រសិនបើសមស្រប លិខិតនេះគួរបញ្ចូលពាក្យសុំទោសផងដែរ។

ឃ. ការសុំទោសផ្ទាល់មាត់៖ វិធីនេះរួមមានការសុំទោសចំពោះសិស្ស ឬអ្នកដែលរងការប្រព្រឹត្តមិនគប្បីក និងសុំការអធ្យាស្រ័យ។ សិស្ស ឬអ្នកដែលរងនូវការប្រព្រឹត្តមិនគប្បី ក៏គួរទទួលយកការសុំអភ័យទោសផងដែរ។

ច. ប្រអប់វិន័យ៖ វិធីនេះពាក់ព័ន្ធជាមួយនឹងការសរសេរឈ្មោះកុមារដាក់លើក្រដាសមួយសន្លឹក ហើយដាក់ក្រដាសនេះទៅក្នុងប្រអប់ ដែលអ្នកបានដាក់នៅក្នុងបន្ទប់រៀន។ គេត្រូវបើកប្រអប់នេះពិនិត្យជារៀងរាល់សប្តាហ៍។ អ្នកអាចកំណត់ថាប្រសិនបើកុមារមានឈ្មោះនៅក្នុងប្រអប់នេះលើសពីប៉ុន្មានដងឡើងទៅ កុមារនោះនឹងត្រូវទទួលវិន័យជាក់លាក់មួយ។

### ការដាក់វិន័យ

ចំពោះហេតុការណ៍ ដែលកើតមានជាបន្តបន្ទាប់និងបង្កគ្រោះថ្នាក់ដល់អ្នកពាក់ព័ន្ធទាំងអស់កុមារដែលប្រព្រឹត្តខុសគួរទទួលវិន័យ ដើម្បីឱ្យពួកគេយល់ពីផលវិបាកនៃសកម្មភាពរបស់ខ្លួន។ វិធានការវិន័យបែបនេះ រួមមាន៖

ក. ការតម្រូវឱ្យធ្វើកិច្ចការណាមួយឱ្យរួចរាល់៖ សិស្សត្រូវចំណាយពេលបន្ថែមក្រោយម៉ោងសិក្សា ដើម្បីឆ្លុះបញ្ចាំងពីអ្វីដែលពួកគេធ្វើខុស។ នេះក៏អាចជាការដាក់ការងារឱ្យធ្វើនៅក្នុងពេលនោះ ដូចជាសរសេរតែងសេចក្តី ឬលិខិតអ្វីមួយច្បាប់ ឬអាចត្រឹមតែជាការអង្គុយ និងធ្វើការឆ្លុះបញ្ចាំង។

៣៦ ការឆ្លើយតបវិន័យបែបវិជ្ជមានត្រូវបានដកស្រង់ចេញពី Raising Voices, The Good School Toolkit, Step 4, p. 103-107



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ខ. ការចុះហត្ថលេខាលើកិច្ចសន្យារក្សាអាកប្បកិរិយាៈ វិធីនេះរួមមានការសរសេរកិច្ចសន្យាលើក្រដាសមួយសន្លឹករវាងសិស្ស និងគ្រូ ដែលរៀបរាប់ពីកំហុសឆ្គង និងជំហាននានា ដែលត្រូវធ្វើ ដើម្បីកែតម្រូវ។ កិច្ចសន្យានេះត្រូវដាក់បញ្ចូលផលវិបាកអវិជ្ជមានផងដែរ ប្រសិនបើកំហុសនេះនៅតែបន្តកើតមានទៀត និងលទ្ធផលវិជ្ជមាន ប្រសិនបើមានការកែខ្លួន។ កិច្ចសន្យានេះត្រូវមានកំណត់ពេលវេលា និងមានការចុះហត្ថលេខា ដោយគ្រូ និងសិស្ស។ សម្រាប់កំហុសធ្ងន់ធ្ងរ កិច្ចសន្យានេះអាចត្រូវចុះហត្ថលេខាដោយឪពុកម្ដាយផងដែរ។ ចំពោះឧទាហរណ៍អំពីកិច្ចសន្យាកែប្រែអាកប្បកិរិយាសូមអានក្នុងឧបសម្ព័ន្ធ ៣។

គ. ការជជែកអំពីវិន័យជាមួយសិស្សៈ វិធីនេះរួមមានការកំណត់ពេលជួបជាមួយសិស្សដើម្បីពិភាក្សា ពីអាកប្បកិរិយារបស់ពួកគេ និងកំណត់ពីវិធីដើម្បីកែលម្អអាកប្បកិរិយានេះ។

## ការផ្ដល់សំណង

សម្រាប់កំហុសដែលនាំឱ្យមានការខូចខាតដល់ភាគីទី៣ សិស្សត្រូវផ្ដល់សំណងជាសាធារណៈ។ វិធីនេះរួមមានការទទួលស្គាល់អំពីអាកប្បកិរិយាខុសឆ្គងនៅចំពោះមុខអ្នកដទៃ និងទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន។ វិធានការវិន័យប្រភេទនេះ រួមមាន ៖

ក) ការសុំទោសជាសាធារណៈ៖ សិស្សត្រូវសុំទោសចំពោះអំពើខុសឆ្គងរបស់ខ្លួននៅចំពោះមិត្តរួមថ្នាក់ ឬចំពោះក្រុមមនុស្សដែលរងការខូចខាតដោយសារសិស្សនោះ ។

ខ) ប្ដូរ ឬជួសជុល៖ ប្រសិនបើកំហុសនេះកើតឡើងដោយចៃដន្យ សិស្សត្រូវរួមចំណែកប្ដូរ ឬជួសជុលការខូចខាតដែលខ្លួនបានបង្កឡើង ដូចជា ធ្វើរបងឡើងវិញ កាប់ឈើ ឬ លាបជញ្ជាំងឡើងវិញ។

គ) សំណងជាប្រាក់កាស៖ ប្រសិនបើកំហុសនោះកើតឡើងដោយចេតនា សិស្សរូបនោះត្រូវប្ដូរ ឬជួសជុលរបស់ខូចខាតនោះ ហើយត្រូវចេញថ្លៃសម្ភារៈដែលចាំបាច់ដើម្បីការជួសជុលនោះ។ ប្រសិនបើមិនអាចសងជាប្រាក់កាសសាលារៀនអាចតម្រូវឱ្យសិស្សនេះធ្វើពលកម្មដែលមានប្រយោជន៍ក្នុងសាលារៀន ជាការប៉ះប៉ូវការខូចខាតនេះ (ដូចជា ក្នុងករណីសិស្សធ្វើឱ្យបែកកញ្ចក់បង្អួចដោយចេតនា)។

ឃ) ការចូលរួមរបស់ឪពុកម្ដាយ៖ សាលារៀននឹងតម្រូវឱ្យឪពុកម្ដាយសិស្សរួមចំណែកក្នុងការប្ដូរជួសជុលឬសូមអភ័យទោសចំពោះការខូចខាតដែលបង្កដោយសិស្សជាកូន។

## ជម្រើសចុងក្រោយ

ចំពោះកំហុសធ្ងន់ធ្ងរដដែលៗ ពេលខ្លះ គេត្រូវចាត់វិធានការធ្ងន់ធ្ងរដែលជាជម្រើសចុងក្រោយ។ វិធានការវិន័យបែបនេះរួមមាន ៖

ក. ការស្ដីបន្ទោសជាផ្លូវការដោយនាយកសាលា៖ ក្នុងករណីដែលការជជែកអំពីវិន័យជាមួយសិស្សមិនបានផលវិធីនេះរួមមានការប្រជុំដែលមានសិស្សនោះគ្រូនិងនាយកសាលាចូលរួម។សិស្សរូបនេះត្រូវទទួលយកសេចក្ដីព្រមានជាលាយលក្សអក្សរនៅក្នុងកំណត់ត្រាឯកសារវិន័យរបស់ខ្លួននិងត្រូវចុះហត្ថលេខាលើលិខិតដើម្បីប្ដេជ្ញាធ្វើការកែប្រែ។ លិខិតនេះចែងអំពីផលវិបាកនៃការមិនកែប្រែ។

ខ) ការអញ្ជើញឪពុកម្ដាយ៖ ក្នុងករណីដែលការស្ដីបន្ទោសជាផ្លូវការដោយនាយកសាលាពុំបានផលឪពុកម្ដាយឬគ្រួសាររបស់សិស្សនោះនឹងត្រូវអញ្ជើញមកជួបនាយកសាលា។ ការប្រជុំនេះរួមបញ្ចូលឪពុកម្ដាយនាយកសាលានិងសិស្សរូបនោះ។

គ) ក្រុមប្រឹក្សាវិន័យ៖ នេះជាជំហានចុងក្រោយនៃជម្រើសចុងក្រោយ។ក្រុមប្រឹក្សាវិន័យមានសមាសភាពជានាយកសាលាក្នុងនាមជាប្រធានក្រុមប្រឹក្សាវិន័យគ្រូបង្រៀនជាជនបង្គោលក្នុងសាលានោះនិងសមាជិកមួយចំនួននៃគណៈកម្មការទ្រទ្រង់សាលារៀន។ ក្រុមប្រឹក្សានឹងជួបប្រជុំ និងពិភាក្សាជាមួយឪពុកម្ដាយនូវវិធីឆ្ពោះទៅមុខ និងចាត់វិធានការដោះស្រាយបញ្ហាប្រឈមដើម្បីគាំទ្រសិស្ស។ សកម្មភាពដែលទទួលបានការណែនាំត្រូវតែប្រកបដោយផលិតភាព និងស្របតាមចំណង់ចំណូលចិត្តកុមារ។

## ឧបសម្ព័ន្ធ៣. គំរូសម្រាប់កិច្ចសន្យាកែប្រែអាកប្បកិរិយា-ឧទាហរណ៍

- នេះជាកិច្ចសន្យារវាង (ឈ្មោះគ្រូ)៖និង (ឈ្មោះសិស្ស)៖..............................................................................
- សិស្សព្រមព្រៀង៖ ..............................................................................................................................
..............................................................................................................................
- គ្រូព្រមព្រៀងជួយសិស្សដោយ៖ ..............................................................................................................
..............................................................................................................................
- បើសិស្សបំពេញតាមកិច្ចសន្យានេះដោយជោគជ័យ៖ ..............................................................................
- ផលវិបាកពីការមិនប្រតិបត្តិតាមកិច្ចសន្យានេះ៖..............................................................................
..............................................................................................................................
- កាលបរិច្ឆេទ/វិធីសម្រាប់ពិនិត្យការរីកចម្រើន៖ ..............................................................................
- ប័ណ្ណនេះនឹងបញ្ចប់នៅកាលបរិច្ឆេទ៖ ..............................................................................

**ហត្ថលេខាសិស្ស៖**......................  **ហត្ថលេខាគ្រូ៖**..............................

**កាលបរិច្ឆេទ៖**............................  **កាលបរិច្ឆេទ៖**...............................

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ឧបសម្ព័ន្ធ៤. ការលើកសរសើរចំពោះអាកប្បកិរិយាល្អ

ចម្លើយវិជ្ជមានដែលអាចមាននិងដែលជាការលើកសរសើរសម្រាប់ប្រយោគនីមួយៗ [៣៧]

| ល.រ | ប្រយោគ | ចម្លើយវិជ្ជមានរបស់អ្នក |
|---|---|---|
| ១ | កុមារម្នាក់ពុំដែលស្លៀកពាក់ឯកសណ្ឋានមកសាលារៀនឡើយលើកលែងតែថ្ងៃនេះ។ អ្នកពោលថា "ឯកសណ្ឋានរបស់ឯងកខ្វក់ណាស់! តើមានអ្វីកើតឡើងចំពោះឯង?" | "ឯងធ្វើបានល្អណាស់ដោយ បានពាក់ឯកសណ្ឋានមករៀនថ្ងៃនេះ។ថ្ងៃស្អែកសូមឱ្យប្រាកដថាឯកសណ្ឋាននេះស្អាតផងណា។" |
| ២ | សិស្សម្នាក់កំពុងរៀនយ៉ាងសកម្មដើម្បីសរសេរភាសាអង់គ្លេសឱ្យបានល្អប៉ុន្តែនៅតែបន្តសរសេរខុស។អ្នកពោលថា "ខ្ញុំគិតថាឯងមិនពូកែភាសាអង់គ្លេសទេ។ បើឯងមិនអាចកែលម្អបានទេនៅសប្តាហ៍ក្រោយឯងនឹងត្រូវធ្លាក់មុខវិជ្ជានេះហើយ"។ | "ប្រឹងប្រែងបានល្អណាស់! ខ្ញុំអាចឃើញថាឯងប្រឹងប្រែងខ្លាំងណាស់នៅក្នុងការរៀនភាសាអង់គ្លេសក្នុងថ្នាក់។ តើមានអ្វីដែលយើងអាចជួយឯងបានទេដើម្បីឯងធ្វើបានល្អជាងនេះ?" |
| ៣ | សិស្សម្នាក់បង្កការរំខានជាខ្លាំងនៅក្នុងថ្នាក់រៀនហើយកំពុងជជែកយ៉ាងច្រើន។ អ្នកធុញទ្រាន់ចំពោះសិស្សនេះ និងពោលថា៖ "ឈប់ជជែកភ្លាម! បើឯងមិនឈប់និយាយឯងនឹងទទួលផលមិនល្អឡើយ!" | "សូមព្យាយាមផ្តល់ការគោរពចំពោះសិស្សដទៃ ដោយរក្សាភាពស្ងប់ស្ងាត់នៅក្នុងម៉ោងសិក្សា ដើម្បីឱ្យសិស្សគ្រប់គ្នាបានរៀន។" ឬស្នើឱ្យសិស្សនោះធ្វើការឆ្លុះបញ្ចាំងអំពីវិន័យក្នុងថ្នាក់រៀន "តើវិន័យក្នុងថ្នាក់រៀនចែងដូចម្តេចអំពីការជជែកនៅក្នុងម៉ោងរៀន?" |
| ៤ | កុមារម្នាក់រត់ក្នុងទីធ្លាសាលារៀនហើយអ្នកបារម្ភថាគាត់នឹងមានរបួស។ ហើយគាត់ក៏រំលោភលើវិន័យផងដែរ។ អ្នកពោលថា "ឈប់រត់ឥឡូវនេះភ្លាមបើពុំនោះទេឯងនឹងទទួលទណ្ឌកម្ម!" | "សូមដើរវិញ។ បើឯងរត់ឯងអាចរងរបួសហើយឯងក៏បំពានវិន័យសាលារៀនផងដែរ។" |
| ៥ | កុមារម្នាក់មករៀនយឺតពេលជាលើកទីបីក្នុងសប្តាហ៍នេះ។ អ្នកធ្វើមិនដឹងចំពោះភាពយឺតយ៉ាវកន្លងមកប៉ុន្តែអ្នកចាប់អារម្មណ៍ថាអ្នកត្រូវនិយាយអ្វីម្យ៉ាង។ អ្នកពោលថា "នេះជាលើកទីបីហើយដែលឯងមករៀនយឺតពេលក្នុងសប្តាហ៍នេះ! តើឯងមានរឿងអ្វី?" | "នេះជាលើកទីបីដែលឯងមកយឺតក្នុងសប្តាហ៍នេះ។ ឯងត្រូវស្ថិតនៅក្នុងថ្នាក់នៅពេលសិស្សដទៃចេញដើម្បីបំពេញម៉ោងដែលបាត់បង់ ហើយយើងនឹងជជែកអំពីមូលហេតុដែលភាពយឺតយ៉ាវនេះនៅតែបន្តកើតមាន។" |
| ៦ | អាកាសខាងក្រៅក្តៅខ្លាំងណាស់ ហើយកុមារម្នាក់ខ្ជះខ្ជាយទឹកដោយទុកឱ្យទឹកហូរចោលក្នុងពេលដាក់ក្បាលនៅពីក្រោមទឹករ៉ូប៊ីនេដើម្បីឱ្យត្រជាក់។ អ្នកពោលថា៖ "តើឯងមានរឿងអី? ឯងកំពុងខ្ជះខ្ជាយទឹក! ឯងចង់ដឹងថាអារម្មណ៍ក្តៅនោះមានបែបណាទេ? ឯងត្រូវចេញទៅឈរនៅកណ្តាលថ្ងៃរហូតដល់ពេលដែលខ្ញុំអាចឱ្យឯងចូលមកក្នុងវិញ!" | "ខ្ញុំដឹងថាខាងក្រៅក្តៅខ្លាំងណាស់ ហើយយើងទាំងអស់គ្នាគ្មានអារម្មណ៍ល្អទេ។ ប៉ុន្តែខ្ញុំគិតថាឯងយល់តើការប្រើទឹកមានបំណងអ្វី។ សិស្សទាំងអស់ត្រូវការទឹកដើម្បីសំអាតខ្លួន។ តើនឹងមានអ្វីកើតឡើងបើឯងប្រើប្រាស់ទឹកនេះអស់?" ចូរផ្តល់ឱកាសឱ្យសិស្សនេះអង្គុយក្នុងបន្ទប់រយៈពេលប្រាំនាទីដើម្បីគិតថាតើទឹកសំខាន់ប៉ុណ្ណា ឬ ដើម្បីសុំការអភ័យទោសដែលប្រើទឹកខុសរបៀប។ |

[៣៧] សកម្មភាពនេះត្រូវបានដកស្រង់ចេញពីRaising Voices, The Good School Toolkit, Step 4, Module 4.7

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews